ព្រឹត្តិបត្រ

# មេធាវី

# BULLETIN METHEAVY

ចេញផ្សាយប្រចាំត្រីមាសខែ មេសា-មិថុនា ឆ្នាំ២០១៧ លេខ១៣

# យុត្តិធម៌ និង ច្បាប់

# JUSTICE AND LAW

ការផ្សាយរបស់គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

អាសយដ្ឋានអគារកាច់ជ្រុងផ្លូវលេខ ១១២៩ កែងផ្លូវ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ : (៨៨៥-២៣) ៦២២ ៧០៧០ អ៊ីម៉ែល : info@bakc.org.kh គេហទំព័រ : www.bakc.org.kh

# ព្រឹត្តិបត្រមេធាវី

លេខ ១៣

ខែ មេសា-មិថុនា ឆ្នាំ ២០១៧

រក្សាសិទ្ធិ © 2017 គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

មតិដែលសំដែងនៅក្នុងព្រឹត្តិបត្រនេះ គឺជាមតិរបស់អ្នកនិពន្ធផ្ទាល់ ហើយមិនមែនបានសេចក្តីថាឆ្លុះបញ្ចាំងនូវទស្សនៈរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាទេ។

ស្របតាមគោលការណ៍សេរីភាពនៃការបញ្ចេញមតិ ដែលជាគោលការណ៍គ្រឹះ និងមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គណៈមេធាវីគាំទ្រឱ្យមានភាពចម្រុះនៃមតិនានា។

ទំព័រ

# មាតិកា

សារពីប្រធានគណៈមេធាវី ....................................................................................iii

## ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

**ទណ្ឌិត ខុច និងសិទ្ធិទទួលបានការលើកលែងទោស** ....................................1

១. សេចក្តីផ្តើម ....................................................................................1

២. ខុច និងសិទ្ធិទទួលបានការលើកលែង ឬការបន្ធូរបន្ថយទោស....................................3

២.១. ការលើកលែងទោស និងបន្ធូរបន្ថយទោសក្រោមច្បាប់អន្តរជាតិ........................3

២.២. សិទ្ធិក្នុងការទទួលបានការលើកលែងទោស និង បន្ធូរបន្ថយទោសក្រោមវិធានច្បាប់អន្តរជាតិ ....................................................................................4

២.៣. សិទ្ធិទទួលបានការលើកលែង ឬបន្ធូរបន្ថយទោសក្រោមច្បាប់កម្ពុជា.................5

៣. សង្ខេប....................................................................................11

៤. សេចក្តីដកស្រង់ច្បាប់....................................................................................11

**មូលហេតុនៃបណ្តឹងសាទុក្ខ ក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជា( ភាគ ១ )** ..............16

១. សេចក្តីផ្តើម ....................................................................................16

២. មូលហេតុនៃបណ្តឹងសាទុក្ខ ....................................................................................16

២.១ សមាសភាពមិនស្របច្បាប់នៃតុលាការ....................................................17

## ផ្នែកពាណិជ្ជកម្ម

**អនុប្បទានគណនី** ....................................................................................21

១. សេចក្តីផ្តើម ....................................................................................21

២. អ្វីដែលហៅថា "គណនី"? ....................................................................................22

៣. ការធានាកាតព្វកិច្ចដោយការធ្វើអនុប្បទានគណនី ....................................................24

៤. ការធ្វើសុក្រឹតកម្មនៃគណនី.....27

៥. ការអនុវត្តសិទ្ធិនៃអនុប្បទានគណនី.....28

៦. ការលក់គណនី.....28

៧. សេចក្តីសន្និដ្ឋាន.....30


## ផ្នែករដ្ឋប្បវេណី


**ហ៊ីប៉ូតែក**.....31

**កំជាប់ពាក្យ**.....35


## ច្បាប់កម្ពុជាក្នុងទិដ្ឋភាពអន្តរជាតិ


**ច្បាប់សន្តិកម្មកម្ពុជាក្នុងទិដ្ឋភាពអន្តរជាតិ(ភាគ ១)**.....38

១. សេចក្តីផ្តើម.....38

២. ក្នុងទិដ្ឋភាពអន្តរជាតិ.....39


## សកម្មភាពរបស់គណៈមេធាវី


១. មហាសន្និបាតប្រចាំឆ្នាំរបស់គណៈមេធាវី ដើម្បីបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី អាណត្តិទី ១១ និងពិធីផ្ទេរតំណែងប្រធានគណៈមេធាវី.....44

២. គោលនយោបាយមូលនិធិសុខុមាលភាពមេធាវី.....45

៣.ទំនាក់ទំនងជាតិ និងអន្តរជាតិ.....52

    ៣.១ ទំនាក់ទំនងជាតិ.....52

    ៣.២ ទំនាក់ទំនងអន្តរជាតិ.....54

៤. មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី.....59

៥. ផ្សេងៗ.....63

# សារពីប្រធានគណៈមេធាវី



ក្រោយពីមានការផ្អាកការបោះផ្សាយព្រឹត្តិបត្រមេធាវីមួយរយៈកន្លងមក គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាមានកិត្តិយសជាថ្មី សូមបោះបន្តនូវព្រឹត្តិបត្រ មេធាវីលេខ ១៣ សម្រាប់ត្រីមាសខែមេសា-មិថុនា ឆ្នាំ២០១៧ ។ ព្រឹត្តិបត្រមេធាវីនេះ បានសម្រេចឡើងដោយការប្រឹងប្រែងលះបង់ពេលវេលាដ៏មានតម្លៃរបស់អ្នកនិពន្ធនីមួយៗ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍របស់គាត់។ តាងនាមឱ្យគណៈមេធាវី ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកនិពន្ធដែលបានរួមចំណែកវិភាគទានអត្ថបទរបស់ខ្លួន។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់លោកអគ្គលេខាធិការ លោកអគ្គលេខាធិការរង ប្រធាន និងបុគ្គលិកនាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយនៃគណៈមេធាវី ដែលបានខិតខំរៀបចំពិនិត្យ និងសម្រួលអត្ថបទ និងការបោះពុម្ពព្រឹត្តិបត្រលេខនេះ។

ព្រឹត្តិបត្រលេខនេះប្រមូលផ្តុំនូវអត្ថបទនៅក្នុងវិស័យនានានៃច្បាប់ ដូចជា ច្បាប់អន្តរជាតិ ច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់ព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី និងច្បាប់ពាណិជ្ជកម្មជាដើម។ បន្ថែមលើការផ្សាយនូវអត្ថបទច្បាប់ ព្រឹត្តិបត្រមេធាវីបានផ្តល់ព័ត៌មានស្តីពីសកម្មភាពនៃគណៈមេធាវី ដើម្បីឲ្យសហភាតាជាមេធាវីបានជ្រាបពីកិច្ចដំណើការនៃគណៈមេធាវី។ គណៈមេធាវីនឹងស្វះស្វែងទាក់ទងមេធាវី និងអ្នកច្បាប់ដទៃទៀត ដើម្បីពង្រីកការចែករំលែកនូវចំណេះដឹងនៅក្នុងវិស័យដទៃទៀត នៅក្នុងការផ្សាយលើកក្រោយៗ។

ការបោះពុម្ពផ្សាយព្រឹត្តិបត្រមេធាវីនេះជាការឆ្លើយតបទៅនឹង**ទិសដៅទី ២ "ពង្រឹង និងការពារវិជ្ជាជីវៈ"** នៃ**ផែនការសកម្មភាពនៃគណៈមេធាវី** ដែលបានអនុម័តដោយក្រុមប្រឹក្សា-គណៈមេធាវី។

ខ្ញុំសង្កេតឃើញថា នៅក្នុងសហគមន៍អ្នកច្បាប់នៅក្នុងប្រទេសកម្ពុជាយើង មានអ្នកជំនាញខាងច្បាប់ជាច្រើនដែលបានសរសេរផ្សព្វផ្សាយសៀវភៅសិក្សា ដើម្បីបម្រើសេចក្តីត្រូវការនៃអ្នកសិក្សាច្បាប់។ ទោះបីមិនមែនជាអ្នកជំនាញក៏ដោយ ខ្ញុំសូមលើកទឹកចិត្តដល់មេធាវី

និងអ្នកសិក្សាទូទៅចូលរួមវិភាគទានអត្ថបទដើម្បីចុះផ្សាយក្នុងព្រឹត្តិបត្រមេធាវី។ គណៈមេធាវីស្វាគមន៍ជានិច្ចដល់ការចូលរួមចែករំលែកអត្ថបទរបស់ខ្លួននៅក្នុងព្រឹត្តិបត្រនេះ។ ចំពោះអ្នកដែលមានបំណិនខាងសរសេរមានកម្រិត គណៈមេធាវីមានក្រុមបណ្ណាធិការមួយដែលនឹងជួយផ្តល់ការណែនាំដល់អ្នកចូលរួម និងជួយកែសម្រួលអត្ថបទ។ គោលដៅនៃការបង្កើតព្រឹត្តិបត្រនេះ មិនត្រឹមតែផ្សព្វផ្សាយអត្ថបទនៃអ្នកនិពន្ធជើងចាស់តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយលើកស្ទួយបំណិនខាងសរសេរដល់អ្នកនិពន្ធជំនាន់ក្រោយផងដែរ។

ខ្ញុំយល់ឃើញថា ថ្វីបើក្រុមបណ្ណាធិការបានផ្ចិតផ្ចង់ក្នុងការធ្វើឲ្យព្រឹត្តិបត្រទទួលបានគុណភាពមួយដ៏ខ្ពស់ក៏ដោយ ការខ្វះខាតគង់តែជៀសមិនផុត។ ដើម្បីជ្រោមជ្រែងឲ្យព្រឹត្តិបត្រនេះមានគុណភាពកាន់តែប្រសើរ ខ្ញុំសូមអំពាវនាវដល់អ្នកអានមេត្តាសរសេរតប និងរិះគន់ស្ថាបនា ធ្វើអត្ថាធិប្បាយ ឬបំពេញបន្ថែមទៅលើអត្ថបទនីមួយៗដែលបានបោះពុម្ពផ្សាយ។ ខ្ញុំសង្ឃឹមថា សហភាគា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីនឹងបានរីករាយក្នុងការអានព្រឹត្តិបត្រមេធាវីលេខនេះ។

ចំពោះការចូលរួមវិភាគអត្ថបទ សូមធ្វើការទាក់ទងមកការិយាល័យគណៈមេធាវីដោយផ្ទាល់តាមអ៊ីម៉ែល info@bakc.org.kh ឬតាមរយៈលោកមេធាវី **កុយ នាម** តាមអ៊ីម៉ែល neam130@bakc.org.kh និងលោក **កែ ប៊ុនធឿន** តាមអ៊ីម៉ែល bunthoeurn@bakc.org.kh ក៏បាន។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់សហភាគា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីទាំងអស់ សូមជួបតែជោគជ័យគ្រប់ប្រការ។

សូមអរគុណ!



**សួន វិសាល**

ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

# ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

# ទណ្ឌិត ឌុច និងសិទ្ធិទទួលបានការលើកលែងទោស ឬការបន្ធូរបន្ថយទោស

ដោយមេធាវី **មាស ប៉ូវ៉ា***

## ១. សេចក្តីផ្តើម

លោក **ឌុច** ជាអតីតមេគុកទួលស្លែង ជាកន្លែងដែលគាត់ត្រូវបានចោទថា បានប្រព្រឹត្ត ឬចូលរួមក្នុងការធ្វើទារុណកម្ម សម្លាប់ ឬធ្វើឲ្យជនរងគ្រោះស្លាប់ជាង ១២.០០០នាក់។[1] សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានចោទប្រកាន់លើអង្គហេតុនេះ ក្នុងចំណោមអង្គហេតុទាំងឡាយតាមដីកាបញ្ជូនរឿងឲ្យស៊ើបសួរចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧។[2] ក្រោយពីទទួលបានដីកា សហចៅក្រមស៊ើបអង្កេតបានធ្វើការស៊ើបអង្កេត និងបញ្ជូន **ឌុច** ទៅជំនុំជម្រះ ដោយអង្គជំនុំជម្រះសាលាដំបូងពីបទមនុស្សឃាត តាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពាក់ព័ន្ធនឹងអង្គហេតុនៃគុកទួលស្លែង។[3] អង្គជំនុំជម្រះ បានសម្រេចសេចក្តីកាត់ទោស **ឌុច** ដាក់ពន្ធនាគារចំនួន ៣៥ ឆ្នាំ (កាត់រយៈពេល ៥ ឆ្នាំ នៃការឃុំខ្លួនខុសច្បាប់មុនបញ្ជូនមក អ.វ.ត.ក)។[4] សហព្រះរាជអាជ្ញាបានប្តឹង

---

* លោកមេធាវី **មាស ប៉ូវ៉ា** បានបញ្ចប់បរិញ្ញាបត្រច្បាប់នៅមហាវិទ្យាល័យច្បាប់ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចភ្នំពេញ ឆ្នាំ១៩៩៨។ ឆ្នាំ២០០៧ លោកទទួលបានបណ្ឌិតច្បាប់ ជំនាញច្បាប់អន្តរជាតិ ពីសាកលវិទ្យាល័យ ណាហ្គូយ៉ា ប្រទេសជប៉ុន។

ក្រៅពីការបង្រៀនច្បាប់សិទ្ធិមនុស្ស និងច្បាប់អន្តរជាតិ លោកជាសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា (CUS) ទទួលបន្ទុកកិច្ចការងារស្រាវជ្រាវ និងជាប្រធានក្រុមអ្នកច្បាប់នៃការិយាល័យសហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

លោកមេធាវីបានសិក្សាស្រាវជ្រាវ និងសរសេរអត្ថបទជាច្រើន ពាក់ព័ន្ធនឹងច្បាប់ព្រហ្មទណ្ឌជាតិ និងអន្តរជាតិ សិទ្ធិមនុស្ស ច្បាប់អន្តរជាតិទូទៅ និងបត្យាប័ន។

[1] សហព្រះរាជអាជ្ញាអន្តរជាតិ, ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, D3, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧។ អង្គជំនុំជម្រះសាលាដំបូង, សាលក្រម, E188, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, កថាខណ្ឌ ២៣។

[2] សហព្រះរាជអាជ្ញាអន្តរជាតិ, ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ (ដូចខាងលើ)។

[3] សហចៅក្រមស៊ើបអង្កេត, ដីកាដំណោះស្រាយ ចោទប្រកាន់ កាំងហ្គេក អ៊ាវ ហៅ ឌុច, D99, ថ្ងៃទី៨ ខែសីហា ឆ្នាំ ២០០៨។

[4] សាលក្រមនៃអង្គជំនុំជម្រះ, លេខយោងទី១, កថាខណ្ឌ ៦៣១-៦៣២។

ឧទ្ធរណ៍ទៅអង្គជំនុំជម្រះតុលាការកំពូល ជំទាស់នឹងរយៈពេលនៃទោសដាក់ពន្ធនាគារ។[5] អង្គជំនុំ-ជម្រះនេះបានសម្រេចដាក់ទោស **ឌុច** មួយជីវិត។ នាពេលនេះ **ឌុច** កំពុងអនុវត្តទោសនៅក្នុងពន្ធនាគារខេត្តកណ្ដាល។[6]

មាត្រា ៤០ ថ្មី នៃច្បាប់ ស្ដីពី ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ច្បាប់ អ.វ.ត.ក) បានចែងថា៖ *"រាជរដ្ឋាភិបាលកម្ពុជា មិនអាចស្នើសុំឱ្យមានការលើកលែងទោស ឬការអនុគ្រោះទោសដល់ជនទាំងឡាយណាដែលអាចត្រូវបានស៊ើបអង្កេត ឬត្រូវបានផ្ដន្ទាទោសអំពីឧក្រិដ្ឋកម្ម ដែលមានចែងក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧, និងមាត្រា ៨ នៃច្បាប់នេះបានឡើយ។ វិសាលភាពនៃការលើកលែងទោស ឬ អនុគ្រោះទោស ដែលអាចត្រូវបានផ្ដល់ឲ្យមុនការអនុម័តច្បាប់នេះ គឺត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ"*។ ស្រដៀងគ្នានេះ មាត្រា ១១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (កិច្ចព្រមព្រៀង ស្ដីពី អ.វ.ត.ក) បានចែងថា៖ *"រាជរដ្ឋាភិបាលកម្ពុជានឹងមិនស្នើសុំឲ្យមានការលើកលែងទោស ឬអនុគ្រោះទោសដល់ជនទាំងឡាយណា ដែលអាចនឹងត្រូវស៊ើបអង្កេត ឬនឹងត្រូវផ្ដន្ទាទោសអំពីឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះទេ"*។

ការពិនិត្យជាបឋមលើខ្លឹមសារនេះ នាំឲ្យមានមន្ទិលផ្លូវច្បាប់ថាតើ **ឌុច** មានសិទ្ធិទទួលបានការបន្ធូរបន្ថយ អនុគ្រោះ ឬលើកលែងទោសដែរឬទេ? និយាយជាសាមញ្ញ តើមាត្រានេះដកហូតសិទ្ធិសេរីភាពរបស់ **ឌុច** ដែរឬទេ?។ បុគ្គលខ្លះ ពិតជាអាចឆ្លើយថា ដោយសារទណ្ឌិត **ឌុច** ជាឧក្រិដ្ឋជន សាហាវយង់ឃ្នង ហើយបានប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ គាត់គ្មានសិទ្ធិទទួលបានការលើកលែង ឬបន្ធូរបន្ថយទោសទេ។ អត្ថបទនេះ អះអាងថា ដោយសារច្បាប់សិទ្ធិមនុស្ស និងយុត្តិធម៌ក្នុងវិស័យព្រហ្មទណ្ឌ (Criminal Justice) មានតួនាទីបំពេញឲ្យគ្នាទៅវិញទៅមក ក្នុងន័យថា ឧក្រិដ្ឋជនប្រព្រឹត្តបទឧក្រិដ្ឋ មិនមែនត្រូវបានបំបិទសិទ្ធិទាំងស្រុងទេ។ ការបកស្រាយផ្ទុយពីនេះ នាំឲ្យវត្តមាននៃប្រព័ន្ធយុត្តិធម៌ និងសិទ្ធិមនុស្សមានភាពមិនចាំបាច់ និងចាកឆ្ងាយពីគោលបំណងនៃមាត្រាទាំងពីរ និងផ្ទុយច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣។ អត្ថបទនេះ បង្ហាញថា ទណ្ឌិត **ឌុច** មានសិទ្ធិក្នុងការទទួលបានការលើកលែង ឬបន្ធូរបន្ថយទោស ដូចទណ្ឌិតដទៃទៀត ក្នុងនាមជាប្រជាពលរដ្ឋខ្មែរ ដែលសិទ្ធិរបស់ពួកគេត្រូវបានធានាដោយច្បាប់រដ្ឋធម្មនុញ្ញ។

---

[5] អង្គជំនុំជម្រះតុលាការកំពូល, សាលដីកា, F28, ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២, ផ្នែកទី ៨ (សេចក្ដីសម្រេច)។

[6] គិតមកដល់ថ្ងៃចេញសាលដីកា **ឌុច** អនុវត្តន៍ទោសពន្ធនាគារបានរយៈ ១២ឆ្នាំ និង ២៦៩ថ្ងៃ (នេះរាប់បញ្ចូលនូវរយៈពេលក្នុងមន្ទីរឃុំឃាំង មុនបញ្ជូនមកសាលាក្ដីខ្មែរក្រហម)។

ដើម្បីបង្កើតបានជំហរនេះ ជាបឋមអត្ថបទនឹងពិនិត្យមើលថាតើច្បាប់អន្តរជាតិ និងច្បាប់ជាតិមានចែងអំពីសិទ្ធិទទួលបានការលើកលែង ឬបន្ធូរបន្ថយទោសដែរឬទេ? ប្រសិនបើមាន តើមាត្រាទាំងនេះ បានដកហូតសិទ្ធិសេរីភាពរបស់ **ឌុច** ដែរឬទេ?។

## ២. ឌុច និងសិទ្ធិទទួលបានការលើកលែង ឬការបន្ធូរបន្ថយទោស

### ២.១. ការលើកលែងទោស និងបន្ធូរបន្ថយទោសក្រោមច្បាប់អន្តរជាតិ

ជាដំបូង មានពាក្យចំនួនបី ដែលត្រូវបំភ្លឺ៖ "**ការលើកលែងទោស**" (Amnesty) "**ការអនុគ្រោះទោស**" (Pardon) និង "**ការបន្ធូរបន្ថយទោស**" (Reduction of Sentence)។ ការបន្ធូរបន្ថយទោស ជាការកាត់បន្ថយទោសឲ្យសល់រយៈពេលកាន់តែខ្លី និងឆាប់បញ្ចប់ទោស ដែលត្រូវអនុវត្ត។ ការលើកលែងទោសមានពីរប្រភេទគឺ៖ ការលើកលែងទោសជាទូទៅ (General Amnesty) និងការលើកលែងទោសធម្មតា (Normal Amnesty)។ ប្រភេទទីមួយ សំដៅលើការលើកលែងទោសដល់ជនប្រព្រឹត្តឧក្រិដ្ឋជាក្រុម តាមរយៈច្បាប់អនុម័ត ដោយសភា។ ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់[7] ដោយប្រយោល ស្ថិតចូលក្នុងប្រភេទនេះ។ ប្រភេទទីពីរ ផ្តល់ជូនដោយព្រះមហាក្សត្រ (ករណីកម្ពុជា)។ នេះខុសពីការបន្ធូរបន្ថយទោស ពីព្រោះការលើកលែងទោស និងបញ្ចប់ការអនុវត្តទោសដែលនៅសល់ ហើយ ទណ្ឌិតនឹងមានសេរីភាពវិញ។ ជាទូទៅ ទណ្ឌិតត្រូវបំពេញលក្ខខណ្ឌមួយចំនួន ដូចជាការកែប្រែអត្ត-ចរិតឲ្យល្អ ហើយទទួលទោសក្នុងពន្ធនាគារបានរយៈពេលកំណត់ណាមួយ មុននឹងទទួលបានការលើកលែងទោស។ ការលើកលែងទោសធម្មតា អាចត្រូវបានហៅថា ជាការអនុគ្រោះទោស។

ជាទូទៅ ការលើកលែងទោសមិនមានភ្ជាប់នូវលក្ខខណ្ឌ ឬជាប់កាតព្វកិច្ចអ្វីទេ។ ការលើកលែងទោសធម្មតាខុសពីការត្រួតពិនិត្យតាមផ្លូវតុលាការ (Judicial Supervision) (ដោយចៅក្រមស៊ើបអង្កេត) ក្នុងអំឡុងមុនពេលសវនាការ ដាក់ឲ្យជនត្រូវចោទនៅក្រៅមន្ទីរឃុំឃាំងជាមួយលក្ខខណ្ឌនៃការគោរពកាតព្វកិច្ចមួយចំនួន។[8] លើកលែង ករណីលើកលែងទោសជាទូទៅ ការលើកលែងទោសធម្មតា មិនបានបញ្ចប់នូវសំណងរដ្ឋប្បវេណីដល់ជនរងគ្រោះឡើយ។[9]

---

[7] ច្បាប់ស្តីពី ការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ ឆ្នាំ១៩៩៤។

[8] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៧, មាត្រា ២២៣។

[9] ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩, មាត្រា ៧។

## ២.២. សិទ្ធិក្នុងការទទួលបានការលើកលែងទោស និង បន្ធូរបន្ថយទោសក្រោមវិធានច្បាប់អន្តរជាតិ

មាត្រា ៦ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ចែងអំពីសិទ្ធិរស់រានមានជីវិត ហើយក្នុងនោះបានចែងករណីលើកលែងចំពោះការអនុវត្តទោសប្រហារជីវិត។ បន្ថែមពីលើនេះ មាត្រានេះ បានចែងតម្រូវឲ្យមានការបន្ធូរបន្ថយទោស ពីទោសប្រហារជីវិត មកជាទោសដាក់ពន្ធនាគារមួយជីវិត។ មាត្រា ១៤ នៃកតិកាសញ្ញាដដែល បានចែងនូវការលើកលែង ឬបន្ធូរបន្ថយទោស ក្នុងករណីមានការប្រព្រឹត្តអយុត្តិធម៌ (Miscarriage of Justice)។[10] ជារួម មាត្រាទាំងពីរចែងឲ្យមានសិទ្ធិក្នុងការបន្ធូរបន្ថយទោស ឬលើកលែងទោស។ ទោះបីជាគេអាចនិយាយថា មាត្រានេះអនុវត្តចំពោះតែករណីបុគ្គលទទួលទោសប្រហារជីវិត ហើយមិនអនុវត្តសម្រាប់ករណីដទៃទៀតដូចជា ករណីបុគ្គលទទួលទោសដាក់ពន្ធនាគារមានរយៈពេលកំណត់ ឬការបន្ធូរបន្ថយទោស និងការលើកលែងទោស ដោយផ្អែកលើមូលដ្ឋានផ្សេងៗទៀត ដូចជាការកែចរិតមារយាទបានល្អ វាជាការមិនត្រឹមត្រូវទេ ពីព្រោះការដាក់ពន្ធនាគារសុទ្ធ គឺជាការកម្រិតសិទ្ធិមួយដែលត្រូវធ្វើឡើងក្នុងករណីចាំបាច់ ហើយការប្រាស្រ័យសិទ្ធិ គឺជាវិធានទូទៅ។[11] គោលបំណងរបស់កតិកាសញ្ញា គឺដើម្បីការពារ និងធានាសិទ្ធិបុគ្គល។ ដូចនេះ ការលើកនូវភាពខ្វះខាតមិនបានចែង ឬចែងមិនគ្រប់ជ្រុងជ្រោយ ដើម្បីបដិសេធសិទ្ធិបុគ្គល អាចនឹងផ្ទុយនឹងគោលបំណងនេះ។ ការបកស្រាយរបៀបនេះ ក៏អាចនឹងនាំឲ្យមានការប្រព្រឹត្តមិនស្មើគ្នារវាងប្រភេទនៃទណ្ឌិត ហើយបើសិនគ្មានហេតុផលសមស្រប នោះនឹងនាំឲ្យរំលោភគោលការណ៍មិនរើសអើង ដែលមានចែងក្នុងកតិកាសញ្ញានេះផងដែរ។[12] បន្ថែមពីលើនេះ ការប្រព្រឹត្តខុសគ្នា អាចនឹងមិនស្របទៅនឹងគោលការណ៍ស្តានីតិសម្បទានៃប្រព័ន្ធដាក់ទណ្ឌកម្ម។[13]

---

[10] កម្ពុជាបានចូលជាភាគីនៃកតិកាសញ្ញាស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ ក្នុងឆ្នាំ១៩៩២ (the International Covenant on Civil and Political Rights (ICCPR), Res. 2200A (XXI) of 16 December 1966).

[11] Handyside v. United Kingdom, គណៈកម្មការសិទ្ធិមនុស្ស អឺរ៉ុប, ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៥, យោងក្នុង Nihal Jayawickrama, ការអនុវត្តសិទ្ធិមនុស្សតាមផ្លូវតុលាការ, យុត្តិសាស្រ្តជាតិ អន្តរជាតិ និងតំបន់ ឆ្នាំ២០០២, ទំព័រ ១៨៤។ គណៈកម្មាធិការសិទ្ធិមនុស្ស, យោបល់ទូទៅលេខ ៣៤ ស្តីពីមាត្រា ៩ (សេរីភាពបញ្ចេញមតិ និងយោបល់) CCPR/C/GC/34, 12 September 2011, កថាខណ្ឌទី ២២។

[12] កតិកាសញ្ញា, លេខយោងទី ១០, មាត្រា ២។

[13] បទដ្ឋានអប្បបរមា សម្រាប់ការប្រព្រឹត្តលើទណ្ឌិត អនុម័តដោយសន្និបាតអង្គការសហប្រជាជាតិលើកទី ១ ស្តីពីការបង្ការ និងការប្រព្រឹត្តលើជនល្មើស, ទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៥ (approved by the Economic and Social Council by its resolutions 663 C (XXIV) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៥៧ និង 2076 (LXII) ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៧, កថាខណ្ឌទី ៨០។

## ២.៣. សិទ្ធិទទួលបានការលើកលែង ឬបន្ធូរបន្ថយទោសក្រោមច្បាប់កម្ពុជា

មានបទប្បញ្ញត្តិនៃច្បាប់ជាច្រើនរបស់កម្ពុជា ចែងអំពីការលើកលែងទោស ឬបន្ធូរ-បន្ថយទោស (សូមមើលឧបសម្ព័ន្ធ) ដោយផ្ទាល់ ឬប្រយោល ដូចជាច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ និងច្បាប់ស្តីពីពន្ធនាគារឆ្នាំ ២០១១ ជាដើម។ ច្បាប់បានចែងនូវការលើកលែងទោសជាទូទៅ[14] និងលើកលែងទោសធម្មតា ដោយព្រះមហាក្សត្រ។[15] មាត្រា ៧៧ នៃច្បាប់ពន្ធនាគារផ្តល់បុព្វសិទ្ធិដល់រាជរដ្ឋាភិបាលក្នុង ការស្នើសុំនៅពេលណាក៏បាន នូវការលើកលែងទោសដល់ទណ្ឌិត។[16] បន្ថែមពីលើនេះ លិខិត បទដ្ឋានគតិយុត្តក៏អនុញ្ញាតឲ្យមានការបន្ធូរបន្ថយទោសផងដែរ។[17] មានភាពមិនច្បាស់លាស់ ថា ពាក្យ "**ទណ្ឌិត**" សំដៅលើបុគ្គលមានទោស តាមសាលក្រមស្ថាពរឬយ៉ាងណា? ក្នុងករណី ដែលពាក្យនេះសំដៅលើតែបុគ្គល ដែលត្រូវបានប្រកាសថាមានទោស តាមរយៈសាលក្រមមិន ទាន់ស្ថាពរ វាមានន័យថា រាជរដ្ឋាភិបាលអាចស្នើលើកលែងទោសដល់អ្នកដែលមិនទាន់មាន ទោសតាមសាលក្រមស្ថាពរ ហាក់មិនស៊ីសង្វាក់គ្នាជាមួយនឹងខ្លឹមសារមាត្រាដទៃទៀត ដែល អនុញ្ញាតឲ្យលើកលែងទោស ឬបន្ថយទោស ក្នុងករណីអនុវត្តទោសក្នុងពន្ធនាគារអស់រយៈ ពេលកំណត់ណាមួយ តាមរយៈសាលក្រមស្ថាពរ។[18]

បទប្បញ្ញត្តិពាក់ព័ន្ធ មិនបានប្រើប្រាស់ពាក្យ "**អនុគ្រោះទោស**" ដូចមាត្រា ៤០ថ្មី និង មាត្រា ១១ ដែលបានដកស្រង់ក្នុងទំព័រមុនទេ។ វាអាចដូចគ្នានឹងន័យនៃការលើកលែងទោស ធម្មតា ដោយព្រះមហាក្សត្រមួយឆ្នាំ បីដង ក្នុងពិធីបុណ្យជាតិសំខាន់ៗ។[19] ទោះបីជាយ៉ាងនេះក្តី បន្ថែមពីលើខ្លឹមសារនៃមាត្រា ៧៧ នៃច្បាប់ស្តីពី ពន្ធនាគារ ការអនុវត្តកន្លងមក ព្រះមហាក្សត្រ ក៏អាចលើកលែងទោសដល់ទណ្ឌិតដែលមិនទាន់បានអនុវត្តទោស កំណត់ក្នុងសាលក្រមកំបាំងមុខ ផងដែរ។ នេះគឺជាករណីលើកលែងទោសដល់លោក **អៀង សារី** ដែលជាអតីតនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលត្រូវ បានកាត់ទោសកំបាំងមុខ ដោយតុលាការប្រជាជនបដិវត្តន៍ក្រុងភ្នំពេញ ខែសីហា ថ្ងៃទី១៩ ឆ្នាំ ១៩៧៩។[20]

---

14 ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា ៩០(ថ្មី)។

15 ដូចលេខយោងខាងលើ, មាត្រា ២៧។

16 ច្បាប់ស្តីពី ពន្ធនាគារកម្ពុជា ឆ្នាំ២០១១។

17 សូមមើលឧបសម្ព័ន្ធ ស្តីពី ច្បាប់ និងបទប្បញ្ញត្តិ។

18 គួរតែមានការស្រាវជ្រាវអំពីអត្ថន័យនៃពាក្យ «ទណ្ឌិត» ឬខ្លឹមសាររួមនៃមាត្រា ៧៧ នៃច្បាប់ស្តីពី ពន្ធនាគារ។

19 ក្រឹត្យច្បាប់លេខ ២៨ ឆ្នាំ១៩៨៨ របស់ក្រុមប្រឹក្សា នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

20 នស/រកត/០៩៩៦/៧២, ទំ.១។

ក្នុងពេលបច្ចុប្បន្ននេះ ពាក់ព័ន្ធនឹងការបន្ធូរបន្ថយ ឬលើកលែងទោស ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨ នៅតែជាឯកសារជាធរមាន និងចម្បងសម្រាប់ជាមូលដ្ឋានផ្លូវច្បាប់នៃការលើកលែងទោស ឬបន្ធូរបន្ថយទោស។ អនុលោមតាមមាត្រា ១,២ និង ៣ នៃក្រឹត្យនេះ ទណ្ឌិតត្រូវមានកិរិយាមារយាទល្អ ទទួលរងទោសចំនួន ២ ភាគ ៣ នៃទោសដាក់ពន្ធនាគារមានកំណត់ ឬទទួលទោសបាន ១៥ឆ្នាំ ចំពោះទោសដាក់ពន្ធនាគារមួយជីវិត ទើបអាចសុំលើកលែងទោស។ ចំណែកការបន្ធូរបន្ថយទោស ក្រៅពីមានកិរិយាមារយាទល្អ ទណ្ឌិតត្រូវទទួលទោសបាន ១ភាគ៣ នៃទោសដាក់ពន្ធនាគារមានកំណត់ ឬទទួលទោសបាន ១៥ឆ្នាំ ចំពោះទោសដាក់ពន្ធនាគារមួយជីវិត។ ទោសចន្លោះពី ១ ដល់ ១០ឆ្នាំ ទណ្ឌិតអាចទទួលបានការបន្ធូរ ៦ខែ ក្នុងពេលស្នើសុំម្តង ទោសចន្លោះពី ១០ឆ្នាំដល់ ១៥ឆ្នាំ បាន៩ខែ ហើយពី១៥ ដល់ ២០ឆ្នាំ ទទួលបានការបន្ធូរបន្ថយចំនួន១២ខែម្តង ក្នុងរយៈពេលមួយឆ្នាំ។ ទណ្ឌិតជាប់ទោសក្នុងពន្ធនាគារមួយជីវិតត្រូវទទួលបន្ថយទោសលើកទី១ ពីមួយជីវិតមក ២០ឆ្នាំ។ ខ្លឹមសារនៃក្រឹត្យលេខ ២៨ មិនបានចែងច្បាស់ថា តើទណ្ឌិតអាចទទួលការបន្ធូរបន្ថយទោសបានច្រើនដង ឬយ៉ាងណាទេ ក៏ប៉ុន្តែ ដោយប្រយោល មាត្រាពាក់ព័ន្ធអាចត្រូវបានបកស្រាយថា ទណ្ឌិតគាត់អាចទទួលបានការបន្ធូរបន្ថយច្រើនដងបាន។

គេគួរកត់សម្គាល់ថា តាមលិខិតរបស់ក្រសួងយុត្តិធម៌ លេខ២៨២៖ "*ទណ្ឌិតណាដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ដូចជាបទសម្លាប់មនុស្សដោយចេតនា សម្លាប់មនុស្សដោយចេតនាគិតទុកជាមុន រំលោភសេពសន្ថវៈរួចសម្លាប់ ប្លន់ប្រដាប់អាវុធ ឬប្រព្រឹត្តបទល្មើសបន្តបន្ទាប់មិនរាងចាល... ពិសេសគឺបទឧក្រិដ្ឋ គួរគប្បីពិនិត្យឲ្យបានច្បាស់លាស់ មិនគួរធ្វើសំណើសុំមកក្រសួងយុត្តិធម៌ សុំឲ្យដោះលែង ដោយគ្មានលក្ខខណ្ឌនោះឡើយ*"។ នេះមានន័យថា គេអាចបកស្រាយបានថា លិខិតនេះមិនហាមឃាត់មិនឲ្យបន្ធូរបន្ថយទោស ឬលើកលែងទោសទេ។ បន្ថែមពីលើនេះ លិខិតនេះប្រើពាក្យ "***មិនគួរ***"។

ក្រៅពីមាត្រា ៧៧ ដែលចែងច្បាស់ពីស្ថាប័នដែលនឹងធ្វើសំណើលើកលែងទោស (រាជរដ្ឋាភិបាល) ជូនព្រះមហាក្សត្រ មាត្រាដទៃទៀត ពាក់ព័ន្ធនឹងការលើកលែង ឬបន្ធូរបន្ថយទោសមិនចែងហាមទណ្ឌិតធ្វើសំណើដាក់មកប្រធានពន្ធនាគារ ដើម្បីពិចារណាសំណើ និងបញ្ជូនបន្តទៅគណៈកម្មាធិការដើម្បីសម្រេចដាក់ជូនរាជរដ្ឋាភិបាលទេ។[21] មាត្រាពាក់ព័ន្ធមិនបានចែងកំណត់ប្រភេទរបស់ទណ្ឌិត ឬប្រភេទបទឧក្រិដ្ឋ ដែលស្ថិតក្នុងបញ្ជីមិនអនុញ្ញាតឲ្យលើកលែង ឬបន្ធូរបន្ថយទោសទេ។ ដូចនេះ គេអាចបកស្រាយថា គ្រប់ទណ្ឌិតទាំងអស់មានសិទ្ធិធ្វើសំណើសុំលើកលែង ឬបន្ធូរបន្ថយទោសបាន។ ក៏ប៉ុន្តែ ការសម្រេចព្រម ឬមិនព្រម ជាសមត្ថកិច្ចរបស់

[21] ច្បាប់ស្តីពី ពន្ធនាគារ, មាត្រា ៧៤។

អាជ្ញាធរមានសមត្ថកិច្ច ដោយមានមូលដ្ឋានសមស្រប និងមិនរំលោភច្បាប់ដែលពាក់ព័ន្ធ។ មាត្រា ៧៦ នៃច្បាប់ស្តីពី ពន្ធនាគារ ចែងថា "*...ទណ្ឌិតដែលយល់ឃើញថា ខ្លួនបានបំពេញលក្ខខណ្ឌក្នុងការស្នើសុំបន្ធូរបន្ថយទោស ឬលើកលែង ប៉ុន្តែមិនត្រូវបានប្រធានពន្ធនាគារស្នើសុំឲ្យខ្លួនសាមី នោះខ្លួនមានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មការថ្នាក់ជាតិ... ដោយមានការគាំទ្រពីក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគារ*" បង្ហាញថា ទណ្ឌិតមានសិទ្ធិក្នុងការដាក់សំណើផ្ទាល់។

## ២.៤. ឌុច មានសិទ្ធិទទួលការលើកលែងទោស ឬបន្ធូរបន្ថយទោស

ជាបឋម មុននឹងឆ្លើយសំណួរសំខាន់នៃអត្ថបទនេះ យើងគួរពិនិត្យមើលខ្លឹមសារជាក់ស្តែងរបស់មាត្រា ៤០ថ្មី និងមាត្រា ១១ នៃកិច្ចព្រមព្រៀង ស្តីពី អ.វ.ត.ក ជាមុនសិន។ មាត្រាទាំងពីរនេះ ចែងពាក្យពេចន៍ស្ទើរដូចគ្នាទាំងស្រុង លើកលែងតែមាត្រា ៤០ថ្មី និយាយយោងដល់មាត្រានៃបទឧក្រិដ្ឋ (មាត្រា ៣ និយាយបទឧក្រិដ្ឋចែងក្រោមច្បាប់ជាតិ) ចំណែកឯមាត្រា ១១ នៃកិច្ចព្រមព្រៀង ស្តីពី អ.វ.ត.ក ប្រើតែពាក្យ "**បទឧក្រិដ្ឋដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ**"។ មាត្រាទាំងពីរបានប្រើប្រាស់ពាក្យ "***ជនទាំងឡាយណាដែលអាចត្រូវបានស៊ើបអង្កេត ឬផ្តន្ទាទោសអំពីឧក្រិដ្ឋកម្ម***"។ "*ជនទាំងឡាយណា*" អាចត្រូវបានគេបកស្រាយរាប់បញ្ចូលនូវទណ្ឌិតដែលជាពិរុទ្ធជនកំពុងអនុវត្តទោសក្នុងពន្ធនាគារ។ ទោះបីជាយ៉ាងនេះក្តី វាជាការមិនត្រឹមត្រូវទេ ប្រសិនបើយោងលើអត្ថន័យយ៉ាងជាក់លាក់នៃពាក្យ "***ស៊ើបអង្កេត***" និងពាក្យ "***ផ្តន្ទាទោស***" ដែលពាក្យខាងក្រោយនេះ *សំដៅទៅលើពាក្យដាក់ទោស ប៉ុន្តែមិនក្តោបដល់ការអនុវត្តទោសទេ*។ ការបកស្រាយនេះ បន្ថែមន័យដោយការមិនប្រើប្រាស់ពាក្យ "***បន្ធូរបន្ថយទោស***" នៅក្នុងមាត្រាទាំងពីរ និងការចែងយោងដល់ការលើកលែងទោស ឬអនុគ្រោះទោសមុនបង្កើត អ.វ.ត.ក (មិននិយាយដល់ការបន្ធូរបន្ថយទោស) ដែលសំដៅដល់ករណីលោក ***អៀង សារី***។

តាមអត្ថន័យនៃមាត្រាទាំងពីរ ដែលមើលឃើញនឹងភ្នែក ច្បាប់នេះក៏នឹងមិនចែងហាមសភាធ្វើច្បាប់លើកលែងទោស ដល់ជនណាមួយដែលកំពុងត្រូវបានស៊ើបអង្កេត ឬផ្តន្ទាទោសដោយ អ.វ.ត.ក ទេ លើកលែងតែការបកស្រាយមាត្រានេះទូលាយ បង្កើតជាកាតព្វកិច្ចចងដល់សភា។ ស្រដៀងគ្នានេះដែរ មាត្រាទាំងពីរមិនបានហាមទណ្ឌិតស្នើសុំការលើកលែងទោស ឬអនុគ្រោះទោសទេ។ នេះគេមិននិយាយដល់ការបន្ធូរបន្ថយទោសផង។ ជាសរុប មាត្រាទាំងពីរចែងកាតព្វកិច្ចដល់រាជរដ្ឋាភិបាលតែប៉ុណ្ណោះ។

គោលបំណងនៃការចែងនេះ គឺដើម្បីបង្ការកុំឲ្យរាជរដ្ឋាភិបាលជាភាគីម្ខាង នៃកិច្ចព្រម-ព្រៀងធ្វើការស្នើលើកលែងទោស ឬអនុគ្រោះទោស ដោយសារហេតុផលណាមួយនោះ ហើយ

ជាលទ្ធផល អ.វ.ត.ក មិនអាចធ្វើការចោទប្រកាន់ជាបន្តលើជននោះបាន ដែលនេះវាផ្ទុយពីគោលបំណងនៃការបង្កើត អ.វ.ត.ក។

ការលើកលែងទោស ឬអនុគ្រោះទោសដល់ឧក្រិដ្ឋជន ប្រព្រឹត្តឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ ដោយប្រទេសមួយមិនអាចជាឧបសគ្គរាំងការចោទប្រកាន់ ឬផ្តន្ទាទោស ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានបដិសេធជាទូទៅ ដោយយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់ប្រទេសមួយចំនួន។[22] ដូចនេះ ការចែងក្នុងមាត្រា ៤០ថ្មី និងមាត្រា ១១ ហាក់មិនមានភាពចាំបាច់។

ប្រសិនបើវត្តមាននៃមាត្រាទាំងពីរនេះចាំបាច់ ការចែងបង្ការនេះវាស៊ីគ្នាដោយប្រយោលទៅនឹងកាតព្វកិច្ចទូទៅរបស់កម្ពុជា ក្នុងការសហការជាមួយអង្គការសហប្រជាជាតិដើម្បីឲ្យដំណើរការនៃ អ.វ.ត.ក ប្រព្រឹត្តទៅទទួលបានលទ្ធផលដូចគោលបំណង។[23] គេអាចអះអាងបានថាការសន្យារបស់រាជរដ្ឋាភិបាលនេះមិនខុសច្បាប់ទេ ហើយដើម្បីសម្របសម្រួលក្នុងលក្ខណៈនយោបាយរបស់កម្ពុជាចំពោះអង្គការសហប្រជាជាតិ។ ខ្លឹមសារនៃកិច្ចពិភាក្សាអនុម័តច្បាប់ ស្តីពី អ.វ.ត.ក ដោយរដ្ឋសភាបានលើកបញ្ហានេះមកពិភាក្សា។ តំណាងរាជរដ្ឋាភិបាលបានអះអាងថាសំណើនៃមាត្រានេះ ត្រូវបានធ្វើឡើង ដោយអង្គការសហប្រជាជាតិ ហើយភាគីកម្ពុជាបានឆ្លើយតបថា វាអាចខុសនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ទោះបីជាយ៉ាងនេះក្តី ខ្លឹមសារត្រូវបានកែសម្រួលមកត្រឹមតែជាការបង្ហាញការសន្យារបស់រាជរដ្ឋាភិបាល មិនស្នើសុំលើកលែងទោស ឬអនុគ្រោះទោស។ ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ៤០/០០២/២០០១ កបធ-ច ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ បានអះអាងយ៉ាងច្បាស់ថា មាត្រា ៤០ថ្មី មិនខុសពីមាត្រា ២៧ នៃច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ទេ៖ *"...មាត្រា ២៧ នៃរដ្ឋធម្មនុញ្ញបានបញ្ញត្តិពីព្រះមហាក្សត្រ មិនមែនពីរាជរដ្ឋាភិបាលឡើយ"*។[24]

ការបកស្រាយ មាត្រា ៤០ថ្មី និង មាត្រា ១១ ចងកាតព្វកិច្ចដល់រដ្ឋាភិបាល ហើយដកសិទ្ធិទណ្ឌិតក្នុងការស្នើសុំលើកលែងទោស បន្ធូរបន្ថយទោស ក្រោយពីអនុវត្តទោស និងបំពេញ

[22] លក្ខន្តិកៈទីក្រុងរ៉ូម មិនបានចែងនូវរបាណាមួយដល់ការកាត់សេចក្តី ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ផ្អែកលើមូលដ្ឋាននៃអភ័យឯកសិទ្ធិទេ លើកលែងមាត្រា ៩៨ នៃលក្ខន្តិកៈ។ មាត្រា ១២០ មិនបានអនុញ្ញាតឲ្យមានខរក្សាសិទ្ធិមិនអនុវត្តទេ។ អង្គជំនុំជម្រះ, សេចក្តីសម្រេច លើអញ្ញត្រកម្មបឋម តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) E51/15, ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១, កថាខណ្ឌ ៥១។ សូមមើលជាទូទៅ, Faustin Z. Ntoubandi, ការលើកលែងទោសសម្រាប់បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ក្រោមច្បាប់អន្តរជាតិ, ឆ្នាំ២០០៧។

[23] ច្បាប់ស្តីពី ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឆ្នាំ២០០៤, មាត្រា ១១។

[24] ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, http://www.ccc.gov.kh/ccc_decision_en.php

គ្រប់លក្ខខណ្ឌក្នុងការទទួលបានការលើកលែង ឬបន្ធូរបន្ថយទោស នឹងមិនស្របទៅតាមទ្រឹស្តីនៃសិទ្ធិពីធម្មជាតិ (Natural Rights) ដែលបុគ្គលមានសិទ្ធិដោយសារខ្លួនជាមនុស្ស (Inherent Rights)។ អាជ្ញាធរមិនមែនជាម្ចាស់សិទ្ធិ និងជាអ្នកផ្តល់សិទ្ធិដល់បុគ្គលទេ។[25] រដ្ឋគ្រាន់តែយកសិទ្ធិដែលមានស្រាប់មកចែងក្នុងច្បាប់ និងធានាអនុវត្តសិទ្ធិរបស់ប្រជាពលរដ្ឋ ធ្វើកុំឲ្យអនុវត្តសិទ្ធិខ្លួនដោយបំពាន បង្កអសន្តិសុខដល់សង្គម។[26] ការបកស្រាយយ៉ាងនេះ អាចឈានទៅរកការកម្រិតសិទ្ធិដែលមិនមានមូលដ្ឋានសមស្របនៃការកម្រិតសិទ្ធិ ដែលមានបញ្ញត្តិក្នុងកតិកា-សញ្ញាស្តីពី សិទ្ធិមនុស្ស។[27] បន្ថែមពីលើនេះ ការបកស្រាយទូលាយ ឬហួសពីបំណងនៃមាត្រា ៤០ថ្មី និងមាត្រា ១១ អាចមិនសមស្រប ប្រសិនបើគេអះអាងថា ហាមតែការលើកលែងទោស អនុគ្រោះទោស ឬបន្ធូរបន្ថយទោស បទឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ ពីព្រោះមាត្រាទាំងពីរចែងលាតសន្ធឹងក្តោបចូលបទឧក្រិដ្ឋកម្ម ក្រោមច្បាប់ព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ផងដែរ។

មាត្រា ៣១ នៃច្បាប់រដ្ឋធម្មនុញ្ញ បានចែងបញ្ចូលនូវសន្ធិសញ្ញាសិទ្ធិមនុស្សដែលកម្ពុជាបានទទួលស្គាល់ រាប់បញ្ចូលនូវកតិកាសញ្ញាស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ ដែលមានមាត្រា ៤ និងមាត្រា ៦ បានចែងអំពីការលើកលែងទោស ឬបន្ធូរបន្ថយទោស ដូចដែលបានជម្រាបខាង-លើ។ នេះមានន័យថា កម្ពុជាជាភាគីមានកាតព្វកិច្ចគោរពសិទ្ធិ និងកាតព្វកិច្ចដែលមានចែងក្នុងកតិកាសញ្ញានេះ។ មាត្រា ៣១ ដដែលបានចែងធានាមិនឲ្យមានការរើសអើង ការប្រាស្រ័យសិទ្ធិរបស់ពលរដ្ឋកម្ពុជា។

ដោយមិនគិតពីប្រភេទនៃសន្ធិសញ្ញាចែងក្នុងមាត្រា ៣១ ឬថាតើកម្ពុជាអនុវត្តសន្ធិសញ្ញាដោយផ្ទាល់ (Direct Application)[28] ដោយមិនចាំបាច់មានច្បាប់ដើម្បីផ្តល់តម្លៃសន្ធិសញ្ញាជាច្បាប់ជាតិជាមុនសិន (Transformation Act)[29] មុននឹងអនុវត្ត កាលបើនិយាយអំពីឋានានុក្រមរបស់សន្ធិសញ្ញាអន្តរជាតិ ឬកិច្ចព្រមព្រៀង ក្នុងប្រព័ន្ធច្បាប់កម្ពុជា តាមទស្សនៈជាក់ស្តែងនិយមកម្ពុជា ក៏ដូចជាបណ្តាប្រទេសដទៃទៀត ជាទូទៅជាក់រដ្ឋធម្មនុញ្ញខ្ពស់ជាងសន្ធិសញ្ញា ឬកិច្ច-ព្រមព្រៀង។

---

[25] តាមទ្រឹស្តីសិទ្ធិមានមកជាមួយនាពេលមនុស្សកើត (Natural and In-alienable Rights) មិនមែនរដ្ឋជាម្ចាស់សិទ្ធិ និងអ្នកផ្តល់សិទ្ធិឲ្យបុគ្គលទេ, http://dailysignal.com/2011/12/19/are-human-rights-the-same-as-natural-rights/

[26] Hersch Lauterpacht, កម្រងសិទ្ធិរបស់មនុស្ស, ឆ្នាំ២០១៣, ទំព័រ ១៧ និង ៨៣។ សេចក្តីប្រកាសស្តីពី សិទ្ធិមនុស្ស និងប្រជាពលរដ្ឋ (បារាំង), កថាខណ្ឌ ២ ។

[27] មាត្រា ១២ នៃកតិកាសញ្ញា, លេខយោងទី ១០។

[28] មាស ប៊ូរ៉ា, នីតិអន្តរជាតិសាធារណៈ, ឆ្នាំ២០១៥, ទំព័រ ១០៦។

[29] ដូចលេខយោង ទី ២៣។

ច្បាប់ជាតិ រួមទាំងច្បាប់រដ្ឋធម្មនុញ្ញ បានចែងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការលើកលែង ឬបន្ធូរបន្ថយទោស ហើយមិនមានហាមជនណាមួយទទួលផលប្រយោជន៍នៃច្បាប់ទាំងនេះទេ ឲ្យតែពួកគេបានបំពេញលក្ខខណ្ឌអាចស្នើសុំបន្ធូរបន្ថយ ឬលើកលែងទោសបាន។ ដូចនេះ ច្បាប់ អ.វ.ត.ក ឬកិច្ចព្រមព្រៀងមិនត្រូវផ្ទុយរដ្ឋធម្មនុញ្ញទេ។

អង្គការសហប្រជាជាតិបានអនុម័ត កិច្ចព្រមព្រៀងមិនផ្តល់រយៈពេលអាជ្ញាយុកាលនៃការចោទប្រកាន់ និងទោស សម្រាប់បទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិដូចជា បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។[30] មាត្រា ១៤៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា ចែងមិនឲ្យមានអាជ្ញាយុកាលនៃការអនុវត្តទោស[31] ដើម្បីកុំឲ្យបុគ្គលប្រព្រឹត្តទទួលបាននិទណ្ឌភាព។ ទោះបីជាយ៉ាងនេះក្តី នេះមិនមានន័យថា ទាំងបទប្បញ្ញត្តិនៃសន្ធិសញ្ញា ឬមាត្រាច្បាប់ដែលពាក់ព័ន្ធ តម្រូវមិនលើកលែងទោស ឬបន្ធូរបន្ថយទោសដល់ទណ្ឌិតដែលបានប្រព្រឹត្តបទឧក្រិដ្ឋប្រភេទនេះ ហើយដែលបានអនុវត្តទោសក្នុងពន្ធនាគារទេ។

បុគ្គលប្រកាន់ទស្សនៈពិតនិយម ដែលផ្តោតទៅលើការប្រព្រឹត្តឃោរឃៅ ឬចំនួននៃជនរងគ្រោះនៃអំពើរបស់ **ឌុច** អាចគិតថា ទណ្ឌិត **ឌុច** សមទទួលទោសមួយជីវិតដូចនេះ និងមិនត្រូវមានថ្ងៃចេញពីគុក តាមរយៈការលើកលែងទោស ឬការបន្ធូរបន្ថយទោសទេ។ នេះដើម្បីធ្វើឲ្យ **ឌុច** ឬឧក្រិដ្ឋជនដទៃទៀតមានការរាងចាល លែងប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរយ៉ាងនេះទៀត។ ការគិតលើតែកត្តានេះជាចម្បង ហើយស្នើឲ្យមានវិធានការរបៀបនេះមិនសមស្របទាំងស្រុង ១០០ ភាគរយទេ ពីព្រោះការដាក់ទោសមួយជីវិត ឬទោសប្រហារជីវិតក៏មិនប្រាកដថា ឧក្រិដ្ឋជនមានការរាងចាលឡើយ។ វិធានការជាច្រើន អាចនឹងត្រូវបានតម្រូវដើម្បីសម្រេចគោលដៅនេះ។ សហគមន៍អន្តរជាតិមានក្តីបារម្ភដូចគ្នា ក៏ប៉ុន្តែវិធានការឆ្លើយតប ក៏មិនត្រូវខ្វះហេតុផលដែរ។ ជាក់ស្តែង ក្នុងករណីលោក **ឌុច** ដដែល សូម្បីគាត់ជាឧក្រិដ្ឋជនក្តី ក៏សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ត្រូវតែបានធានាចំពោះគាត់។[32]

**ឌុច** មិនមែនជាបុគ្គលម្នាក់ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលបានប្រព្រឹត្តបទឧក្រិដ្ឋទេ។ គាត់បានសារភាពទទួលកំហុស[33] និងសហការជួយការងារស៊ើបអង្កេត ឬចោទប្រកាន់របស់ អ.វ.ត.ក យ៉ាងសកម្ម។ គាត់មានវិប្បដិសារី[34] គាត់ទទួលរងការឈឺចាប់ផ្លូវចិត្តជាខ្លាំង និងការ

---

[30] អនុសញ្ញាស្តីពី ការមិនអនុវត្តនូវអាជ្ញាយុកាលចំពោះ បទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, Res. 2391(XXIII), ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៦៨។

[31] ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩។

[32] វិធានផ្ទៃក្នុងនៃ អ.វ.ត.ក, វិធានទី ២១។

[33] សាលក្រម, លេខយោងទី ១, កថាខណ្ឌទី ៦២៩។

[34] ដូចលេខយោងខាងលើ, កថាខណ្ឌទី ៦០៦។

រើសអើងក្នុងជីវិត។ បន្ថែមពីលើនេះ គាត់ក៏មានវ័យកាន់តែចំណាស់ហើយ។ ទោះបីនេះមិនមែនជាមូលដ្ឋានចម្បងចែងក្នុងច្បាប់ពាក់ព័ន្ធសម្រាប់ពិចារណានូវការបន្ធូរបន្ថយទោស ឬលើកលែងទោសយ៉ាងនេះក្តី អាជ្ញាធរមានសមត្ថកិច្ចក្នុងការពិចារណាមិនគួរមើលរំលងកត្តាទាំងនេះទេ។ បន្ថែមពីលើនេះ ការបន្ធូរបន្ថយទោស **ឌុច** ឬលើកលែងទោសមិនអាចនាំដល់ប៉ះពាល់សុវត្ថិភាពគាត់ ឬសណ្តាប់ធ្នាប់សង្គមដែរ ដោយពិចារណានៅលើភាពស្ងប់ចិត្តរបស់ជនរងគ្រោះ ក្រោយពី អ.វ.ត.ក បានកាត់ទោសដាក់គុកមួយជីវិតលើគាត់។ ការប្រៀបធៀបរវាង **ឌុច** និងឧក្រិដ្ឋជនដទៃនាំឲ្យប្រព្រឹត្តខុសគ្នាដែលគ្មានមូលដ្ឋាន ឬហេតុផលសមស្របនឹងនាំឲ្យមានអំពើរើសអើង។ បន្ថែមពីលើនេះ ទស្សនៈផ្ទុយនឹងគោលការណ៍ ស្តានីតិសម្បទាសម្រាប់ឲ្យឧក្រិដ្ឋជនដែលបានជាប់ទោស អនុវត្តទោស បានកែប្រែល្អ មានឱកាសត្រឡប់ មកចូលរួមរស់ក្នុងសង្គម។

## ៣. សង្ខេប

ក្រោយពីបានពិនិត្យ មើលបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង កតិកាសញ្ញា ច្បាប់ជាតិ ការសិក្សានេះបានរកឃើញថា មិនមានបទប្បញ្ញត្តិណាចែងដោយផ្ទាល់ ឬដោយប្រយោល ដកហូតសិទ្ធិរបស់ **ឌុច** ក្នុងការស្នើសុំលើកលែងទោស ឬបន្ធូរបន្ថយទោសទេ។ មាត្រា ៤០ថ្មី និងមាត្រា ១១ នៃកិច្ចព្រមព្រៀង ស្តីពី អ.វ.ត.ក ដែលចែងហាមរាជរដ្ឋាភិបាលស្នើមិនមានបំបាត់សិទ្ធិសេរីភាពរបស់ទណ្ឌិត **ឌុច** ឡើយ។ មាត្រានៃកិច្ចព្រមព្រៀង និង អ.វ.ត.ក មិនខុសច្បាប់រដ្ឋធម្មនុញ្ញទេ ដោយសារមិនបានចែងក្តោបដល់ការលើកលែងទោស ឬបន្ធូរបន្ថយទោស ក្នុង-អំឡុងពេលអនុវត្តទោស។

## ៤. សេចក្តីដកស្រង់ច្បាប់

### ៤.១. ច្បាប់ស្តីពី ពន្ធនាគារ

<u>**មាត្រា ៧៤**</u>៖ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបង្កើតគណៈកម្មការមួយដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត ក្នុងរយៈពេលជាប់ឃុំនៅក្នុងពន្ធនាគារ...។ គណៈកម្មការនេះត្រូវធ្វើបញ្ជីទណ្ឌិតដែលមានលក្ខណសម្បត្តិ អាចស្នើសុំបន្ធូរបន្ថយទោស និងលើក-លែងទោស...។...ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**<u>មាត្រា ៧៥</u>**៖ រាជរដ្ឋាភិបាលត្រូវបង្កើតគណៈកម្មការជាតិមួយ...។ ក្រោយពីបានពិនិត្យវាយតម្លៃរួចហើយ គណៈកម្មការនេះត្រូវធ្វើបែបបទជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ដើម្បីដាក់សំណើថ្វាយព្រះមហាក្សត្រ សុំបន្ធូរបន្ថយទោស និងលើកលែងទោសឲ្យទណ្ឌិត...។
**<u>មាត្រា ៧៦</u>**៖ ...ទណ្ឌិតដែលយល់ឃើញថា ខ្លួនបានបំពេញលក្ខខណ្ឌក្នុងការស្នើសុំបន្ធូរបន្ថយទោស ឬលើកលែង ប៉ុន្តែមិនត្រូវបានប្រធានពន្ធនាគារ ស្នើសុំឲ្យខ្លួនសាមី ខ្លួនមានសិទ្ធិប្ដឹងតវ៉ាទៅគណៈកម្មការថ្នាក់ជាតិ ...ដោយមានការគាំទ្រពីក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគារ។
**<u>មាត្រា ៧៧</u>**៖ ក្នុងករណីចាំបាច់ ប្រមុខរាជរដ្ឋាភិបាល មានបុព្វសិទ្ធិធ្វើសំណើថ្វាយព្រះមហាក្សត្រសុំលើកលែងទោសឲ្យទណ្ឌិតនៅពេលណាក៏បាន។
**<u>មាត្រា ៧៨</u>**៖ ពិធីបុណ្យ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។
**<u>មាត្រា ៧៩</u>**៖ គ្រប់ទណ្ឌិត ដែលត្រូវទទួលទោសពន្ធនាគារមួយ ឬច្រើន អាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនោះបានបង្ហាញឲ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទា ដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន។ លក្ខខណ្ឌ និងបែបបទនៃការអនុវត្តការដោះលែង ដោយមានលក្ខខណ្ឌក្នុងច្បាប់នេះ ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

## ៤.២.ច្បាប់រដ្ឋធម្មនុញ្ញ

**<u>មាត្រា ៨</u>**៖...ព្រះមហាក្សត្រ...ទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ។
**<u>មាត្រា ២៧</u>**៖ ព្រះមហាក្សត្រមានព្រះរាជសិទ្ធិ បន្ធូរបន្ថយទោស ឬលើកលែងទោស។
**<u>មាត្រា ៣១</u>**៖ ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ ប្រជាពលរដ្ឋខ្មែរមានភាពស្មើភាពគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ការប្រើប្រាស់សិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗមិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ដោយច្បាប់។
**<u>មាត្រា ៩០ថ្មី</u>**៖ រដ្ឋសភាអនុម័តច្បាប់ស្តីពី ការលើកលែងទោសជាទូទៅ។

### ៤.៣. ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ (ឆ្នាំ ១៩៩៤)

**មាត្រា ៥**៖ ច្បាប់នេះផ្តល់រយៈពេល ៦ខែ ចាប់តាំងពីថ្ងៃចូលជាធរមានដល់បុគ្គលដែលជាសមាជិករបស់អង្គការនយោបាយនៃកងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យ ឲ្យចុះចូលមកក្រោមរាជរដ្ឋាភិបាលកម្ពុជា ដោយមិនមានទោសទណ្ឌ សម្រាប់បទឧក្រិដ្ឋដែលពួកគេបានប្រព្រឹត្ត។

**មាត្រា ៦**៖ សម្រាប់មេដឹកនាំក្រុមកម្ពុជាប្រជាធិបតេយ្យ រយៈពេលកំណត់ខាងលើមិនអនុវត្តឡើយ។

**មាត្រា ៧**៖ ព្រះមហាក្សត្រមានសិទ្ធិផ្តល់នូវ ការលើកលែងទោស ឬការឲ្យរួចទោសដូចដែលមានចែងនៅក្នុងមាត្រា ២៧ នៃច្បាប់រដ្ឋធម្មនុញ្ញ។

### ៤.៤. ព្រះរាជក្រឹត្យ លើកលែងទោស លោក អៀង សារី (ឆ្នាំ ១៩៩៦)

**មាត្រា ១**៖ ឲ្យរួចទោស (Pardon) ដល់លោក **អៀង សារី** អតីតនាយករដ្ឋមន្ត្រីទទួលបន្ទុកការបរទេស ក្នុងរដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ ចំពោះការកាត់ទោសប្រហារជីវិត និងការរឹបអូសទ្រព្យសម្បត្តិទាំងអស់របស់គាត់ ធ្វើឡើងតាមបញ្ជារបស់តុលាការប្រជាជនបដិវត្តន៍កម្ពុជាទីក្រុងភ្នំពេញ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៩ និងការលើកលែងទោស (Amnesty) ចំពោះការកាត់ទោសក្រោមច្បាប់ស្តីពី ការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យនៅក្រៅច្បាប់ ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ១ ឆ្នាំ១៩៩៤ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤។

### ៤.៥. កតិកាសញ្ញាស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ ឆ្នាំ ១៩៧៧

**មាត្រា ៦(៤)**៖ ជនដែលទទួលទោសប្រហារជីវិត មានសិទ្ធិសុំអភ័យទោស ឬបន្ធូរបន្ថយ ទោស។ ការលើកលែងទោស ការអភ័យទោស ឬការបន្ធូរបន្ថយទោសប្រហារជីវិត អាចផ្តល់ឲ្យបានគ្រប់ករណីទាំងអស់។

**មាត្រា ១៤(៦)**៖ នៅពេលជនណាម្នាក់ ត្រូវបានប្រកាសឲ្យជាប់ពិរុទ្ធបទព្រហ្មទណ្ឌជាស្ថាពរ ហើយក្រោយមកការប្រកាសឲ្យជាប់ពិរុទ្ធនេះ ត្រូវបានបដិសេធ ឬត្រូវបានលើកលែងទោស ដោយហេតុថា អង្គហេតុថ្មី ឬដែលបានរកឃើញថ្មីបញ្ជាក់យ៉ាងច្បាស់ថា មានការខុសឆ្គងពីសំណាក់តុលាការ ជនដែលទទួលរងគ្រោះ ដោយសារការដាក់ទោសនេះ ត្រូវទទួលសំណងស្របតាមច្បាប់ លើកលែងតែមានការកំណត់បង្ហាញថា ការមិនលាតត្រដាងអាថ៌កំបាំងនៃការពិតទាន់ពេល បណ្តាលមកពីជននោះទាំងស្រុង ឬមួយផ្នែក។

## ៤.៦. ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

<u>**មាត្រា ៧**</u>៖ មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅគឺ៖...៣-ការលើកលែងទោសជាទូទៅ។ ...កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិន-អាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់។...

<u>**មាត្រា ៥៤២**</u>៖ បញ្ជីថ្កោលទោស ត្រូវបានកាន់កាប់ដោយអង្គភាពមួយនៃក្រសួងយុត្តិធម៌។... វិធានការលើកលែងទោស និងបន្ធូរបន្ថយទោស ដែលប្រទានដោយព្រះមហាក្សត្រនៃព្រះរាជា-ណាចក្រកម្ពុជា...។...ត្រូវដកចេញពីបញ្ជីថ្កោលទោសៈ...ការផ្តន្ទាទោសដែលត្រូវបានលុបលាងដោយការលើកលែងទោសជាទូទៅ...។

<u>**មាត្រា ៥៥៥**</u>៖ ការអនុគ្រោះទោស (Pardon) ឬការលើកលែងទោស (Amnesty) មិនមែនជាឧបសគ្គដល់ការប្តឹងសើរើទេ។

<u>**មាត្រា ៥៤៣**</u>៖ អង្គភាពថ្កោលទោសរ៉ាប់រងទទួលព័ត៌មាន អំពីវិធានការលើកលែងទោស និងបន្ធូរបន្ថយទោស ដែលប្រទានដោយព្រះមហាក្សត្រ និងសេចក្តីសម្រេចបណ្តេញជនបរទេស។

## ៤.៧. ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

<u>**មាត្រា ១៣៩**</u>៖ កាលបើទោសជាកម្មវត្ថុនៃវិធានការលើកលែងទោស និងបន្ធូរបន្ថយទោស ដូចមានចែងក្នុងមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែគិតគូរអំពីទោស ដែលជាលទ្ធផលនៃការលើកលែងទោស និងបន្ធូរបន្ថយទោស ដើម្បីអនុវត្តវិធានស្តីពីការស្រូបបញ្ចូលគ្នានៃទោស។ ...

<u>**មាត្រា ១៤៣**</u>៖ ...ទោសដែលប្រកាសពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាមមិនអាចផុតរលត់អាជ្ញាយុកាលទេ។

<u>**មាត្រា ១៤៩**</u>៖ ការលើកលែងទោសជាទូទៅ ដូចមានចែងក្នុងមាត្រា ៩០ថ្មី(ពីរ) វាក្យខណ្ឌទី៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លុបបំបាត់ចោលនូវទណ្ឌកម្មដែលពាក់ព័ន្ធនឹងច្បាប់ស្តីពី ការលើកលែងទោសជាទូទៅ។

<u>**មាត្រា ១៥០**</u>៖ កាលបើការព្យួរទោសពីមុន ត្រូវបានដកហូតដោយអានុភាពនៃការផ្តន្ទាទោសខាងក្រោយ ការលើកលែងទោសជាទូទៅ ចំពោះទោសខាងក្រោយនេះ បង្កើតឡើងវិញនូវផលប្រយោជន៍នៃការព្យួរទោសដែលមានពីមុន។

### ៤.៨. ក្រឹត្យ ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា (ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៨៩)

**មាត្រា១**៖ ត្រូវបានអនុគ្រោះ បន្ថយទោស ឬលើកលែងទោសចំពោះបណ្ដាពិរុទ្ធជនដែលបានជាប់ពន្ធនាគារ ហើយបានកែប្រែល្អតាមបណ្ដាលក្ខខណ្ឌដូចខាងក្រោមនេះ៖ ១. លក្ខខណ្ឌសម្រាប់ពិនិត្យ អនុគ្រោះ បន្ថយទោស ឬលើកលែងទោស៖ ...បានគោរពប្រតិបត្តិតាមយ៉ាងហ្មត់ចត់នូវបណ្ដារបបបទបញ្ជាផ្ទៃក្នុងរបស់មន្ទីរឃុំឃាំង។ ...ក្រោយពីបានជាប់ឃុំឃាំងក្នុងពន្ធនាគារអស់រយៈពេលយ៉ាងតិចមួយភាគប្រាំនៃកម្រិតទោស។ ទោសអស់មួយជីវិត គឺត្រូវជាប់ឃុំឃាំងក្នុងពន្ធនាគារបានប្រាំឆ្នាំយ៉ាងតិច។ ..

.

### ៤.៩. លិខិតលេខ២៨២ របស់ក្រសួងយុត្តិធម៌ ឆ្នាំ១៩៩៤

...២. អាចសុំលើកលែងទោសបានតែចំពោះទណ្ឌិតដែលត្រូវតុលាការផ្ដន្ទាទោសមិនធ្ងន់ធ្ងរ ហើយកែប្រែខ្លួនបានល្អនៅក្នុងពន្ធនាគារ។ ចំណែកទណ្ឌិតដែលត្រូវតុលាការផ្ដន្ទាទោសធ្ងន់ធ្ងរ គប្បីស្នើសុំមកត្រឹមតែការបន្ថយទោសឲ្យបានហើយ។ ...ស្នើសុំដោះលែងដោយមានលក្ខខណ្ឌ ចំពោះទណ្ឌិតណាដែលបានប្រព្រឹត្តបទល្មើសមិនធ្ងន់ធ្ងរ និងទទួលរងទោសក្នុងពន្ធនាគារបាន ២ភាគ៣ នៃទោសកំណត់ក្នុងសាលក្រម និងទណ្ឌិតណាដែលមានជម្ងឺធ្ងន់ធ្ងរមិនអាចទុកនៅពន្ធនាគារបាន។ ចំពោះទណ្ឌិតណាដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ដូចជាបទសម្លាប់មនុស្សដោយចេតនា សម្លាប់មនុស្សដោយចេតនាគិតទុកជាមុន រំលោភសេពសន្ថវៈរួចសម្លាប់ ប្លន់ប្រដាប់អាវុធ ឬប្រព្រឹត្តបទល្មើសបន្តបន្ទាប់មិនរាងចាល ...ពិសេសគឺបទឧក្រិដ្ឋ គួរគប្បីពិនិត្យឲ្យបានច្បាស់លាស់ មិនគួរធ្វើសំណើសុំមកក្រសួងយុត្តិធម៌ សុំយោបល់ពីការដោះលែងដោយមានលក្ខខណ្ឌនោះឡើយ។

# មូលហេតុនៃបណ្តឹងសាទុក្ខ ក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជា
# (ភាគ ១)

ដោយមេធាវី **សូ មូស្សេន្នី***

## ១. សេចក្តីផ្តើម

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ បណ្តឹងសាទុក្ខទៅតុលាការកំពូលមានសារសំខាន់ ដោយហេតុថា នេះគឺជាដំណាក់កាលចុងក្រោយ ហើយបិទផ្លូវតវ៉ា។[35] បើសិនជាតុលាការកំពូលច្រានចោលបណ្តឹងសាទុក្ខរបស់មេធាវី ហើយតម្កល់សាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ (ហៅកាត់ថា សាលាឧទ្ធរណ៍)ទុកជាបានការ នោះប្រហែលជាមេធាវីមិនអាចប្តឹងតវ៉ាទៅតុលាការណាទៀតឡើយ។[36] នៅក្នុងអត្ថបទនេះ អ្នកនិពន្ធផ្តោតទៅលើបណ្តឹងសាទុក្ខតាមមាត្រា ៤១៩ **"មូលហេតុនៃបណ្តឹងសាទុក្ខ"** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ២. មូលហេតុនៃបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខទៅតុលាការកំពូល បើកផ្លូវឲ្យភាគី[37]ប្តឹងសាទុក្ខប្រឆាំងនឹងសាលដីការបស់សាលាឧទ្ធរណ៍ ដើម្បីឲ្យតុលាការកំពូលបដិសេធសាលដីកានេះ។ ម្យ៉ាងវិញទៀត បណ្តឹងសាទុក្ខមានអានុភាពបង្អង់ការអនុវត្តសាលដីការបស់សាលាឧទ្ធរណ៍។[38] ដើម្បីឲ្យតុលាការកំពូលបដិសេធសាលដីកាសាលាឧទ្ធរណ៍ បណ្តឹងសាទុក្ខត្រូវសំអាងទៅលើចំណុចដែលមានរាយនាម

---

* លោក សូ មូស្សេន្នី បច្ចុប្បន្នគឺជាសហមេធាវីការពារក្តីជាតិក្នុងសំណុំរឿង០០៤ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយក៏ជាស្ថាបនិក និងជាមេធាវីនៅការិយាល័យមេធាវី អេសភីខ្មែរឡេហ្គាល ដែលមានអាសយដ្ឋានផ្ទះលេខ ១៥អា ផ្លូវលេខ៣២០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ។

[35] សូមមើលមាត្រា ៤៣៩ ចែងត្រង់ផ្នែកពាក់ព័ន្ធថា "... ប្រសិនបើបណ្តឹងសាទុក្ខត្រូវបានបដិសេធ នោះសេចក្តីសម្រេចដែលតវ៉ាមានអាជ្ញាអស់ជំនុំ។ អ្នកប្តឹងសាទុក្ខមិនត្រូវបានអនុញ្ញាតឲ្យប្តឹងសាទុក្ខជាថ្មីម្តងទៀត អំពីសាលដីកាដដែលនោះទេ"។

[36] លើកលែងករណីបណ្តឹងសើរើ ជាអាទិ៍ សូមមើលមាត្រា ៤៤៣ ដែលចែងត្រង់ផ្នែកពាក់ព័ន្ធថា "បណ្តឹងសើរើ គឺជាផ្លូវតវ៉ាមួយប្រឆាំងនឹងសាលក្រម និងសាលដីកាដែលស្ថាពរ ហើយដែលមានអាជ្ញាអស់ជំនុំ"។

[37] ចំពោះភាគីដែលអាចប្តឹងសាទុក្ខបាន សូមមើលមាត្រា ៤១៨ ចំណែកសេចក្តីសម្រេចដែលអាចធ្វើបណ្តឹងសាទុក្ខបាន សូមមើលមាត្រា ៤១៧ ចំពោះទម្រង់នៃការប្រកាសបណ្តឹងសាទុក្ខ សូមមើលមាត្រា ៤២២ ហើយរយៈពេលដើម្បីប្តឹងសាទុក្ខ សូមមើលមាត្រា ៤២០។

[38] ចំពោះអានុភាពផ្សេងទៀត សូមមើលមាត្រា ៤៣៥។

ក្នុងមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មាត្រានេះចែងថា៖

មាត្រា[39] ៤១៩៖ តុលាការកំពូលអាចបដិសេធសេចក្តីសម្រេចក្នុងករណីដូចតទៅ៖

- សមាសភាពមិនស្របច្បាប់នៃតុលាការ
- អសមត្ថកិច្ចនៃតុលាការ
- ការរំលោភអំណាច
- ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់
- ការបំពាន ឬភ្លេចទម្រង់ការ ដែលច្បាប់បញ្ញត្តិថាត្រូវទុកជាមោឃៈ
- ការមិនបានសម្រេចលើពាក្យសុំរបស់អយ្យការ ឬភាគីកាលណាពាក្យបណ្តឹងសុំនោះ ធ្វើជាលាយលក្ខណ៍អក្សរ និងមានន័យយ៉ាងច្បាស់លាស់
- ការបំភ្លៃអង្គហេតុ
- ការផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្តីសម្រេច។

## ២.១ សមាសភាពមិនស្របច្បាប់នៃតុលាការ

សមាសភាពមិនស្របច្បាប់នៃតុលាការ សំដៅទៅលើសមាសភាពនៃអង្គជំនុំជម្រះរបស់តុលាការជាន់ក្រោមដូចជា សាលាឧទ្ធរណ៍ សាលាដំបូង ជាអាទិ៍។ សមាសភាពមិនស្របច្បាប់នៃតុលាការមានជាអាទិ៍ដូចជា សាលាឧទ្ធរណ៍មានសមាសភាពចៅក្រមដដែលក្នុងករណីរឿងក្តីដែលបង្វិលពីតុលាការកំពូលដើម្បីជំនុំជម្រះសារជាថ្មីជាលើកទីពីរ ការមិនមានសមាសភាពបីរូបនៃចៅក្រមនៅសាលាដំបូងជំនុំជម្រះសេចក្តីក្នុងរឿងក្តីបទឧក្រិដ្ឋ និងសមាសភាពនៃតុលាការដែលមានវិសមិតភាពនៃមុខងារចោទប្រកាន់ ស៊ើបសួរ និងជំនុំជម្រះ។ កាលណាសាលាដំបូង ឬសាលាឧទ្ធរណ៍ ជំនុំជម្រះក្តីដោយមានសមាសភាពមិនស្របទៅតាមលក្ខខណ្ឌតម្រូវដោយច្បាប់[40] នោះជាមូលហេតុដែលនាំឲ្យតុលាការកំពូលបដិសេធសេចក្តីសម្រេចរបស់តុលាការទាំងនោះ។ គោលបំណងសំខាន់នៃចំណុចទីមួយនៃមាត្រា ៤១៩ នេះគឺថា ភាគីនៃរឿងក្តីត្រូវទទួលបានការ

---

[39] កំណត់សម្គាល់ កាលណាអ្នកនិពន្ធប្រើតែមាត្រា ដោយមិនមានបញ្ជាក់ច្បាប់ណាច្បាស់លាស់ គឺអ្នកនិពន្ធសំដៅតែទៅលើមាត្រាទាំងឡាយនៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ប៉ុណ្ណោះ។

[40] ករណីខ្លះច្បាប់កំណត់ការមិនគោរពលក្ខខណ្ឌតម្រូវនេះនាំឲ្យមានមោឃភាពសេចក្តីសម្រេច ដែលចេញដោយតុលាការទាំងនេះ សូមមើលមាត្រា ៥៤ មាត្រា ២៨៨ និងមាត្រា ៣៧៤ ក្នុងលេខយោងខាងក្រោម ទោះបីជាហេតុផលនេះដូចគ្នានឹងចំណុចទី៥ នៃមាត្រា ៤១៩ "ការបំពាន ឬភ្លេចទម្រង់ការ ដែលច្បាប់បញ្ញត្តិថាត្រូវទុកជាមោឃៈ" ក៏ដោយ ក៏ប្រហែលជាគេអាចអះអាងបានដូចគ្នាជាមូលដ្ឋានដើម្បីប្តឹងសាទុក្ខទៅតុលាការកំពូលបានដែរ ឈរលើមូលហេតុសមាសភាពមិនស្របច្បាប់នៃតុលាការ។

កាត់សេចក្ដីដោយចៅក្រម ដែលមានសមាសភាពថ្មី គំនិតថ្មីមិនពាក់ព័ន្ធពីអ្វីដែលខ្លួនធ្លាប់បានពិភាក្សា ឬសម្រេចសេចក្ដីពីមុន ព្រមទាំងប្រកាន់ភាពមិនលំអៀង មានអព្យាក្រឹតភាពដើម្បីផ្ដល់យុត្តិធម៌ និងស្វែងរកការពិត។ ខាងក្រោមនេះគឺជាសេចក្ដីបកស្រាយទៅលើករណីនីមួយៗដែលគេយល់ឃើញថា ជាសមាសភាពមិនស្របច្បាប់នៃតុលាការ។

ករណីទីមួយ គឺនៅពេលដែលមានការបដិសេធ ដោយតុលាការកំពូល លើសាលដីកាសាលាឧទ្ធរណ៍ហើយតម្រូវបង្វិលឲ្យសាលាឧទ្ធរណ៍កាត់សេចក្ដីឡើងវិញ ច្បាប់កំណត់ថា សមាសភាពនៃអង្គជំនុំជម្រះនៃសាលាឧទ្ធរណ៍នៃការជំនុំជម្រះលើកទី២នេះ ត្រូវមានសមាជិកថ្មីផ្សេងពីសមាសភាពពីមុន។[41] បើសិនជាសាលាឧទ្ធរណ៍មិនប្ដូរសមាសភាពថ្មី តែយកចៅក្រមដែលកាត់សេចក្ដីលើកទីមួយមកចូលរួមជំនុំជម្រះលើកទី២ នោះសមាសភាពនៃអង្គជំនុំជម្រះនេះគឺមានភាពផ្ទុយនឹងច្បាប់ ដែលជាមូលហេតុនាំឲ្យតុលាការកំពូលអាចច្រានចោលសាលដីកាសាលាឧទ្ធរណ៍បាន ដោយយោងលើមូលហេតុសមាសភាពមិនស្របច្បាប់នៃតុលាការ។

ករណីមួយទៀត(ករណីទីពីរ)នៃសមាសភាពមិនស្របច្បាប់នៃតុលាការ ដូចជាការជំនុំជម្រះរឿងក្ដីបទល្មើសឧក្រិដ្ឋនៅសាលាដំបូងដែលច្បាប់[42] តម្រូវឲ្យមានសមាសភាពចៅក្រមបីរូប[43]។ បើសិនជាសាលាដំបូងមិនគោរពតាមបញ្ញត្តិនេះ ដោយមានសមាសភាពតែចៅក្រមមួយរូប នោះជាការកាត់សេចក្ដីដែលសមាសភាពមិនស្របច្បាប់នៃតុលាការ។ ក្នុងករណីនេះគេអាចចោទសួរជាឧបមាថា បើសិនជានៅសាលាឧទ្ធរណ៍មិនមានភាគី[44]ណាមួយ លើកពីសមាសភាព

[41] សូមមើលមាត្រា ៤៣៩ ត្រង់ចំណុចពាក់ព័ន្ធចែងថា "...កាលណាតុលាការកំពូលបដិសេធសេចក្ដីសម្រេចដែលគេតវ៉ា តុលាការកំពូលបញ្ជូនរឿង និងគូភាគីនៅចំពោះមុខសាលាឧទ្ធរណ៍មួយផ្សេងទៀត ឬនៅចំពោះមុខសាលាឧទ្ធរណ៍ដដែល ប៉ុន្តែមានសមាសភាពថ្មីផ្សេងពីសមាសភាពមុន"។ យ៉ាងណាក៏ដោយ គេមិនត្រូវយល់ច្រឡំថា សមាសភាពនៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍ដែលត្រូវកាត់សេចក្ដីជាថ្មីលើរឿងក្ដីដដែល ក្នុងករណីដែលមានការប្ដឹងទាស់នឹងសាលដីកាកំបាំងមុខរបស់សាលាឧទ្ធរណ៍ សូមមើលមាត្រា ៤១៥ "សាលដីកាចេញតាមបណ្ដឹងទាស់" ត្រង់ចំណុចពាក់ព័ន្ធថា "រឿងត្រូវលើកមកជំនុំជម្រះនៅមុខសាលាឧទ្ធរណ៍ដដែល...." ។ ដោយហេតុ មាត្រា ៤១៥ នេះមិនមានចែងលម្អិតពីពាក្យ "សាលាឧទ្ធរណ៍ដដែល" អ្នកនិពន្ធយល់ថា មាត្រានេះសំដៅលើសមាសភាពដដែលនៃអង្គជំនុំជម្រះរបស់សាលាឧទ្ធរណ៍ ដែលការបកស្រាយនេះ យោងទៅលើមាត្រា ៤៣៩ ខាងលើ។

[42] សូមមើលមាត្រា ២៨៩ ដែលចែងត្រង់ចំណុចពាក់ព័ន្ធថា "... សាលាដំបូងសម្រេចជាក្រុមសមូហភាពដែលមានចៅក្រម ៣(បី) រូប ចំពោះបទឧក្រិដ្ឋ..."។

[43] សូមមើលមាត្រា ៣៤៨ ចំពោះករណីរឿងក្ដីព្រហ្មទណ្ឌជាបទល្មើសមជ្ឈិម តែសមាសភាពចៅក្រមមានបីរូបវិញគឺមានលក្ខណៈផ្ទុយពីករណីនេះដោយហេតុថា ច្បាប់អនុញ្ញាតឲ្យចៅក្រមបន្តមានសមត្ថកិច្ចដើម្បីជម្រះដដែល។

[44] ភាគីនាពេលនេះសំដៅលើ អយ្យការ ភាគីម្ចាស់បណ្ដឹងឧទ្ធរណ៍ និងចុងបណ្ដឹងឧទ្ធរណ៍។

មិនស្របច្បាប់នៃតុលាការសាលាដំបូង ហើយសាលដីកាសាលាឧទ្ធរណ៍មិនពិនិត្យ លើចំណុចនេះ តើភាគីអាចលើកយកចំណុចនេះជាមូលហេតុនៃបណ្តឹងសាទុក្ខ ដើម្បីឲ្យតុលាការកំពូលច្រានចោលសាលដីកាសាលាឧទ្ធរណ៍បានដែរទេ។ តាមទស្សនៈរបស់អ្នកនិពន្ធ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនបានកំណត់ជាក់លាក់ពីការថ្លោះសិទ្ធិប្តឹងតវ៉ា ដោយសារការមិនបានអះអាងបែបនេះនាពេលសវនាការនៅតុលាការជាន់ក្រោមនោះទេ។ ដូច្នេះភាគីនៅតែអាចលើកឡើងនៅក្នុងបណ្តឹងសាទុក្ខបាន ហើយតុលាការកំពូលអាចសម្រេចសេចក្តីឈរលើមូលដ្ឋាននេះ។ ម្យ៉ាងវិញទៀត ដោយសារក្នុងរឿងក្តីព្រហ្មទណ្ឌ តុលាការព្រហ្មទណ្ឌជាតុលាការសកម្ម ដូច្នេះទោះបីជាភាគីមិនលើកពីចំណុចនេះនៅក្នុងបណ្តឹងសាទុក្ខ ក៏តុលាការកំពូលអាចលើកឡើងពីសមាសភាពមិនស្របច្បាប់នៃតុលាការ ដោយឆន្ទានុសិទ្ធិបានដែរ។

ករណីទីបី គឺសមាសភាពនៃតុលាការមិនស្របច្បាប់ដែលហាមឃាត់វិសមិតភាពនៃមុខងារចោទប្រកាន់ ស៊ើបសួរ និងជំនុំជម្រះនៃចៅក្រម។[45] ការហាមឃាត់បែបនេះគឺមានគោលបំណងឲ្យរឿងក្តីត្រូវទទួលបានការកាត់សេចក្តី (ឬស៊ើបសួរ) ដោយបុគ្គលដែលមិនពាក់ព័ន្ធនឹងនីតិវិធីពីមុន ដើម្បីធានាអនាគតិ (ភាពមិនលម្អៀង)ជាអាទិ៍។ល។ ម្យ៉ាងទៀត ដូចដែលគេនិយាយប្រៀបធៀបជាទូទៅដោយប្រដូចទៅនឹងកីឡាបាល់ទាត់ ដែលមនុស្សម្នាក់មិនអាចជាកីឡាករផង និងជាអាជ្ញាកណ្តាលផងបាននោះទេ។ ករណីបែបនេះ អាចកើតមានឡើងដោយសារចៅក្រម ឬព្រះរាជអាជ្ញា អាចនឹងត្រូវបានតម្លើងតំណែង តែងតាំង ឬផ្លាស់ប្តូរទៅវិញទៅមកក្នុងចំណោមមុខងារទាំងនេះ។ ឧទាហរណ៍ ព្រះរាជអាជ្ញាដែលធ្វើបណ្តឹងអាជ្ញា (ចោទប្រកាន់) នៅសាលាដំបូងខេត្ត-ក្រុង អាចត្រូវបានតែងតាំងជាចៅក្រម ជាអនុប្រធាន ឬជាប្រធានសាលាឧទ្ធរណ៍ ហើយជំនុំជម្រះលើរឿងក្តីដដែល ដែលខ្លួនធ្លាប់ធ្វើបណ្តឹងអាជ្ញា។ ចំណុចនេះ អាចមានបញ្ហា

---

[45]សូមមើលមាត្រា ៥៤ "ចៅក្រមស៊ើបសួរមិនអាចចូលរួមក្នុងការជំនុំជម្រះរឿងព្រហ្មទណ្ឌ ដែលខ្លួនបានចាត់ការក្នុងឋានៈជាចៅក្រមស៊ើបសួរបានទេ បើពុំដូច្នេះទេ ការជំនុំជម្រះត្រូវចាត់ទុកជាមោឃៈ"។ សូមមើលផងដែរមាត្រា ២៨៨ "រវាងមុខងារជាចៅក្រម និងមុខងារជាព្រះរាជអាជ្ញា ឬជាព្រះរាជអាជ្ញារង គឺមានវិសមិតភាពនឹងគ្នាយ៉ាងដាច់ខាត។ ចៅក្រមណាដែលបានបំពេញមុខងារក្នុងឋានៈជាព្រះរាជអាជ្ញា ជាព្រះរាជអាជ្ញារង ឬជាចៅក្រមស៊ើបសួរលើរឿងណាមួយ មិនអាចចូលរួមក្នុងការជំនុំជម្រះរឿងនោះបានទេ បើពុំដូច្នោះទេ សាលក្រមនឹងត្រូវទុកជាមោឃៈ" និង មាត្រា ៣៧៤ "ចៅក្រមណាម្នាក់ដែលបានបំពេញកិច្ចចោទប្រកាន់ ឬស៊ើបសួរ ឬដែលបានចូលរួមជំនុំជម្រះសាលាដំបូងរួចហើយនោះ មិនអាចនឹងចូលរួមជំនុំជម្រះនៅសាលាឧទ្ធរណ៍ក្នុងឋានៈជាប្រធាន ឬចៅក្រមចំពោះរឿងដដែលនោះបានឡើយ"។ សូមមើលផងដែររដ្ឋធម្មនុញ្ញ មាត្រា ១២៩ថ្មី និងមាត្រា១៣១ថ្មី ដែលសំដៅការបែងចែកដាច់ពីគ្នាពីមុខងារធ្វើបណ្តឹងអាជ្ញា (សម្រាប់ការចោទប្រកាន់ សូមមើលមាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) និងមុខងារជំនុំជម្រះក្តី ។

ចោទដែលមេធាវីអាចមើលរំលង ឬមិនបានប្តឹងសាទុក្ខលើចំណុចនេះ[46] នៅពេលដែលមេធាវីទទួលការពារក្តីនៅតុលាការកំពូល ពុំបានថតចម្លងឲ្យបានសព្វគ្រប់នូវសំណុំរឿង ជាពិសេសតាមបទពិសោធន៍ជាក់ស្តែង ដែលក្រឡាបញ្ជីមួយចំនួនពុំបានថតចម្លងសំណុំរឿងទាំងមូលឲ្យដោយគ្រាន់តែបញ្ជាក់ថា យកតែផ្នែកសំខាន់ៗនៃសំណុំរឿងដែលគ្រប់គ្រាន់សម្រាប់ការពារក្តីបានហើយ (ក្រឡាបញ្ជីពុំមែនជាមេធាវី មិនយល់ពីតួនាទីមេធាវី យុទ្ធសាស្ត្រ និងទ្រឹស្តីនៃរឿងក្តីរបស់មេធាវី ហើយក៏មិនមែនជាតួនាទីរបស់ក្រឡាបញ្ជីក្នុងការធ្វើដូច្នេះដែរ[47])។

ដូច្នេះជាសរុបមក សមាសភាពមិនស្របច្បាប់នៃតុលាការ មានជាអាទិ៍ដូចជា សាលាឧទ្ធរណ៍មានសមាសភាពចៅក្រមដដែល ក្នុងករណីរឿងក្តីដែលបង្វិលពីតុលាការកំពូលដើម្បីជំនុំជម្រះសារជាថ្មីជាលើកទីពីរ ការមិនមានសមាសភាពបីរូបនៃចៅក្រមនៅសាលាដំបូងជំនុំជម្រះសេចក្តីក្នុងរឿងក្តីបទឧក្រិដ្ឋ និងសមាសភាពនៃតុលាការដែលមានវិសមិតភាពនៃមុខងារចោទប្រកាន់ ស៊ើបសួរ និងជំនុំជម្រះ គឺជាមូលហេតុដែលមេធាវីអាចប្តឹងសាទុក្ខ ទៅតុលាការកំពូល ដើម្បីច្រានចោលសាលដីកាសាលាឧទ្ធរណ៍។

(នៅមានតនៅលេខក្រោយ)

---

[46]ដូចបានអះអាងខាងលើ តុលាការព្រហ្មទណ្ឌជាតុលាការសកម្ម ដូច្នេះតុលាការអាចលើកពីចំណុចនេះដោយឆន្ទានុសិទ្ធិបានដែរ។ យ៉ាងណាក៏ដោយ នេះជាតួនាទីចម្បងរបស់មេធាវីក្នុងការជួយដល់តុលាការដើម្បីការពារប្រយោជន៍របស់កូនក្តី និងប្រយោជន៍យុត្តិធម៌ ដែលត្រូវធ្វើការឲ្យបានអស់ពីចិត្តពីថ្លើមពីសមត្ថភាព (due diligent) មិនត្រូវពឹងលើតុលាការដោយហេតុថា តុលាការអាចប្រើឆន្ទានុសិទ្ធិបែបនេះបានទេ។

[47]ជាពិសេសមេធាវីថ្មីដែលទទួលការពារក្តីបន្តនៅដំណាក់កាលតុលាការកំពូល។ សូមមើលផងដែរមាត្រា ១២៩ មុខងាររបស់ក្រឡាបញ្ជី ជាអាទិ៍។ ល។ មានការលើកឡើងជាញយដង អំពីបញ្ហានេះ ទាំងនៅក្នុងកម្មវិធីសិក្ខាសាលាមេធាវី ឬមហាសន្និបាតប្រចាំឆ្នាំរបស់គណៈមេធាវីផងដែរ។ យ៉ាងណាក៏ដោយគេអាចយល់ថា នេះអាចជាកំហុសរបស់មេធាវីផងដែរ បើសិនជាខ្លួនមិនព្យាយាមតវ៉ាឲ្យអស់ពីចិត្តពីថ្លើមពីសមត្ថភាព(due diligent) ទៅក្រឡាបញ្ជីកាន់សំណុំរឿង ឬ ចៅក្រមទទួលបន្ទុក ឬអង្គភាពដែលគ្រប់គ្រងក្រឡាបញ្ជី ជាអាទិ៍។ ល។

# ផ្នែកពាណិជ្ជកម្ម

# អនុប្បទានគណនី

ដោយមេធាវី **កុយ គន្ធី**[*]

## ១. សេចក្តីផ្តើម

ដើម្បីអនុវត្តគម្រោងអ្វីមួយ ឬសេចក្តីត្រូវការអ្វីមួយ បើគេគ្មានប្រាក់ខ្លួនឯងគ្រប់គ្រាន់ទេ គេតែងស្វែងរកប្រាក់ពីប្រភពខាងក្រៅដើម្បីផ្គត់ផ្គង់គម្រោង ឬសេចក្តីត្រូវការនោះ ដោយការខ្ចីប្រាក់ពីប្រភពនោះ។ ដើមដំបូងបំផុតការឲ្យខ្ចីត្រូវបានធ្វើឡើងតាមរយៈការស្គាល់គ្នា និងការជឿទុកចិត្តគ្នា។ ការផ្តល់កម្ចីតាមរយៈការជឿទុកចិត្តគ្នា មិនអាចផ្តល់នូវសន្តិសុខដល់ម្ចាស់-បំណុលជានិច្ចទេ។ ជួនកាលកូនបំណុលមិនសងប្រាក់វិញ ដោយប្រការណាមួយ ដូចជាការខាតបង់ ភាពទាល់ច្រកគ្មានប្រាក់សង ឬមានគំនិតមិនល្អចង់បំបាត់បំណុលជាដើម។ វិធីមួយក្នុងការទាមទារបំណុលមកវិញគឺត្រូវប្តឹងទៅតុលាការ ដើម្បីបង្គាប់ឲ្យកូនបំណុលសងប្រាក់មកម្ចាស់បំណុលវិញ។ ប៉ុន្តែក្នុងករណីដែលកូនបំណុលនៅតែមិនមានលទ្ធភាពសងប្រាក់ ម្ចាស់-បំណុលនៅតែមិនអាចទទួលបាននូវការសងប្រាក់ដដែល។ ឬទោះបីកូនបំណុលមានលទ្ធភាពសងក៏ដោយ ដោយសារនីតិវិធីតុលាការស្មុគស្មាញ និងអូសបន្លាយ ការសង្គ្រោះតាមផ្លូវតុលាការនៅតែជាបញ្ហាដល់ម្ចាស់បំណុល។

ដោយសារការឲ្យខ្ចីតាមរយៈការជឿទុកចិត្តរវាងម្ចាស់បំណុល និងកូនបំណុល មិនសូវមានសន្តិសុខ គេបានបង្កើតក្របខណ្ឌគតិយុត្តមួយទៀតដើម្បីបង្កើនសន្តិសុខដល់ម្ចាស់បំណុល គឺការធានាដោយបុគ្គល មានន័យថា មុននឹងកូនបំណុលអាចទទួលកម្ចីបាន កូនបំណុលត្រូវរកមនុស្សម្នាក់ ឬច្រើននាក់ (អាចជាបង ប្អូន ឬមិត្តភក្តិ ជាអាទិ៍) មកចូលរួមជួយធានាបំណុលក្នុងន័យបង្ការថា បើកូនបំណុលមិនសង បងប្អូន ឬមិត្តភក្តិ របស់កូនបំណុល ដែលជាអ្នកធានានោះនឹងសងជំនួសកូនបំណុល។ មធ្យោបាយនេះផ្តល់ឲ្យម្ចាស់បំណុល នូវជម្រើសក្នុងការទាមទារបំណុល ពោលគឺ បើកូនបំណុលមិនសងម្ចាស់បំណុលត្រូវបង្ខំអ្នកធានាឲ្យសង តាមរយៈបណ្តឹងនៅតុលាការជាដើម។ មធ្យោបាយនេះហាក់ដូចជាល្អសម្រាប់ម្ចាស់បំណុល ប៉ុន្តែម្ចាស់បំណុល

[*] លោក **កុយ គន្ធី** ជាមេធាវីនៅការិយាល័យមេធាវី ខេអិន ពិគ្រោះច្បាប់។ លោក **កុយ គន្ធី** ប្រកបវិជ្ជាជីវៈមេធាវីនៅក្នុងវិស័យភតិសន្យាហិរញ្ញវត្ថុ, ប្រតិបត្តិការអចលនវត្ថុ, ការសាងសង់, រដ្ឋប្បវេណី និងព្រហ្មទណ្ឌ។ អ្នកនិពន្ធសូមអរគុណដល់លោកមេធាវី **កុយ នាម** ដែលបានណែនាំ, ពិនិត្យ និងកែសម្រួលអត្ថបទនេះ។

នៅតែទទួលបន្ទុកហានិភ័យដដែល ដោយសារក្នុងករណីដែលអ្នកធានាគ្មានលទ្ធភាពសង ម្ចាស់បំណុលនៅតែមិនអាចប្រមូលបំណុលរបស់ខ្លួនមកវិញបានដដែល។

បន្ទាប់មកទៀត ដើម្បីពង្រឹងសន្តិសុខនៃបំណុលឲ្យកាន់តែរឹងមាំ ក្របខណ្ឌគតិយុត្តមួយទៀតត្រូវបានអភិវឌ្ឍន៍ដោយការធានាដោយវត្ថុ។ ការធានាដោយវត្ថុជាមូលដ្ឋានដែលគេបានប្រើគឺការបញ្ចាំ ឬការដាក់ហ៊ីប៉ូតែកដើម្បីធានាបំណុល។ វត្ថុដែលយកមកបញ្ចាំ/ហ៊ីប៉ូតែកគឺ អាចជាដីធ្លី (អចលនវត្ថុ) ការធានាបែបនេះ នាំឲ្យម្ចាស់បំណុលបន្ថយនូវហានិភ័យរបស់ខ្លួន ព្រោះក្នុងករណីដែលកូនបំណុលមិនសងបំណុល ម្ចាស់បំណុលអាចធ្វើការអនុវត្តសិទ្ធិរបស់ខ្លួន ដោយសុំឲ្យតុលាការធ្វើការអនុវត្តដោយបង្ខំទៅលើ ដីធ្លី ដែលកូនបំណុលបានដាក់បញ្ចាំ ឬដាក់ហ៊ីប៉ូតែកដើម្បីជម្រះបំណុលដែលកូនបំណុលមិនបានសង។

ការធានាបំណុលតាមរយៈការដាក់បញ្ចាំអចលនវត្ថុ និងហ៊ីប៉ូតែកគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពចំពោះម្ចាស់បំណុល ប៉ុន្តែចំនួនអចលនវត្ថុមានកម្រិត។ ចំពោះពាណិជ្ជករដែលប្រកបរបរផ្ដល់ហិរញ្ញប្បទាន ដូចជាធនាគារជាអាទិ៍ គេត្រូវធ្វើការបញ្ចេញឥណទានរបស់ខ្លួនឲ្យបានច្រើន តាមដែលអាចធ្វើទៅបាន ដូច្នេះការទាមទារឲ្យមានអចលនវត្ថុយកមកធានាបំណុលនោះនាំឲ្យអតិថិជនដែលគ្មានអចលនវត្ថុមិនអាចចូលទៅរកឥណទានបាន ថ្វីបើគេមានទ្រព្យសម្បត្តិផ្សេងទៀតក៏ដោយ ឧទាហរណ៍ ម្ចាស់ហាងដែលមានទំនិញនៅពេញក្នុងដៃជាដើម។ ដូច្នេះ ពាណិជ្ជករទាំងនោះងាកមករកការធានាកាតព្វកិច្ច (ធានាបំណុល) ដោយចលនវត្ថុវិញ។

ការធានាកាតព្វកិច្ចដោយចលនវត្ថុនេះ ត្រូវបានធ្វើឡើងជាពីររូបភាពគឺ ការធានាកាតព្វកិច្ចដោយចលនវត្ថុរូបី (Tangible movable property) និងចលនវត្ថុអរូបី (Intangible movable property)។

ការធានាកាតព្វកិច្ចដោយចលនវត្ថុរូបីអាចធ្វើឡើងក្រោមរូបភាពដូចជា ការបញ្ចាំចលនវត្ថុប្រាតិភោគដោយអនុប្បទាន ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និងការធានាដោយទំនិញ និងចលនវត្ថុ ដែលមានចែងនៅក្នុងច្បាប់ស្ដីពីប្រតិបត្តិការមានកិច្ចធានាឆ្នាំ២០០៧។

អត្ថបទនេះផ្ដោតតែលើការធានាកាតព្វកិច្ចដោយចលនវត្ថុអរូបី និងជាពិសេសចលនវត្ថុអរូបីប្រភេទគណនី។

## ២. អ្វីដែលហៅថា "គណនី"?

ការធានាកាតព្វកិច្ចដោយគណនីត្រូវបានគ្រប់គ្រងដោយច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧។ គណនីត្រូវបានកំណត់និយមន័យនៅក្នុងមាត្រា ៣.១១ នៃច្បាប់ស្ដីពី

ប្រតិបត្តិការដែលមានកិច្ចធានាដែលមានសេចក្តីថា៖

> "គណនី" សិទ្ធិទទួលការទូទាត់ថ្លៃទំនិញដែលបានលក់ ឬបានជួល ឬថ្លៃសេវាកម្ម ដែលមិនមែនជាលិខិតស្នាម ឬកិច្ចសន្យាលក់ដែលមានកិច្ចធានា។

យោងតាមមាត្រានេះ គេមិនត្រូវច្រឡំ "គណនី" (Account) ជាមួយគណនីធនាគារទេ។ គណនី គឺជាកំណត់ត្រាមួយដែលកត់សម្គាល់សិទ្ធិរបស់បុគ្គលម្នាក់ដែលបានលក់ទំនិញ ឬ សេវាទៅឲ្យបុគ្គលម្នាក់ទៀត ហើយបុគ្គលម្នាក់ទៀតនោះមិនទាន់បានទូទាត់ថ្លៃទំនិញ ឬ សេវាទៅឲ្យបុគ្គលខាងដើម។ ឧទាហរណ៍ ក្រុមហ៊ុនអេប៊ីស៊ី បានលក់កុំព្យូទ័រ ៥០ គ្រឿងទៅឲ្យក្រុមហ៊ុនអង្គរអភិវឌ្ឍន៍ ក្នុងតម្លៃមួយគ្រឿង ៧០០ ដុល្លារ ហើយក្រុមហ៊ុន អង្គរអភិវឌ្ឍន៍ ត្រូវទូទាត់ប្រាក់ក្នុងរយៈពេល ៣០ថ្ងៃ។ ក្រុមហ៊ុន អេប៊ីស៊ី បានចេញវិក្កយបត្រទៅឲ្យ ក្រុមហ៊ុន អង្គរអភិវឌ្ឍន៍ ឬកត់ត្រានៅក្នុងសៀវភៅរបស់ខ្លួនពីការទទួលទំនិញ និងប្រាក់ជំពាក់នៃក្រុមហ៊ុនអង្គរអភិវឌ្ឍន៍។ វិក្កយបត្រ ឬការកត់ត្រាទុកក្នុងសៀវភៅនេះ ជាភស្តុតាងនៃសិទ្ធិរបស់ ក្រុមហ៊ុន អេប៊ីស៊ី ដើម្បីទទួលបានការទូទាត់ប្រាក់ថ្លៃលក់កុំព្យូទ័ររបស់ខ្លួនពី ក្រុមហ៊ុន អង្គរអភិវឌ្ឍន៍។ តាមភាសាគណនេយ្យ គណនីដែលបានពោលមកនេះ គេហៅថាគណនីដែលត្រូវទទួល។

លិខិតស្នាម (Instrument) គឺជាកំណត់ត្រាដែលបង្ហាញភស្តុតាងពីសិទ្ធិទទួលប្រាក់ដែលមិនមែនជាកិច្ចព្រមព្រៀងប្រាតិភោគ (Security agreement) ឬកិច្ចសន្យាជួល (Lease) និងការផ្ទេរមួយប្រភេទដែលកើតឡើង តាមការប្រគល់ក្នុងអាជីវកម្មធម្មតាដោយមានបិដ្ឋិលេខចំណារខ្នង (Endorsement) ឬអនុប្បទានសិទ្ធិ (Assignment)។[48] ពាក្យនេះរាប់បញ្ចូលទាំងភស្តុតាងនៃសិទ្ធិប្រាតិភោគ (Certificated security) ផងដែរ។ ឧទាហរណ៍នៃលិខិតស្នាមមានដូចជា ប័ណ្ណខ្ចីប្រាក់ (Promissory note) ដែលគ្មានអមដោយកិច្ចព្រមព្រៀងប្រាតិភោគ វិញ្ញាបនបត្រភាគហ៊ុន។ ល។

កិច្ចសន្យាដែលមានកិច្ចធានា (Secured sale contract) មានន័យថា កំណត់ត្រាដែលបង្កើតកាតព្វកិច្ចបង់ប្រាក់ [កាតព្វកិច្ចជាទឹកប្រាក់] និងសិទ្ធិប្រាតិភោគ លើទំនិញ ឬការជួលទំនិញ (Security interest in, or lease of, goods)។[49] កិច្ចសន្យាដែលមានកិច្ចធានានេះមាននិយមន័យដូចគ្នានឹង Chattel paper នៅក្នុងច្បាប់អាមេរិកាំង (ក្រមពាណិជ្ជកម្មរួម មាត្រា ៩-១០៥(១)(៥)។ ឧទាហរណ៍នៃកិច្ចសន្យាដែលមានកិច្ចធានាមានដូចជា កិច្ចសន្យាដែលលក់ទំនិញជឿ ហើយអ្នកលក់រក្សាសិទ្ធិប្រាតិភោគលើទំនិញនោះ។ **សុខា** ចុះកិច្ចសន្យា

[48] មាត្រា ៣.២៦ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។

[49] មាត្រា ៣.៦ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។

ជួលរថយន្តជាមួយ **តារា** ក្នុងរយៈពេលមួយឆ្នាំ។ **សុខា** យកកិច្ចសន្យាជួលរថយន្តនោះទៅធានាការខ្ចីប្រាក់ពី **សំអុល** ចំនួន ៥០០ ដុល្លារ។ **សុខា** និង **សំអុល** បានចុះកិច្ចព្រមព្រៀងប្រាតិភោគដែលធានាដោយកិច្ចសន្យាជួល។ កិច្ចសន្យាទាំងពីរនេះរួមគ្នាជាកិច្ចសន្យាដែលមានកិច្ចធានា។

ទាំងគណនី, លិខិតស្នាម, និងកិច្ចសន្យាដែលមានកិច្ចធានាសុទ្ធតែទាក់ទងនឹងសិទ្ធិទទួលការទូទាត់ជាប្រាក់ទាំងអស់ ប៉ុន្តែគណនីជាសិទ្ធិទទួលការទូទាត់ប្រាក់ទាំងឡាយណាដែលមិនមែនជាលិខិតស្នាម និងកិច្ចសន្យាដែលមានកិច្ចធានា។ ឧទាហរណ៍ជាក់ស្តែងនៃគណនី គឺគណនីដែលត្រូវទទួល (Account receivable)។ ឯកសារភស្តុតាងនៃគណនីដែលត្រូវទទួលមានដូចជាឯកសារប្រគល់ទំនិញ ហើយអ្នកទទួលទំនិញមិនទាន់បង់ប្រាក់ថ្លៃទំនិញជាដើម ពោលគឺការទទួលទំនិញដោយជំពាក់។

## ៣. ការធានាកាតព្វកិច្ចដោយការធ្វើអនុប្បទានគណនី

ឧទាហរណ៍ ក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងសំណង់មួយមានអតិថិជនជាច្រើន ជាអ្នកម៉ៅការសំណង់។ ក្រុមហ៊ុននេះមានជោគជ័យក្នុងការធ្វើអាជីវកម្ម រហូតដល់ពេលមួយគាត់ចង់ពង្រីកអាជីវកម្មនេះឲ្យធំស្របនឹងសេចក្តីត្រូវការនៃទីផ្សារសំណង់។ តែអកុសល ក្រុមហ៊ុនខ្វះដើមទុនដើម្បីពង្រីកអាជីវកម្ម។ បញ្ហាម្យ៉ាងគឺ ដោយសារលំហូរសាច់ប្រាក់មានការកកស្ទះ ដោយសារអ្នកម៉ៅការសំណង់ជាច្រើនបង្វិលប្រាក់មកឲ្យក្រុមហ៊ុនមិនទាន់។ ដើម្បីពង្រីកអាជីវកម្មបាន ក្រុមហ៊ុនគិតចង់ខ្ចីប្រាក់ពីធនាគារ តែគេមិនមានអចលនវត្ថុដើម្បីយកទៅដាក់ធានាបំណុល។ ក្រុមហ៊ុនក៏ទៅចរចារជាមួយធានាគារដើម្បីខ្ចីប្រាក់ ដោយប្រាប់ធនាគារថា ខ្លួនមានគណនីដែលត្រូវទទួល ដែលមានទឹកប្រាក់ជាច្រើនក្នុងមួយខែៗ។ ក្រុមហ៊ុនបញ្ជាក់ថា ខ្លួនចង់ខ្ចីប្រាក់មួយចំនួន ហើយជាថ្នូរនឹងការសងប្រាក់នេះ ក្រុមហ៊ុននឹងធ្វើអនុប្បទានគណនីដែលត្រូវទទួលទាំងអស់ ឬក្នុងចំនួនណាមួយឲ្យធនាគារ។ **នេះជាការយកសិទ្ធិលើបំណុលទៅធានាបំណុល។** ជាទូទៅ ធនាគារមិនឲ្យប្រាក់ខ្ចីស្មើនឹងចំនួននៃគណនីដែលត្រូវទទួលឡើយ។ ឧទាហរណ៍ អ្នកផ្គត់ផ្គង់មានគណនីដែលត្រូវទទួលចំនួន ១០០.០០០ ដុល្លារ យកទៅធានា។ ធនាគារអាចផ្តល់កម្ចី ៨៥% នៃចំនួនទឹកប្រាក់នៃគណនីដែលត្រូវទទួល។

កាលណាមានការព្រមព្រៀងគ្នា ក្នុងការឲ្យខ្ចីជាថ្នូរនឹងការផ្ទេរសិទ្ធិលើគណនីដែលត្រូវទទួល ភាគីទាំងពីរចុះកិច្ចព្រមព្រៀងមួយ ដែលគេហៅថា កិច្ចព្រមព្រៀងប្រាតិភោគ (សូមមើលនិយមន័យក្នុងមាត្រា ៣.៧ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា)។ នៅក្នុងកិច្ចព្រមព្រៀងនេះ គេយកគណនីដែលត្រូវទទួលធ្វើជាប្រាតិភោគ (Collateral) ដែលជាវត្ថុសម្រាប់ធានាថា

កាលណាកូនបំណុលមិនសងបំណុលទេ ម្ចាស់បំណុលមានសិទ្ធិទាមទារយកប្រាតិភោគនោះ។ ដូច្នេះដំណើរការនៃការផ្ទេរសិទ្ធិលើ ឬអនុប្បទានគណនីត្រូវបានដូចខាងក្រោមនេះ ៖

១. អ្នកផ្គត់ផ្គង់លក់ទំនិញឲ្យអតិថិជនដោយឲ្យជំពាក់

២. អ្នកផ្គត់ផ្គង់កត់ត្រាគណនីដែលត្រូវទទួលពីអតិថិជន។ អតិថិជននេះគេហៅថា "កូន-បំណុលគណនី" (Account debtor or Obligor on account)។ យោងតាមមាត្រា ៣.៩ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា កូនបំណុលគណនីគឺ ជាបុគ្គលដែលជំពាក់កាតព្វកិច្ចក្នុងគណនី, កិច្ចសន្យាលក់ដែលមានកិច្ចធានា, ឬទ្រព្យអរូបីដទៃទៀត។

៣. អ្នកផ្គត់ផ្គង់សុំខ្ចីប្រាក់ពីគ្រឹះស្ថានឥណទាន (ឬគ្រឹះស្ថានដែលផ្តល់ប្រាក់កម្ចី) (Lending Institution)។

៤. អ្នកផ្គត់ផ្គង់ធានាចំពោះគ្រឹះស្ថានឥណទានថា ជាថ្នូរនឹងប្រាក់កម្ចីនេះ ខ្លួននឹងផ្ទេរសិទ្ធិលើគណនីដែលត្រូវទទួល (ឬធ្វើអនុប្បទានគណនីដែលត្រូវទទួល) ដែលមាននៅពេលបច្ចុប្បន្ន ឬដែលនឹងទទួលបាននាពេលអនាគត របស់ខ្លួនទៅឲ្យគ្រឹះស្ថានឥណទាន។[50] នេះជាការយកគណនីមកធ្វើជាប្រាតិភោគ។ គ្រឹះស្ថានឥណទានយកការប្រាក់លើប្រាក់កម្ចីព្រមទាំងថ្លៃសេវាឥណទាន។

៥. អ្នកផ្គត់ផ្គង់សន្យាថា ក្នុងករណីដែលខ្លួនខកខានសងបំណុលដល់គ្រឹះស្ថានឥណទាន គ្រឹះស្ថាននោះមានសិទ្ធិទាមទារយកគណនីដែលត្រូវទទួលពីអតិថិជន ដែលជាកូនបំណុលគណនី។ នៅក្នុងកិច្ចព្រមព្រៀង គេអាចចែងពីព្រឹត្តិការណ៍មិនអនុវត្តកាតព្វកិច្ច[51] (Event of default) ដើម្បីកំណត់ចំណុចនៃពេលវេលា ដែលអាចឲ្យគ្រឹះស្ថានឥណទានទាមទារយកគណនីដែលត្រូវទទួលពីកូនបំណុលគណនី។

៦.នៅក្នុងកិច្ចព្រមព្រៀងនេះ គេអាចចែងពី ខ ដែលតម្រូវឲ្យមានការជូនដំណឹងដល់កូនបំណុលគណនីបានដឹងពីសិទ្ធិរបស់គ្រឹះស្ថានឥណទានលើគណនី ឬមិនបាច់ជូនដំណឹងទៅកូនបំណុលគណនី ដើម្បីជៀសវាងកុំឲ្យកូនបំណុលគណនីដឹងពីស្ថានភាពហិរញ្ញវត្ថុរបស់អ្នក-

[50] សូមមើលមាត្រា ២៥ ច្បាប់ស្តីពី ប្រតិបត្តិការដែលមានកិច្ចធានា។ មាត្រា ២៥.២ អនុញ្ញាតឲ្យការប្រើប្រាស់ប្រាតិភោគដែលកូនបំណុលកំពុងមានបច្ចុប្បន្ន ឬដែលនឹងទទួលបាននាពេលអនាគត។ ឧទាហរណ៍ នៅពេលចរចាជាមួយធនាគារ អ្នកផ្គត់ផ្គង់មានគណនីដែលត្រូវទទួលពីអ្នកម៉ៅការសំណង់៥រូប ដែលមានទឹកប្រាក់ ១០.០០០ដុល្លារ។ គាត់អាចធានាជាមួយធនាគារថា គាត់សុំដាក់គណនីទាំងនេះជាប្រាតិភោគបច្ចុប្បន្ន ហើយតទៅមុខទៀត បើគាត់មានគណនីផ្សេងទៀត គាត់សុំយកគណនីដែលកើតមាននាពេលអនាគតទាំងនោះ មកធ្វើជា-ប្រាតិភោគទៀតនៅក្នុងកិច្ចព្រមព្រៀងបច្ចុប្បន្ន។

[51] មាត្រា ៤៦ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ មាត្រា ៣៨៩.ឃ នៃក្រមរដ្ឋប្បវេណី បើកសេរីភាពឲ្យភាគីកំណត់យកព្រឹត្តិការណ៍ណាមួយតាមការព្រមព្រៀងគ្នា មកធ្វើជាព្រឹត្តិការណ៍នៃការមិនអនុវត្តកាតព្វកិច្ច។

ផ្គត់ផ្គង់។[52] បើសិនជាមានការតម្រូវឲ្យជូនដំណឹងដល់កូនបំណុលគណនី គេអាចចែងអំពីកាតព្វកិច្ចរបស់កូនបំណុលគណនីត្រូវបង់ប្រាក់មកគ្រឹះស្ថានឥណទានដោយផ្ទាល់[53] ឬបង់ទៅឲ្យអ្នកផ្គត់ផ្គង់។[54]

៧.ក្នុងករណីដែលកិច្ចព្រមព្រៀងចែងថាកូនបំណុលគណនី (អតិថិជន) ត្រូវទូទាត់គណនីដល់អ្នកផ្គត់ផ្គង់ដោយផ្ទាល់ កូនបំណុលគណនីត្រូវបន្តទូទាត់គណនីដែលត្រូវទទួលឲ្យអ្នកផ្គត់ផ្គង់ដដែល ទោះបីគណនីនេះត្រូវបានផ្ទេរ ឬធ្វើអនុប្បទានឲ្យទៅគ្រឹះស្ថានឥណទានក៏ដោយ។

៨.កិច្ចព្រមព្រៀងអាចចែងថា កូនបំណុលគណនីត្រូវរក្សាតម្លៃគណនីក្នុងកម្រិតមួយ (ឧទាហរណ៍ ១៣០%) នៃចំនួនទឹកប្រាក់កម្ចី ហើយតួលេខនេះត្រូវរាយការណ៍មកគ្រឹះស្ថានឥណទានជារយៈពេលទៀងទាត់ ឬគ្រឹះស្ថានឥណទានអាចចុះទៅពិនិត្យពីស្ថានភាពនៃគណនីនេះនៅពេលណាគេចង់ដឹង។ នៅពេលណាមួយដែលមានការបំពានលើកិច្ចព្រមព្រៀង ឬស្ថានភាពគណនីធ្លាក់ចុះពីតម្លៃដែលបានកំណត់ អ្នកផ្គត់ផ្គង់អាច(តាមសេចក្តីចែងនៃកិច្ចព្រមព្រៀង) ទាមទារឲ្យអ្នកផ្គត់ផ្គង់ប្រមូលគណនី ព្រមទាំងបង្គាប់ឲ្យកូនបំណុលគណនីទូទាត់គណនីឲ្យគ្រឹះស្ថានឥណទានដោយផ្ទាល់[55] (កាលណាកិច្ចព្រមព្រៀងមិនទាមទារឲ្យកូនបំណុលគណនីបង់ប្រាក់ទូទាត់ដោយផ្ទាល់ទៅគ្រឹះស្ថានឥណទាន)។

ដ្យាក្រាមនៅផ្នែកខាងក្រោយ ពន្យល់បង្ហាញពីរបៀបធ្វើអនុប្បទានគណនី។

---

[52] មាត្រា ៥០៣ នៃក្រមរដ្ឋប្បវេណីចែងថា ដើម្បីអាចតតាំងចំពោះកូនបំណុល អនុប្បទាយី (គ្រឹះស្ថានឥណទាន) ត្រូវជូនដំណឹងដល់កូនបំណុលគណនី។ ទោះបីយ៉ាងនេះក្តី មាត្រា ២៥.៤ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាមិនតម្រូវឲ្យជូនដំណឹងទេ។ តែបើកិច្ចព្រមព្រៀងប្រាតិភោគទាមទារឲ្យជូនដំណឹងទៅកូនបំណុលគណនីវិញ ការជូនដំណឹងនោះត្រូវបញ្ជាក់ពីសិទ្ធិអ្វីខ្លះដែលត្រូវធ្វើអនុប្បទាន ហើយត្រូវបញ្ជាក់ទទួលស្គាល់ដោយអនុប្បទាយី (អ្នកផ្គត់ផ្គង់) ឬអនុប្បទានិក ហើយមិនចាំបាច់ត្រូវបើកបង្ហាញពីខចែង និងលក្ខខណ្ឌនានានៃកិច្ចព្រមព្រៀងប្រាតិ-ភោគឡើយ (មាត្រា ២៥.៥)។

[53] ជាការជាក់ស្តែង អ្នកផ្គត់ផ្គង់មិនចង់ឲ្យកូនបំណុលគណនីទូទាត់គណនីឲ្យគ្រឹះស្ថានឥណទានដោយផ្ទាល់ទេ ព្រោះគេត្រូវការបង្វិលប្រាក់រកស៊ីបន្ត។ អ្នកផ្គត់ផ្គង់ចង់បង់ការប្រាក់ឲ្យគ្រឹះស្ថានឥណទានវិញ ជាការប្រសើរ។

[54] យោងតាមមាត្រា ២៥.៧ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា កាលណាម្ចាស់បំណុល/អនុប្បទាយី (អ្នកផ្គត់ផ្គង់) ជូនដំណឹងទៅកូនបំណុលគណនី (អតិថិជន) ថាគណនីត្រូវបានធ្វើអនុប្បទានរួចហើយ ព្រមទាំងបញ្ជាក់ថាកូនបំណុលគណនីត្រូវបង់ឲ្យអនុប្បទានិកវិញនោះ (គ្រឹះស្ថានឥណទាន) នោះកូនបំណុលគណនីត្រូវបង្វែរការបង់ប្រាក់នោះទៅឲ្យអនុប្បទានិកវិញ។ ប៉ុន្តែ បើអនុប្បទាយី (អ្នកផ្គត់ផ្គង់មិនទាន់បានជូនដំណឹងពីការធ្វើអនុប្បទានគណនីទេនោះ កូនបំណុលគណនីត្រូវបង់ប្រាក់ឲ្យអ្នកផ្គត់ផ្គង់ (មាត្រា ២៥.៦)។

[55] សម្រាប់ព័ត៌មានបន្ថែមអំពី សិទ្ធិទាមទាររបស់គ្រឹះស្ថានឥណទាន សូមមើលមាត្រា ២៥ នៃច្បាប់ស្តីពី ប្រតិបត្តិការដែលមានកិច្ចធានា។

## ៤. ការធ្វើសុក្រឹតកម្មនៃគណនី

អ្នកផ្គត់ផ្គង់ប្រហែលជាមិនខ្ចីប្រាក់ពីប្រភពតែមួយទេ។ គេប្រហែលជាខ្ចីពីប្រភពផ្សេងទៀត ហើយយកគណនីនោះទៅធានាបំណុលដូចគ្នា។ ក្នុងករណីនេះ គ្រឹះស្ថានឥណទានដែលយើងកំពុងបានពោលមកនេះ ប្រហែលជាត្រូវគិតគូរពីផលប្រយោជន៍ប្រជែងគ្នាជាមួយប្រភពឥណទានផ្សេងទៀត។ ដើម្បីយកប្រៀបលើប្រភពឥណទានដទៃទៀតលើប្រាតិភោគតែមួយ គ្រឹះស្ថានឥណទាន ត្រូវធ្វើសុក្រឹតកម្មសិទ្ធិអនុប្បទានរបស់ខ្លួន (perfection of security interest)។ ដោយហេតុថា គ្រឹះស្ថានឥណទានមិនអាចកាន់កាប់គណនីបាន គ្រឹះស្ថាននេះត្រូវធ្វើសុក្រឹតកម្មដោយការចុះបញ្ជី (Perfection by filing) សិទ្ធិប្រាតិភោគរបស់ខ្លួន ដើម្បីបង្ហាញដល់ភាគីទីបីថា ប្រាតិភោគជាក់លាក់ណាមួយ ឬប្រភេទណាមួយត្រូវបានយកមកធានាបំណុលរបស់ខ្លួនរួចហើយ។ ដូច្នេះ កាលណាមានការទាមទារយកប្រាតិភោគណាមួយក្នុងបណ្តាភាគីច្រើន ភាគីណាដែលបានធ្វើសុក្រឹតកម្មមុនគេ ភាគីនោះត្រូវមានអាទិភាពក្នុងការទាមទារយកប្រាតិភោគនោះ។ ដូច្នេះ កាលបរិច្ឆេទនៃការធ្វើសុក្រឹតកម្ម ជាកត្តាកំណត់អាទិភាពនៃសិទ្ធិលើប្រាតិភោគ។[56]

សុក្រឹតកម្មត្រូវធ្វើនៅការិយាល័យចុះបញ្ជីប្រតិបត្តិការដែលមានកិច្ចធានា (Secured Transactions Filing Office) នៃក្រសួងពាណិជ្ជកម្ម។[57]




[56] សូមមើលមាត្រា ១២ នៃច្បាប់ស្តីពី ប្រតិបត្តិការដែលមានកិច្ចធានា។

[57] សម្រាប់ព័ត៌មានលំអិតនៃការចុះបញ្ជីប្រតិបត្តិការដែលមានកិច្ចធានា សូមចូលក្នុងគេហទំព័រ http://www.setfo.gov.kh

## ៥. ការអនុវត្តសិទ្ធិនៃអនុប្បទានគណនី

នៅពេលដែលអ្នកផ្ដត់ផ្គង់មិនបានអនុវត្តកាតព្វកិច្ចសងបំណុលរបស់ខ្លួន តាមកិច្ចព្រម-ព្រៀងប្រាតិភោគ គ្រឹះស្ថានឥណទានមានសិទ្ធិជូនដំណឹង និងតម្រូវឲ្យកូនបំណុលគណនីសងប្រាក់មកខ្លួនដោយផ្ទាល់ ទោះបីការធ្វើអនុប្បទានគណនីនោះមិនត្រូវបានជូនដំណឹងទៅកូន-បំណុលគណនីក៏ដោយ។[58] គ្រឹះស្ថានឥណទានអាចចាត់ការបង្គាប់ឲ្យកូនបំណុលគណនីសងប្រាក់មកខ្លួន ដោយមិនបាច់ពឹងពាក់តុលាការធ្វើអន្តរាគមន៍ឡើយ។[59] គ្រឹះស្ថានឥណទានអាចប្រមូលបំណុលពីកូនបំណុលគណនីតាមរបៀបសមរម្យក្នុងផ្លូវពាណិជ្ជកម្ម ហើយមានសិទ្ធិកាត់-កងការចំណាយរបស់ខ្លួនក្នុងការប្រមូលបំណុលនេះ បើប្រាក់ដែលប្រមូលបាននោះលើសពីបំណុលដែលអ្នកផ្ដត់ផ្គង់បានជំពាក់ ប៉ុន្តែបើការប្រមូលនេះមិនបានគ្រប់តាមចំនួនបំណុលដែលជំពាក់ទេ អ្នកផ្ដត់ផ្គង់ត្រូវនៅជំពាក់គ្រឹះស្ថានឥណទាននូវចំនួនមិនគ្រប់នោះ លើកលែងតែមានការព្រមព្រៀងគ្នាថា គ្រឹះស្ថានឥណទានសុខចិត្តយកត្រឹមចំនួនដែលប្រមូលបាន។[60]

ដើម្បីសម្រួលដល់ការប្រមូលគណនីពីកូនបំណុលគណនី មានវិធីមួយដែលគ្រឹះស្ថានឥណទានប្រើគឺ ការតម្រូវឲ្យអ្នកផ្ដត់ផ្គង់បើកគណនីមួយនៅក្នុងគ្រឹះស្ថានរបស់ខ្លួន (បើគ្រឹះស្ថាននោះជាធនាគារ) ហើយរាល់ការទូទាត់គណនីដែលត្រូវទទួលទាំងអស់ត្រូវធ្វើតាមរយៈគណនីធនាគារនោះ។ ការធ្វើបែបនេះអាចឲ្យគ្រឹះស្ថានមានអំណាចត្រួតត្រាលើគណនីរបស់គ្រឹះស្ថានបាន ហើយនៅពេលដែលអ្នកផ្ដត់ផ្គង់មិនអនុវត្តកាតព្វកិច្ច គ្រឹះស្ថានឥណទានអាចទទួលយកការបង់ប្រាក់ពីកូនបំណុលគណនី តាមរយៈគណនីរបស់អ្នកផ្ដត់ផ្គង់។

## ៦. ការលក់គណនី

ការលក់គណនីមានលក្ខណៈខុសពីការធ្វើអនុប្បទានគណនី។ នៅក្នុងអនុប្បទានគណនីអ្នកផ្ដត់ផ្គង់មានសិទ្ធិត្រួតត្រា និងប្រមូលគណនី រីឯនៅក្នុងការលក់គណនីវិញ ការប្រមូលគណនីជារឿងរបស់គ្រឹះស្ថានឥណទាន។

ឧបមាថា អ្នកផ្ដត់ផ្គង់មានគណនីច្រើនមានចំនួនទឹកប្រាក់រហូតដល់ទៅ ១.000.000ដុល្លារ តែគាត់ត្រូវការប្រាក់ ៨00.000ដុល្លារ។ គាត់អាចលក់គណនីដែលមានចំនួនទឹកប្រាក់ ១.000.000 ដុល្លារ ដោយសុខចិត្តទទួលថ្លៃលក់តែ ៨00.000ដុល្លារ ហើយការប្រមូលគណនីជាភារៈកិច្ចរបស់គ្រឹះស្ថានឥណទាន។ គ្រឹះស្ថានឥណទានបានចំណេញពីការជួញដូរនេះចំនួន ២00.000ដុល្លារ។

---

[58] មាត្រា ៤៧.២ ច្បាប់ស្ដីពី ប្រតិបត្តការដែលមានកិច្ចធានា។

[59] ប្រភពដូចខាងលើ មាត្រា ៤៧.៥។

[60] ប្រភពដូចខាងលើ មាត្រា ៤៧.៣។

កូនបំណុលគណនីមានកាតព្វកិច្ចទូទាត់ឲ្យគ្រឹះស្ថានឥណទានដោយផ្ទាល់។ បើសិនគ្រឹះស្ថានឥណទានមិនអាចប្រមូលគណនីបានពីកូនបំណុលគណនីបានទេ គ្រឹះស្ថានឥណទានមិនអាចមកទារប្រាក់ដែលខាតបង់ពីអ្នកផ្គត់ផ្គង់បានទេ។ គ្រឹះស្ថានឥណទានត្រូវទទួលយកហានិភ័យនៃប្រតិបត្តិការនេះ ដូច្នេះគ្រឹះស្ថានឥណទានត្រូវតែវាយតម្លៃ កូនបំណុលគណនីអំពីសមត្ថភាពសងរបស់គេ ហើយត្រូវមានសិទ្ធិតាមដានប្រតិបត្តិការរបស់អ្នកផ្គត់ផ្គង់យ៉ាងហ្មត់ចត់។

នៅក្នុងការលក់គណនីនេះ មានការផ្ទេរសិទ្ធិលើបំណុលទៅឲ្យអ្នកទិញ ដោយអ្នកទិញជាអ្នកប្រមូលគណនី។ បែបនេះជាការធ្វើអនុប្បទានក្នុងគោលបំណងផ្ទេរនាទីប្រមូលគណនីឲ្យអ្នកទិញ។ អ្នកទិញគណនីនេះគេហៅថាឈ្មួញគណនី (Factor) ហើយដំណើរការនៃការជួញដូរគណនីនេះ គេមិនហៅថាជាអនុប្បទានគណនីទេ តែគេហៅថា Factoring។

ដោយសារនៅក្នុងដំណើការជួញដូរនេះមានការពាក់ព័ន្ធនឹងការផ្ទេរ (អនុប្បទាន) គណនីពីអ្នកលក់ទៅឲ្យអ្នកទិញ ប៉ុន្តែក្នុងគោលបំណងប្រមូលប្រាក់ដែលជំពាក់ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាមិនអនុវត្តលើប្រតិបត្តិការនេះទេ។[61]




**<u>ដ្យាក្រាមនៃការលក់</u>**
**គណនី**

[61] ប្រភពដដែល មាត្រា ២.៤.គ។

## ៧. សេចក្តីសន្និដ្ឋាន

ដូចបានកត់សម្គាល់នៅខាងដើម ហិរញ្ញប្បទាននៅប្រទេសកម្ពុជាយើង ជាទូទៅត្រូវបានធ្វើឡើងតាមរយៈការបញ្ចាំ ឬដាក់ធានាអចលនទ្រព្យ ឬហ៊ីប៉ូតែក។ មានហិរញ្ញប្បទានខ្លះទៀតត្រូវបានធ្វើតាមរយៈការដាក់បញ្ចាំ ឬធានាដោយចលនទ្រព្យដែលជាទូទៅអាចជារថយន្ត ឬយានជំនិះ។ ហិរញ្ញប្បទានដែលធ្វើឡើង ដោយការធានាទ្រព្យអរូបីគឺជាទម្រង់មួយដែលមិនធ្លាប់មានទោះបីច្បាប់ស្តីពី កិច្ចប្រតិបត្តិការដែលមានកិច្ចធានា បានអនុម័តជប់ឆ្នាំហើយក៏ដោយ អត្ថបទនេះគ្រាន់តែណែនាំរបៀបធ្វើហិរញ្ញប្បទានថ្មី ដែលច្បាប់បានអនុញ្ញាតប៉ុណ្ណោះ៕

# ផ្នែករដ្ឋប្បវេណី

# ហ៊ីប៉ូតែក

ដោយមេធាវី **អ៊ីវ ប៉ូលី***

ការធានាបំណុលតាមរយៈហ៊ីប៉ូតែក ជាប្រព័ន្ធធានាដែលកំណត់វត្ថុធានាជាក់លាក់ ដែលយើងហៅថា ការធានាដោយវត្ថុ។ ប្រព័ន្ធនេះត្រូវបានបង្កើតឡើងដើម្បីធានាដល់ការសងបំណុល មានន័យថាបុគ្គលដែលទទួលកាតព្វកិច្ច នៅពេលដែលមិនអនុវត្តកាតព្វកិច្ច បុគ្គលដែលមានសិទ្ធិអាចអនុវត្តសិទ្ធិរបស់ខ្លួនដោយមានភាពងាយស្រួល និងមានអាទិភាពជាងបុគ្គលដែលមានសិទ្ធិលើបំណុលដែលមិនត្រូវបានធានា។ ហ៊ីប៉ូតែក គឺជាប្រភេទនៃសិទ្ធិប្រតិភោគប្រត្រក្យដែលម្ចាស់បំណុលមិនកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកដោយផ្ទាល់ទេ ក្នុងន័យនេះ យើងឃើញថា ហ៊ីប៉ូតែកគ្រប់គ្រងចំពោះតម្លៃនៃវត្ថុប៉ុណ្ណោះ ហេតុនេះកូនបំណុល ឬតតិយជនដែលយកវត្ថុមកដាក់ហ៊ីប៉ូតែកនៅតែមានសិទ្ធិ ប្រើប្រាស់ អាស្រ័យផល និងចាត់ចែងពីវត្ថុនោះ។

ក្រៅពីគោលបំណងនៃការការពារម្ចាស់បំណុល ការធានាតាមរយៈហ៊ីប៉ូតែកក៏ការពារកូនបំណុលផងដែរ តាមរយៈការអនុញ្ញាតឲ្យកូនបំណុលប្រើប្រាស់ឲ្យអស់ពីលទ្ធភាពពីតម្លៃនៃវត្ថុ ដូចជាការបង្កើតហ៊ីប៉ូតែកច្រើនដងលើវត្ថុតែមួយ ហើយលំដាប់អាទិភាពត្រូវបានកំណត់យកពេលវេលានៃការចុះបញ្ជីហ៊ីប៉ូតែក[62] ដោយមិនតម្រូវឲ្យផ្ទេរប័ណ្ណកម្មសិទ្ធិ និងមិនអនុញ្ញាតឲ្យម្ចាស់បំណុលយកវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក មកធ្វើជាកម្មសិទ្ធិរបស់ខ្លួនឡើយ។

នៅក្នុងក្រមរដ្ឋប្បវេណីបានកំណត់អំពីកម្មវត្ថុនៃហ៊ីប៉ូតែក ដែលអាចជាអចលនវត្ថុ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ជាអាទិ៍។ ប៉ុន្តែទោះបីជាដូច្នោះក៏ដោយ ប្រសិនបើមានអត្ថបទ

---

* លោក **អ៊ីវ ប៉ូលី** ជាមេធាវីនៃក្រុមហ៊ុនមេធាវី កម្ពុជា អន្តរជាតិ
ជាសមាជិកក្រុមប្រឹក្សាគណៈមេធាវី
ជាប្រធានក្រុមការងារកិច្ចការរដ្ឋប្បវេណីនៃគណៈមេធាវី និង
ជាគ្រូបង្រៀនច្បាប់នៃមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី។

[62] មាត្រា ៨៥១ នៃក្រមរដ្ឋប្បវេណី។

ច្បាប់ពិសេសទទួលស្គាល់នូវកម្មវត្ថុផ្សេងទៀត[63] ក៏មានអនុភាពផងដែរ ដូចជា ច្បាប់ពិសេសកំណត់ថា យន្តហោះ នាវា ឬវត្ថុផ្សេងៗដែលអាចចុះបញ្ជី គឺជាផ្នែកមួយនៃកម្មវត្ថុហ៊ីប៉ូតែក ហេតុនេះប្រសិនបើមានច្បាប់ពិសេសបែបនេះមែន កម្មវត្ថុនៃហ៊ីប៉ូតែកនឹងពង្រីកវិសាលភាព។

ដើម្បីក្លាយជាម្ចាស់បំណុលហ៊ីប៉ូតែកស្របច្បាប់ តើត្រូវធ្វើដូចម្តេច?

ដើម្បីចុះបញ្ជីហ៊ីប៉ូតែក តើភាគីត្រូវធ្វើដូចម្តេច?

តើហ៊ីប៉ូតែកមានប្រយោជន៍អ្វីក្នុងប្រតិបត្តិការសេដ្ឋកិច្ច?

ការទទួលបានឋានៈជាម្ចាស់បំណុលហ៊ីប៉ូតែកស្របច្បាប់ ត្រូវធ្វើឡើងតាមលក្ខខណ្ឌដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណី ដោយលក្ខខណ្ឌបង្កើត គឺហ៊ីប៉ូតែកត្រូវបានបង្កើតឡើងតាមការព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុល ឬតតិយជនប៉ុណ្ណោះ មានន័យថា កិច្ចសន្យាហ៊ីប៉ូតែក មានអានុភាពត្រឹមការព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុល ឬតតិយជន ទោះបីផ្ទាល់មាត់ក៏ដោយ។[64] ប៉ុន្តែដើម្បីអាចតតាំងជាមួយនឹងតតិយជន ឬបុគ្គលផ្សេងទៀតក្រៅពីភាគីហ៊ីប៉ូតែកត្រូវធ្វើឡើងតាមទម្រង់យថាភូត និងចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី។[65] លិខិតយថាភូតដែលមានបញ្ញត្តិនៅក្នុងមាត្រា ៨៤៥ នៃក្រមរដ្ឋប្បវេណី សំដៅលិខិតដែលធ្វើឡើង ដោយមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីនីតិវិធីចុះបញ្ជី[66] គឺមេឃុំ.ចៅសង្កាត់។

## ទម្រង់នៃកិច្ចសន្យាមានដូចខាងក្រោម

## កិច្ចសន្យាបង្កើតហ៊ីប៉ូតែក

*ម្ចាស់បំណុលហ៊ីប៉ូតែក៖ អត្តសញ្ញាណ....*

*អ្នកបង្កើតហ៊ីប៉ូតែក៖ អត្តសញ្ញាណ.......*

*ក. កម្មវត្ថុនៃកិច្ចសន្យា៖ បង្កើតហ៊ីប៉ូតែកលើអចលនវត្ថុ ទំហំនៃសិទ្ធិលើបំណុលគឺ ប្រាក់ដើម ការប្រាក់សំណងនៃការខូចខាត ជាអាទិ៍*

*ខ. ការធានាអះអាង៖ អចលនវត្ថុនេះគឺជាកម្មសិទ្ធិរបស់អ្នកបង្កើត*

---

[63] មាត្រា ៨៤៣ ក្រមដ្ឋប្បេវណី។

[64] មាត្រា ៨៤៤ នៃក្រមរដ្ឋប្បវេណី។

[65] មាត្រា ៨៤៥ នៃក្រមរដ្ឋប្បវេណី។

[66] មាត្រា០៩ចំណុច "ខ" នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។

*គ- ខសន្យាពិសេស៖ អ្នកបង្កើតមិនលក់អចលនវត្ថុនេះ ក្នុងអំឡុងពេលនេះទេ ជាអាទិ៍*

*ឃ- បទប្បញ្ញត្តិរួម៖ ភាគីទាំងពីរត្រូវអនុវត្តកិច្ចសន្យានេះដោយសុចរិត និងស្មោះត្រង់*

*ហត្ថលេខាម្ចាស់បំណុលសេចក្តីបញ្ជាក់មេឃុំ-ចៅសង្កាត់ ហត្ថលេខាកូនបំណុល*

ដើម្បីចុះបញ្ជីហ៊ីប៉ូតែក ត្រូវធ្វើតាមលក្ខខណ្ឌដែលមានកំណត់នៅក្នុងប្រកាសអន្តរក្រសួង ស្តីពី នីតិវិធីនៃការចុះបញ្ជីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី[67] ដែលមានខ្លឹមសារថា ៖

## ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក

*បុគ្គលមានសិទ្ធិទាមទារឲ្យចុះបញ្ជី (ម្ចាស់បំណុលហ៊ីប៉ូតែក)*

*អ្នកមានកាតព្វកិច្ចចុះបញ្ជី (អ្នកបង្កើតហ៊ីប៉ូតែក)*

*ក- គោលបំណងនៃការចុះបញ្ជី៖ ការបង្កើតហ៊ីប៉ូតែកលើកម្មសិទ្ធិ*

*ខ- មូលហេតុ៖ កិច្ចសន្យាខ្ចីប្រាក់ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក*

*គ- បុគ្គលមានសិទ្ធិទាមទារឲ្យចុះបញ្ជី៖ អត្តសញ្ញាណម្ចាស់បំណុល*

*ឃ- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី៖ អត្តសញ្ញាណអ្នកបង្កើតហ៊ីប៉ូតែក (កូនបំណុល ជាអាទិ៍)*

*ង- ចំណុចផ្សេងៗដែលត្រូវចុះបញ្ជី៖ ប្រាក់ដើម ការប្រាក់ សំណងនៃការខូចខាត ជាអាទិ៍*

*ច- អត្តសញ្ញាណកម្មវត្ថុនៃហ៊ីប៉ូតែក ៖ អចលនវត្ថុ................*

បន្ទាប់ពីបានបំពេញឯកសារទាំងនេះហើយ និងបានយកទៅអង្គភាពសុរិយោដីនៃទីតាំងដែលអចលនវត្ថុស្ថិតនៅរួចហើយ មន្ត្រីចុះបញ្ជីនឹងចេញលិខិតដែលមានខ្លឹមសារថា៖

## ខ្លឹមសារនៃការចុះបញ្ជីហ៊ីប៉ូតែក

*១. បង្កើតហ៊ីប៉ូតែកឲ្យម្ចាស់បំណុលហ៊ីប៉ូតែក (B)*

*កូនបំណុល (A)*

*ប្រាក់ដើម ២០.០០០ ដុល្លារអាមេរិក*

*ការប្រាក់ ១៨%*

*ការប្រាក់យឺតយ៉ាវ ២៧%*

[67] ប្រកាសអន្តរក្រសួងរវាងក្រសួងយុត្តិធម៌ និងក្រសួងដែនដីនគររូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ ២០១៣ ស្តីពីពីនីតិវិធីនៃការចុះបញ្ជីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី។

*តាមរយៈកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ១០.១០.២០១២ និង*
*កិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី ១០.១០.២០១២*

ហ៊ីប៉ូតែក ជាឧបករណ៍ធានាបំណុលមួយជួយឲ្យអ្នកផ្តល់សេវាហិរញ្ញវត្ថុមានទំនុកចិត្ត បន្តសកម្មភាពផ្តល់សេវាកម្ចីទៅលើគ្រប់ប្រតិបត្តិការ ផ្តល់ទំនុកចិត្តឲ្យគ្នាទៅវិញទៅមក (កូនបំណុល និងម្ចាស់បំណុល) ធានាបាននូវការសងដែលមានអាទិភាពសម្រាប់ម្ចាស់បំណុលហ៊ីប៉ូតែក ហើយ អនុញ្ញាតឲ្យកូនបំណុលប្រើប្រាស់វត្ថុនោះបាន មានន័យថា កូនបំណុល និងម្ចាស់បំណុល ទទួលបានផលចំណេញដូចគ្នា ក្នុងការជ្រើសរើសយកប្រតិបត្តិការនេះ។

សរុបមក ហ៊ីប៉ូតែកជាយន្តការបង្កើតឡើងដើម្បីធានាសិទ្ធិលើបំណុល តាមរយៈការ កំណត់វត្ថុជាក់លាក់ (ការធានាដោយវត្ថុ) ដោយអនុញ្ញាតឲ្យម្ចាស់បំណុលហ៊ីប៉ូតែកទទួលបាន ការសងជាអាទិភាព និងផ្តល់សិទ្ធិឲ្យកូនបំណុលប្រើវត្ថុនោះឲ្យអស់តម្លៃ។ ហ៊ីប៉ូតែកជាប្រភេទ មួយនៃសិទ្ធិប្រាតិភោគប្រត្យក្សដែលមានអានុភាពអះអាងចំពោះភាគីតតិយជន និងបុគ្គលផ្សេង ទៀត នៅពេលបំពេញលក្ខខណ្ឌតាមច្បាប់កំណត់ (លក្ខខណ្ឌបង្កើតអានុភាព និងលក្ខខណ្ឌ តតាំង) ហើយម្ចាស់បំណុលហ៊ីប៉ូតែកអាចចាត់ចែងសិទ្ធិនេះបានដោយសេរី ដូចជា លក់ ឬធ្វើ អំណោយ ឬដាក់ប្រាតិភោគនូវហ៊ីប៉ូតែករបស់ខ្លួនឲ្យទៅបុគ្គលដទៃបាន។ ដើម្បីទទួលបានការ ការពារ និងសិទ្ធិដ៏ច្រើនបែបនេះ ការចុះបញ្ជីគឺជាជម្រើសដែលខ្វះមិនបាន និងត្រូវចុះបញ្ជីនៅ អង្គភាពសុរិយោដីនៃទីតាំងដីស្ថិតនៅ៕

# កំជាប់ពាក្យ

ដោយមេធាវី **អ៊ីវ ប៉ូលី***

ទំនាក់ទំនងញាតិ គឺអានុភាពគតិយុត្តមួយដែលមានលក្ខណៈស្មុគស្មាញចាប់តាំងពីការបង្កើតដំណើរការ និងការបញ្ចប់ដែលនៅក្នុងលក្ខខណ្ឌនេះ សហព័ទ្ធក៏ជាញាតិតាមផ្លូវច្បាប់ផងដែរ និងនៅពេលទទួលឋានៈជាសហព័ទ្ធ ជាទំនៀមទម្លាប់នៅក្នុងប្រទេសកម្ពុជា ពេលខ្លះគឺមានពិធីមួយ យើងហៅថាពិធីកំជាប់ពាក្យ មុននឹងអាចឈានទៅដល់ការកំណត់ថ្ងៃរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែមិនមែនជាបុរេលក្ខខណ្ឌច្បាប់នៃអាពាហ៍ពិពាហ៍នោះទេ។

កំជាប់ពាក្យ គឺជាសេចក្តីសន្យារវាងបុរស នារី ថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត ដោយធ្វើពិធីកំជាប់ពាក្យដែលជាទូទៅនៅក្នុងសង្គមកម្ពុជា មុននឹងឈានដល់ការរៀបអាពាហ៍ពិពាហ៍តាមច្បាប់ តែងតែមានការរៀបចំពិធីកំជាប់ពាក្យ ដើម្បីជាសក្ខីភាពនៃការសន្យាថានឹងរៀបអាពាហ៍ពិពាហ៍ ដោយនៅក្នុងពិធីកំជាប់ពាក្យតែងតែមានជំនូន។

ជាទម្លាប់គឺ ខាងប្រុសយកជំនូនមកឱ្យខាងស្រី ដោយជំនូនគឺជាភស្តុភារ ឬបណ្ណាការដែលភាគីម្ខាងជូនទៅភាគីម្ខាងទៀត នៅក្នុងអំឡុងពេលរៀបចំពិធីកំជាប់ពាក្យ ដោយសង្ឃឹមថានឹងបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត។

ប្រសិនបើកំជាប់ពាក្យត្រូវបានរំលាយ ឬមិនអាចរៀបអាពាហ៍ពិពាហ៍បាន តើត្រូវដោះស្រាយដូចម្តេចតាមច្បាប់?

តើជំនូនដែលបានផ្តល់រួចហើយ អាចទាមទារតាមវិធីណា?

ប្រសិនបើមានការខូចខាត តើអាចទាមទារតាមវិធីណា?

កំជាប់ពាក្យគឺជាការសន្យារបស់បុរស និងនារី ប៉ុន្តែការសន្យានេះគឺមានលក្ខណៈខុសពីកិច្ចសន្យាធម្មតា មានន័យថា ជាគោលការណ៍ បើកិច្ចសន្យាគ្មានវិការៈក្នុងការបង្ហាញឆន្ទៈ ឬគ្មាន

---

* លោក **អ៊ីវ ប៉ូលី** ជាមេធាវីនៃក្រុមហ៊ុនមេធាវី កម្ពុជា អន្តរជាតិ
ជាសមាជិកក្រុមប្រឹក្សាគណៈមេធាវី
ជាប្រធានក្រុមការងារកិច្ចការរដ្ឋប្បវេណីនៃគណៈមេធាវី និង
ជាគ្រូបង្រៀនច្បាប់នៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។

កំហុសនោះទេ ភាគីត្រូវអនុវត្តកិច្ចសន្យា។ ផ្ទុយទៅវិញ ចំពោះកំជាប់ពាក្យ បើភាគីណាម្ខាង បដិសេធការរៀបអាពាហ៍ពិពាហ៍ ដោយគ្មានមូលហេតុត្រឹមត្រូវក៏ដោយ ក៏ភាគីម្ខាងទៀតមិនអាចទាមទារឱ្យភាគីម្ខាងទៀតអនុវត្តការសន្យានោះបានដែរ ពីព្រោះការរៀបអាពាហ៍ពិពាហ៍ត្រូវធ្វើឡើង ដោយការស្ម័គ្រចិត្តរបស់ភាគី ហេតុនេះដំណោះស្រាយតាមផ្លូវច្បាប់ចំពោះអ្នកខូចប្រយោជន៍គឺមានសិទ្ធិទាមទារជំនួន និងសំណងនៃការខូចខាត ទៅតាមនីតិវិធីដែលមានកំណត់នៅក្នុងច្បាប់ជាធរមាន។[68]

កំជាប់ពាក្យរលាយ នៅពេលគម្រោងរៀបអាពាហ៍ពិពាហ៍មិនអាចដំណើរការទៅបានតាមកាលបរិច្ឆេទដែលបានកំណត់សម្រាប់ដំណើរការរៀបចំពិធីអាពាហ៍ពិពាហ៍ ឬភាគីម្ខាងទៀតស្នើសុំផ្តាច់ពាក្យ ឬភាគីទាំងសងខាងព្រមព្រៀងគ្នាផ្តាច់ពាក្យ ឬភាគីណាម្ខាងបានទទួលមរណភាព។

ក្នុងករណីភាគីម្ខាងបដិសេធកំជាប់ពាក្យដោយគ្មានមូលហេតុត្រឹមត្រូវ ឬមិនអាចរៀបអាពាហ៍ពិពាហ៍បាន ភាគីខូចផលប្រយោជន៍អាចធ្វើបណ្តឹងដើម្បីទាមទារជំនួន និងសំណងនៃការខូចខាត។ ប្រសិនបើភាគីណាបានលើកជំនួនឲ្យទៅភាគីម្ខាងទៀត ដើម្បីរៀបចំពិធីកំជាប់-ពាក្យ ភាគីនោះអាចទាមទារជំនួនត្រលប់មកវិញបាន ក្នុងករណីកំជាប់ពាក្យត្រូវបានរំលាយដោយគ្មានមូលហេតុសមរម្យ។ មូលហេតុសមរម្យដើម្បីអាចរំលាយកំជាប់ពាក្យបាន មានដូចជាភាគីម្ខាងមិនស្មោះត្រង់ មានគូដណ្តឹងហើយ ប៉ុន្តែនៅតែមានដៃគូជីវិតផ្សេងទៀត ឬភាគីម្ខាងមិនអាចផ្តល់សុភមង្គលសម្រាប់គ្រួសារ (លេងល្បែង ជក់ថ្នាំញៀន ឬគ្មានមុខការពិតប្រាកដ ឬប្រកបរបរខុសច្បាប់ ជាអាទិ៍) ឬភាគីម្ខាងប្រមាថមើលងាយភាគីម្ខាងទៀត ក្រុមគ្រួសារភាគីម្ខាងទៀត ឬភាគីម្ខាងប្រើហិង្សាលើភាគីម្ខាងទៀត ជាអាទិ៍។

ប្រសិនបើការរំលាយកំជាប់ពាក្យបណ្តាលឲ្យមានការខូចខាត ភាគីដែលទទួលរងការខូចខាតអាចទាមទារសំណងនៃការខូចខាតបាន ទាំងសំណងផ្នែកសម្ភារៈ និងសំណងផ្លូវចិត្ត

[68] មាត្រា ៩៤៦ ក្រមរដ្ឋប្បវេណី

ពីភាគីម្ខាងទៀត។ ការគណនាសំណងនៃការខូចខាត យើងអាចយកមូលដ្ឋាននៃការមិនអនុវត្តកាតព្វកិច្ច ឬអំពើអនីត្យានុកូល ក្នុងការវិនិច្ឆ័យអំពីទំហំនៃសំណងសម្រាប់អ្នកដែលខាតបង់។[69]

អ្នកដែលមានសិទ្ធិទាមទារជំនូន និងសំណងនៃការខូចខាតត្រូវធ្វើបណ្តឹងនៅក្នុងអំឡុងពេល ០១ (មួយ)ឆ្នាំ គិតចាប់ពីពេលដែលកំជាប់ពាក្យនោះត្រូវបានរំលាយ។[70]

សរុបសេចក្តីមក កំជាប់ពាក្យជាកិច្ចសន្យារវាងបុរស និងនារី ថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត។ ជាទំនៀមទម្លាប់បុរសជាអ្នកលើកជំនូន ទៅភាគីខាងនារីដើម្បីរៀបចំពិធីកំជាប់ពាក្យ ដោយធ្វើពិធីនៅផ្ទះខាងស្រី។ ប្រសិនបើភាគីនារីស្នើសុំមិនរៀបអាពាហ៍ពិពាហ៍ ឬផ្តាច់ពាក្យដោយគ្មានមូលហេតុសមរម្យ ភាគីបុរសអាចទាមទារជំនូនពីភាគីនារីវិញបាន ហើយក៏អាចទាមទារសំណងនៃការខូចខាត ប្រសិនបើមានការខូចខាតកើតឡើង។ ការអនុវត្តសិទ្ធិទាមទារជំនូន និងសំណងនៃការខូចខាតត្រូវធ្វើឡើងតាមផ្លូវតុលាការក្នុងអំឡុងពេល ០១ (មួយ)ឆ្នាំ គិតចាប់ពីពេលកំជាប់ពាក្យត្រូវបានរំលាយ ប្រសិនបើភាគីនារីមិនសងជំនូន និង/ឬ ការខូចខាតដោយស្ម័គ្រចិត្ត៕

69 មាត្រា ៩៤៥ ក្រមរដ្ឋប្បវេណី

70 មាត្រា ៩៤៧ ក្រមរដ្ឋប្បវេណី

# ច្បាប់កម្ពុជាក្នុងទិដ្ឋភាពអន្តរជាតិ

# ច្បាប់សន្តតិកម្មកម្ពុជាក្នុងទិដ្ឋភាពអន្តរជាតិ (ភាគ ១)

លោក **កែ ប៊ុនធឿន***

## ១. សេចក្តីផ្តើម

សន្តតិកម្មចាប់ផ្តើមនៅពេលមតកជនបានទទួលមរណភាព ឬសន្មតថាបានទទួលមរណភាពក្នុងករណីបុគ្គលនោះបានបាត់ខ្លួនដោយមានការប្រកាសពីតុលាការ នោះទ្រព្យសម្បត្តិរបស់ខ្មោច (មតកជន) នឹងត្រូវបានចាត់ចែងតាមបណ្តាំ (មតកសាសន៍) ឬតាមផ្លូវច្បាប់។ នៅក្នុងពិភពលោក ប្រព័ន្ធនៃការបែងចែកទ្រព្យរបស់មតកជនមានពីរប្រភេទគឺ តាមប្រព័ន្ធជម្រះបញ្ជី និងតាមប្រព័ន្ធទទួលបន្តដោយស្វ័យប្រវត្តិ។ ចំពោះប្រព័ន្ធទាំងពីរនេះមានគុណសម្បត្តិ និងគុណវិបត្តិរបស់វារៀងៗខ្លួន។

ចំពោះប្រព័ន្ធទទួលទ្រព្យសម្បត្តិតាមរយៈជាជម្រះបញ្ជី គឺត្រូវជម្រះបញ្ជីទាំងអស់នូវសិទ្ធិលើបំណុល និងកាតព្វកិច្ចរបស់មតកជន មានន័យថា នៅពេលដែលសន្តតិកម្មចាប់ផ្តើម (ពេលមតកជនទទួលមរណភាព) នោះគេត្រូវជួលសវនករមកធ្វើការជម្រះបញ្ជីថាតើទ្រព្យរបស់មតកជននោះមានទ្រព្យសកម្មប៉ុន្មាន ទ្រព្យអកម្ម (បំណុល) ប៉ុន្មាន។ ក្នុងករណីរកឃើញថាទ្រព្យអកម្មច្រើនជាងទ្រព្យសកម្ម នោះគេនឹងប្រកាសក្ស័យធន ដូច្នេះអ្នកស្នងមត៌ក (សន្តតិជន) មិនអាចទទួលបានទ្រព្យសម្បត្តិពីមតកជនបានឡើយ។ ប៉ុន្តែបើក្នុងករណីអ្នកជម្រះបញ្ជីរកឃើញថា ទ្រព្យសកម្មមានច្រើនជាងទ្រព្យអកម្ម នោះសន្តតិជនម្នាក់ៗនឹងទទួលបានទ្រព្យសកម្មនោះ ដោយពុំមានជាប់កាតព្វកិច្ចអ្វីទៀតឡើយ។ ប្រព័ន្ធនេះត្រូវចំណាយប្រាក់កាស និងពេលវេលាច្រើនណាស់ក្នុងការធ្វើការបែងចែកទ្រព្យរបស់មតកជន។

---

* លោក **កែ ប៊ុនធឿន** ជាប្រធាននាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ លោកមានតួនាទីជាទីប្រឹក្សាច្បាប់នៅការិយាល័យអង្គការសហប្រជាជាតិប្រយុទ្ធ ប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC)។ លោកក៏ជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យកម្ពុជាបង្រៀនលើមុខវិជ្ជានីតិសិទ្ធិមនុស្ស និងនីតិអន្តរជាតិឯកជន។ លោក **ប៊ុនធឿន** មានបទពិសោធន៍ការងារផ្នែកច្បាប់ជាង១០ឆ្នាំ ដែលនៅក្នុងនោះ លោកជាអតីតមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកកម្មវិធីច្បាប់ និងសិទ្ធិមនុស្សនៅអង្គការមូលនិធិអាស៊ី និងជាជំនួយការគម្រោងរបស់ JICA សម្រាប់បណ្តុះបណ្តាលចៅក្រម និងព្រះរាជអាជ្ញាលើក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។ ក្នុងឆ្នាំ២០១៥ លោកបានទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេស ឡាត វៀ (Latvia) ដោយបានបញ្ចប់ថ្នាក់អនុបណ្ឌិត នីតិអន្តរជាតិសាធារណៈ និងសិទ្ធិមនុស្ស។ ឆ្នាំ២០១៣ លោកក៏បានបញ្ចប់ថ្នាក់អនុបណ្ឌិតស្តីពី នីតិឯកជននៅសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចផងដែរ។

ដោយឡែកចំពោះប្រព័ន្ធទទួលមត៌កបន្តដោយស្វ័យប្រវត្តិវិញ គឺសន្តតិជនទទួលទ្រព្យពីមតកជនទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម។ មានន័យថា បើសន្តតិជនយល់ព្រមទទួលមត៌កពីមតកជនហើយនោះ ចំណែកដែលសន្តតិជនដែលទទួលគឺទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម។ ពេលខ្លះទ្រព្យអសកម្មច្រើនជាងទ្រព្យសកម្ម នោះវាជាបន្ទុកសម្រាប់សន្តតិជនត្រូវចេញសងនូវចំណែកនៃបំណុលដែលខ្លួនស្នងមត៌កពីមតកជនផងដែរ។ គុណសម្បត្តិនៃប្រព័ន្ធនេះ គឺមិនចំណាយពេលវេលាច្រើនក្នុងការចាត់ចែងទ្រព្យរបស់មតកជនទេ។ ម្យ៉ាងទៀត តាមសីលធម៌សន្តតិជនគួរជួយលាងបំណុលដល់មតកជនរបស់ខ្លួន នៅពេលដែលខ្លួនព្រមទទួលយកមត៌កទាំងនោះ។ បើតាមជំនឿខ្មែរវិញ គឺមិនចង់ឲ្យមតកជនខ្លួនទទួលរងទុក្ខកម្មនៅឋានអវីចីណាមួយឡើយ នៅពេលដែលមតកជននោះមិនបានសងបំណុលទៅម្ចាស់បំណុលមុន ឬក្រោយពេលស្លាប់នោះ។

នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ដែលមានប្រទេសជប៉ុនជួយគាំពារក្នុងការធ្វើសេចក្តីព្រាងក្រមនេះបានយកប្រព័ន្ធទី២ (ការទទួលមត៌កបន្តដោយស្វ័យប្រវត្តិ) មកអនុវត្តពីព្រោះ ប្រព័ន្ធនេះមានភាពងាយស្រួលសម្រាប់បរិបថកម្ពុជា។

ក្នុងការអនុវត្តរស់នៅប្រចាំថ្ងៃ គ្រួសារខ្លះបានបញ្ជូនកូនចៅរបស់ខ្លួនទៅរៀនសូត្រ ឬឲ្យទៅរស់នៅក្រៅប្រទេស ពេលខ្លះពួកគាត់ក៏ទទួលបាននូវសញ្ជាតិពីប្រទេសដែលពួកគាត់រស់នៅដែរ។ នៅក្នុងច្បាប់សញ្ជាតិកម្ពុជា មិនបានហាមឃាត់ចំពោះជនជាតិខ្មែរតម្រូវឲ្យមានតែសញ្ជាតិខ្មែរតែមួយឡើយ លើកលែងតែមានច្បាប់ចែងពិសេសប៉ុណ្ណោះ។[71]

ក្នុងករណីសន្តតិជនជាជនបរទេស ឬមានសញ្ជាតិបរទេស តើក្រមរដ្ឋប្បវេណីអនុញ្ញាតឲ្យសន្តតិជននោះអាចទទួលមត៌ក ពីមតកជនជាជនជាតិខ្មែរដែលមានសញ្ជាតិជាខ្មែរបានដែរឬទេ?

## ២. ក្នុងទិដ្ឋភាពអន្តរជាតិ

នៅក្នុងអត្ថបទនេះ អ្នកនិពន្ធមិនលើកយកទម្រង់នៃការធ្វើសន្តតិកម្មមកពិភាក្សាឡើយ តែអ្នកនិពន្ធធ្វើការសិក្សាលើករណីពាក់ព័ន្ធនឹងអនុភាពនៃសាលក្រមបរទេស និងសាលក្រមនៃតុលាការខ្មែរលើរឿងសន្តតិកម្មប៉ុណ្ណោះ។

[71] ឧទាហរណ៍ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឆ្នាំ២០១៥ ដែលតម្រូវឲ្យសមាសភាពគណៈកម្មាធិការរៀបចំការបោះឆ្នោតត្រូវតែមានសញ្ជាតិខ្មែរពីកំណើត និងមានសញ្ជាតិខ្មែរមួយគត់ក្នុងពេលបំពេញការងារ (មាត្រា ៥)។

ក្នុងករណីសន្តតិជនមានសញ្ជាតិបរទេស នោះគាត់មិនអាចទទួលបានមត៌ក ឬអច្ច័យ-ទាន[72]ជាដីធ្លីពីមតកជនជាជនជាតិខ្មែរបានឡើយ ប៉ុន្តែដីដែលជាមត៌កនោះនឹងក្លាយទៅជានីតិ-បុគ្គល[73] ហើយការគ្រប់គ្រង និងការចាត់ចែងដីធ្លីនោះ ត្រូវធ្វើឡើង ដោយសន្តតិជនដែលមានលំដាប់សន្តតិកម្មមុន។[74] នៅពេលដីនោះក្លាយជានីតិបុគ្គល នៅក្នុងក្រមរដ្ឋប្បវេណីអនុញ្ញាតឲ្យសន្តតិជនជាជនបរទេសនោះអាចលក់ដីក្នុងអំឡុងពេលបីខែ ក្រោយពីខ្លួនយល់ព្រមទទួលមត៌កពីមតកជន។ ក្នុងករណីសន្តតិជនមិនបានលក់ដីក្នុងអំឡុងពេលបីខែនេះទេ សន្តតិជនដែលមានសញ្ជាតិបរទេសនោះមិនអាចចាត់ចែងទ្រព្យមត៌ក(ដី)នោះឡើយ ដូច្នេះដីនោះនឹងក្លាយទៅជាគ្មានម្ចាស់ (ក្នុងករណីគ្មានសន្តតិជនលំដាប់បន្ទាប់) ហើយធ្លាក់ទៅជាកម្មសិទ្ធិរបស់រដ្ឋដោយស្វ័យប្រវត្តិ។ មានករណីលើកលែង ចំពោះជនបរទេសអាចទទួលបាននូវកម្មសិទ្ធិអាគារសហកម្មសិទ្ធិចាប់ពីជាន់ទី១ឡើងទៅ។[75] ដូច្នេះសន្តិជនបរទេសអាចទទួលបានមត៌កពីមតកជនរបស់ខ្លួនបានដែរ។

ក្នុងករណីខ្លះ មតកជនខ្មែរមានសន្តតិជនមានសញ្ជាតិបរទេសច្រើននាក់រស់នៅក្រៅប្រទេស ហើយពួកគេមានជម្លោះពាក់ព័ន្ធនឹងមត៌ក ថាតើតុលាការមួយណាមានសមត្ថកិច្ចដោះស្រាយរឿងក្តី (តុលាការកម្ពុជា ឬតុលាការបរទេសស្ថិតនៅទីលំនៅរបស់សន្តតិជន)នេះ ឬយ៉ាងណា។ ប្រសិនបើមតកជនបានទទួលមរណភាពនៅកម្ពុជា នោះតុលាការនៃលំនៅឋាន ឬទីសំណាក់របស់មតក-ជនមានសមត្ថកិច្ចដោះស្រាយលើជម្លោះមត៌កនោះ[76] ដោយតម្រូវឲ្យសន្តតិជនទាំងនោះដាក់ពាក្យបណ្តឹងមកតុលាការកម្ពុជាដើម្បីដោះស្រាយ។ សន្តតិជនដែលជាជនជាតិបរទេសនោះ ត្រូវមានលិខិតបញ្ជាក់ថា ពួកគេមានជាប់ពាក់ព័ន្ធនឹងមតកជន ដូចជា កូនបង្កើត កូនស្មុំ ឬជាជនដែលមានឧបនិស្ស័យពិសេស[77]ដែលអាចទទួលមត៌កពីមតកជនបាន។

[72] អច្ច័យទានជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួន តាមរយៈមតកសាសន៍។ ដកស្រង់ចេញពីសទ្ទានុក្រមផ្នែករដ្ឋប្បវេណី បោះពុម្ពដោយក្រសួងយុត្តិធម៌ឆ្នាំ២០១០។

[73] នីតិបុគ្គល ជាក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច។ ដកស្រង់ចេញពីសទ្ទានុក្រមផ្នែករដ្ឋប្បវេណី បោះពុម្ពដោយក្រសួងយុត្តិធម៌ឆ្នាំ២០១០។

[74] មាត្រា ១១៥៥ កថាខណ្ឌទី៣ ក្រមរដ្ឋប្បវេណី។

[75] មាត្រា ៦ នៃច្បាប់ស្តីពី ការផ្តល់កម្មសិទ្ធិលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិដល់ជនបរទេសចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០ "អនុញ្ញាតឲ្យជនបរទេសមានកម្មសិទ្ធិលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិចាប់ពីជាន់ទី១ទៅ"។

[76] មាត្រា ៩ (ឈ) ក្រមនីតិវិធីរដ្ឋប្បវេណី។

[77] បុគ្គលដែលមិនមែនជាសន្តតិជន តែមានជីវភាពរស់នៅជាមួយគ្នានឹងមតកជន ឬជាបុគ្គលដែលបានខិតខំមើលព្យាបាលមតកជនជាអាទិ៍។ ដកស្រង់ចេញពីសទ្ទានុក្រមផ្នែករដ្ឋប្បវេណី បោះពុម្ពដោយក្រសួងយុត្តិធម៌ឆ្នាំ២០១០។

នៅក្នុងទិដ្ឋភាពអន្តរជាតិ ច្បាប់កម្ពុជាទទួលស្គាល់សេចក្តីសម្រេចរបស់តុលាការបរទេស កាលបើសាលក្រមនៃតុលាការបរទេសនោះបានបញ្ជាក់ថា បានចូលជាស្ថាពរ ហើយត្រូវមានអានុភាព លុះត្រាតែបំពេញតាមលក្ខខណ្ឌដូចចែងនៅក្នុងមាត្រា ១៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ក្នុងមាត្រា ១៩៩ បានកំណត់ថាៈ

*ក- បើសិទ្ធិជម្រះក្តីរបស់តុលាការបរទេសត្រូវបានទទួលស្គាល់ ដោយច្បាប់ ឬសន្ធិសញ្ញា ឬ អនុសញ្ញាដែលព្រះរាជាណាចក្រកម្ពុជាជាភាគី។*

*ខ- បើចុងចម្លើយដែលចាញ់ក្តី បានទទួលការបញ្ជូនដីកាកោះហៅ ឬដីកាបង្គាប់ដែលចាំបាច់ដើម្បីចាប់ផ្តើមនីតិវិធី ឬមិនបានទទួលទេ តែបានឆ្លើយដោះសារតបចំពោះបណ្តឹងនោះ។*

*គ- បើខ្លឹមសារនៃសាលក្រម និងនីតិវិធីនៃបណ្តឹងនោះ មិនប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់ល្អនៃព្រះរាជាណាចក្រកម្ពុជា។*

*ឃ- <u>បើមានការធានាទៅវិញទៅមករវាងព្រះរាជាណាចក្រកម្ពុជា និងបរទេស</u>។*

បើខ្លឹមសារនៃសាលក្រមបរទេសនោះ បានបំពេញតាមលក្ខខណ្ឌតាមមាត្រាខាងលើ ភាគីដែលពាក់ព័ន្ធអាចសុំឲ្យតុលាការកម្ពុជាអាចអនុវត្តបាន ដោយតុលាការកម្ពុជាមិនពិចារណាអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការចេញសាលក្រមរបស់តុលាការបរទេសឡើយ។[78] ច្បាប់កម្ពុជាមិនទាមទារឲ្យភាគីចាញ់ក្តី ឬកូនបំណុលបញ្ជាក់ថា សាលក្រមតុលាការបរទេសនោះចេញសេចក្តីសម្រេចដោយខុសច្បាប់ឬយ៉ាងណាឡើយ ពីព្រោះតុលាការកម្ពុជាមិនមានសមត្ថកិច្ចក្នុងការវិនិច្ឆ័យពីភាពស្របច្បាប់ ឬមិនស្របច្បាប់នៃការចេញសាលក្រមរបស់តុលាការបរទេសនោះទេ ដោយសារតុលាការបរទេសបានបំពេញកិច្ចនីតិវិធីរបស់ខ្លួន នៅក្នុងច្បាប់ជាតិរបស់ពួកគេរួចរាល់ហើយ។ នៅក្នុងខ្លឹមសារនៃមាត្រាខាងលើនេះ បើយើងពិនិត្យមើលចំណុច (ក) ខាងលើបានកំណត់ថា "*បើសិទ្ធិជម្រះក្តីរបស់តុលាការបរទេសត្រូវបានទទួលស្គាល់ដោយច្បាប់ ឬសន្ធិសញ្ញា ឬអនុសញ្ញាដែលព្រះរាជាណាចក្រកម្ពុជាជាភាគី។*" ក្នុងឃ្លានេះមានន័យថា បើកម្ពុជាមិនបានចូលជាសមាជិកនៃសន្ធិសញ្ញាណាមួយទេ នោះកម្ពុជានឹងមិនទទួលស្គាល់នូវសាលក្រមរបស់តុលាការបរទេសនោះឡើយ។ ឧទាហរណ៍ កម្ពុជាមិនបានចូលជាសមាជិកនៃអង្គសន្និសីទឡាអេស្តីពី នីតិអន្តរជាតិឯកជន (តទៅនេះហៅកាត់ថា សន្និសីទឡាអេ) នោះប្រទេសដែលជាសមាជិកនៃអង្គសន្និសីទនេះមិនអាចយកសាលក្រមរបស់ខ្លួនមកឲ្យតុលាការកម្ពុជាអនុវត្តឡើយ។ ផ្ទុយមកវិញ

---

[78] មាត្រា ៣៩២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ច្បាប់កម្ពុជា (ព្រះរាជក្រមលេខនស/រកម/០៧០១/១០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ច្បាប់ស្តីពី ការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តិករបរទេស) ក៏មានការទទួលស្គាល់នូវសេចក្តីសម្រេចមជ្ឈត្តិករបរទេសផងដែរ ដោយកម្ពុជាបានយកខ្លឹមសារទាំងស្រុងនៃអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការទទួលស្គាល់ និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តិករបរទេសដែលធ្វើនៅទីក្រុងញូវយ៉កថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៥៨។

កម្ពុជាក៏ដូចគ្នាដែរ គឺមិនអាចយកសាលក្រមនៃតុលាការរបស់ខ្លួនទៅសុំឲ្យតុលាការបរទេសអនុវត្ត ដោយគ្មានការព្រមព្រៀងគ្នារវាងប្រទេសកម្ពុជា និងប្រទេសនោះជាមុនឡើយ។

ក្នុងករណី មតកជនជាជនជាតិខ្មែររស់នៅកម្ពុជា តែមានទ្រព្យនៅបរទេស ហើយតុលាការកម្ពុជាបានធ្វើការបែងចែកទ្រព្យទាំងនោះឲ្យសន្តតិជនរៀងៗខ្លួន។ សន្តតិជននោះអាចយកសាលក្រមស្ថាពរនោះទៅសុំឲ្យតុលាការបរទេសអនុត្ត តាមខ្លឹមសារនៃសាលក្រមតុលាការខ្មែរនោះបាន កាលបើតុលាការបរទេសនោះទទួលយល់ព្រមក្នុងការទទួលយកសាលក្រមតុលាការកម្ពុជាទៅអនុវត្តលើទឹកដីរបស់ពួកគេដែរ។ នេះជាគោលការណ៍ស្មើភាពក្នុងវិស័យយុត្តិធម៌ និងនយោបាយបរទេសនៃប្រទេសនីមួយៗលើពិភពលោក។

ដើម្បីមានភាពងាយស្រួល ក្នុងការអនុវត្តសាលក្រមតុលាការកម្ពុជានៅបរទេស លើពិភព-លោក កម្ពុជាគួរចូលជាសមាជិកនៅក្នុងសន្និសីទឡាអេនេះ។ ពីព្រោះខ្លឹមសារនៃសាលក្រមកម្ពុជាអាចយកទៅអនុវត្តនៅប្រទេសផ្សេងៗបាន នៅក្នុងរដ្ឋសមាជិកនៃសន្និសីទឡាអេនេះ។ សន្និសីទឡាអេនេះមានបេសកកម្មសំខាន់គឺ ដើម្បីធ្វើយ៉ាងណា "ឲ្យមានដំណើរការនៃឯកភាពគ្នា" លើវិធានអន្តរជាតិឯកជន។ សន្និសីទនេះជម្រុញឲ្យមាននូវកិច្ចឯកភាពជាអន្តរជាតិលើបញ្ហាដូចជា អំណាចយុត្តាធិការតុលាការ ច្បាប់ដែលអាចអនុវត្តបាន និងការទទួលស្គាល់ និងការអនុវត្តសាលក្រមឲ្យមានលក្ខណៈទូលំទូលាយដែលទាក់ទងនឹងច្បាប់ពាណិជ្ជកម្ម ច្បាប់ធនាគារ និងនីតិវិធីរដ្ឋប្បវេណីអន្តរជាតិ និងការការពារកុមារទាក់ទងនឹងអាពាហ៍ពិពាហ៍ និងឋានៈបុគ្គល។[79] នៅក្នុងតំបន់អាស៊ីអាគ្នេយ៍នេះមានប្រទេសតែបួន (ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងវៀតណាម)[80] ប៉ុណ្ណោះដែលបានចូលនៅក្នុងអង្គភាពនេះ។ សន្និសីទឡាអេនេះជាអង្គការអន្តររដ្ឋាភិបាលសាកលមួយ[81] ដែលមានសមាជិកចំនួន ៨២រដ្ឋសមាជិក (៨១រដ្ឋ និងសហគមន៍អឺរ៉ុប) តំណាងឲ្យទ្វីបទាំងអស់លើពិភពលោក។ វាជាការងាយស្រួលសម្រាប់កម្ពុជាផងដែរក្នុងការអនុវត្តវិធាននៃសន្តតិកម្ម ឬច្បាប់ផ្សេងៗទៀតទាក់ទងទៅនឹងវិស័យអន្តរជាតិឯកជន បើកម្ពុជាចូលជាសមាជិកនៅក្នុងសន្និសីទឡាអេនេះ។ គេសម្គាល់ឃើញថា ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាថ្ងៃទី ២៩ ឧសភា ១៩៩៣ ស្តីពីការការពារកុមារ និងកិច្ចសហប្រតិបត្តិការលើកិច្ចការសុំកូនអន្តរប្រទេស[82] នៃសន្និសីទឡាអេនេះផងដែរ។ ផលប្រយោជន៍នៃការចូលជាសមាជិកសន្និសីទឡាអេនេះ គឺរាល់សេចក្តីសម្រេចនៃតុលាការនៃរដ្ឋសមាជិក អាចយកទៅអនុវត្តនៅរដ្ឋសមាជិក

---

[79] សូមមើលគេហទំព័រ https://www.hcch.net/en/about

[80] រហូតមកដល់ខែមិថុនា ឆ្នាំ២០១៧ នៅអាស៊ីអាគ្នេយ៍នេះមានតែប្រទេស៤ប៉ុណ្ណោះដែលបានចូលជាសមាជិកនៃអង្គសន្និសីទឡាអេ សូមមើលគេហទំព័រ https://www.hcch.net/en/states/hcch-members

[81] សូមមើលគេហទំព័រ https://www.hcch.net/en/about

[82] សូមមើលគេហទំព័រ https://www.hcch.net/en/states/other-connected-states/details2/?sid=221

ផ្សេងៗទៀត ដោយមិនចាំបាច់មានការព្រមព្រៀងទ្វេភាគី ឬពហុភាគីរវាងប្រទេសទាំងនោះឡើយ។[83]

ប្រទេសដែលជាសមាជិកនៃសហគមន៍អឺរ៉ុបបានចូលរួមធ្វើជាសមាជិក នៃសន្និសីទឡាអេទាំងអស់ មិនត្រឹមតែប៉ុណ្ណោះសហគមន៍អឺរ៉ុបបានពង្រីកនូវខ្លឹមសារនៃច្បាប់អន្តរជាតិឯកជនទាំងនោះសម្រាប់បម្រើផលប្រយោជន៍ដល់សហគមន៍របស់ខ្លួនផងដែរ នៅក្នុងនោះសហគមន៍អឺរ៉ុបបានអនុម័តនូវវិធានលេខ No. 650/2012 ដែលបានអនុម័តដោយសភា និងក្រុមប្រឹក្សាអឺរ៉ុបនៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១២ ស្ដីពី យុត្តាធិការច្បាប់អាចអនុវត្តបាន និងការអនុវត្តសេចក្ដីសម្រេច និងការទទួលយក និងការអនុវត្តនៃលិខិតតូបករណ៍យថាភូតក្នុងរឿងសន្តតិកម្ម និងការបង្កើតវិញ្ញាបនបត្រនៃសន្តតិកម្ម។[84] សហគមន៍អឺរ៉ុបក៏បានចេញនូវវិធានលេខ No. 1329/2014[85] ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពី ការបង្កើតនូវទម្រង់នៃមតកសាសន៍សម្រាប់យកទៅអនុវត្តនៅក្នុងប្រទេសសមាជិកទាំងមូលផងដែរ។ ជាគោលការណ៍ សាលក្រមនៃប្រទេសមួយនៅក្នុងសហគមន៍ត្រូវបានទទួលស្គាល់ និងយកទៅអនុវត្តជាស្វ័យប្រវត្តិ[86] នៅប្រទេសផ្សេងទៀតនៅក្នុងសហគមន៍អឺរ៉ុបទាំងមូលបាន៕

(នៅមានតនៅលេខក្រោយ)

---

[83] មាត្រា ៣ នៃអនុសញ្ញាថ្ងៃទី១ កុម្ភៈ ១៩៧១ ស្ដីពីការទទួលស្គាល់ និងការអនុវត្តសាលក្រមតុលាការបរទេសក្នុងរឿងរដ្ឋប្បវេណី និងពាណិជ្ជកម្ម។ សូមមើលគេហទំព័រ https://www.hcch.net/en/instruments/conventions/full-text/?cid=78

[84] សូមមើលគេហទំព័រ http://eur-lex.europa.eu/legal-content/EN/TXT/?uri=celex%3A32012R0650

[85] សូមមើលគេហទំព័រ http://publications.europa.eu/en/publication-detail/-/publication/25d82b78-8291-11e4-89f7-01aa75ed71a1/language-en

[86] សូមមើលគេហទំព័រ http://ec.europa.eu/justice/civil/family-matters/successions/index_en.htm

# សកម្មភាពរបស់គណៈមេធាវី

## ១. មហាសន្និបាតប្រចាំឆ្នាំរបស់គណៈមេធាវី ដើម្បីបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីអាណត្តិទី ១១ និងពិធីផ្ទេរតំណែងប្រធានគណៈ-មេធាវី

### មហាសន្និបាតប្រចាំឆ្នាំ

សកម្មភាពមហាសន្និបាតប្រចាំឆ្នាំលើកទី២១ ប្រព្រឹត្តទៅនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៦ របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីអាណត្តិទី ១១ នៅសណ្ឋាគារ រ៉េស៊ីដង់ សុខាភ្នំពេញ។



### ពិធីផ្ទេរតំណែងប្រធានគណៈមេធាវី អាណត្តិទី១០ ជូនប្រធានគណៈមេធាវីអាណត្តិទី១១

នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំពិធីផ្ទេរតំណែងប្រធានគណៈមេធាវី អាណត្តិទី១០ ជូនប្រធានគណៈមេធាវី អាណត្តិទី១១ ពិធីចែកវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវីដល់សិស្សមេធាវីជំនាន់ទី១៣ ទី១៤ និងពិធីចែក-វិញ្ញាបនបត្រសុក្រឹតការវិជ្ជាជីវៈមេធាវីសម្រាប់មេធាវីចូលប្រកបវិជ្ជាជីវៈមេធាវី តាមមាត្រា៣២ នៃច្បាប់ស្ដីពី លក្ខន្តិកៈមេធាវី ព្រមទាំងពិធីជប់លៀង អបអរសាទរប្រធានគណៈមេធាវីអាណត្តិទី១១ ក្រោមអធិបតីភាពរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី **ឱម យ៉ិនទៀង** ប្រធានអង្គភាពប្រឆាំងអំពើ-

ពុករលួយ។ ពិធីនេះមានការអញ្ជើញចូលរួមពីសមាជិករាជរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ ប្រធានស្ថាប័នតុលាការ និងអយ្យការរាជធានី-ខេត្ត សិស្សមេធាវី និងមេធាវីដែលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា ៣២ សរុបប្រមាណ ៤៥០រូប។

សិស្សមេធាវីជ័យលាភី ជំនាន់ទី១៣ ទី១៤ ព្រមទាំងមេធាវីចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃច្បាប់ស្តីពី លក្ខន្តិកៈមេធាវីដែលត្រូវទទួលវិញ្ញាបនបត្រមានចំនួនសរុប ៣៨៥រូប។ បន្ទាប់ពីចប់ពិធីចែកវិញ្ញាបនបត្រ គណៈមេធាវីបានរៀបចំពិធីជប់លៀងអបអរសាទរប្រធានគណៈមេធាវីអាណត្តិទី១១ ដោយមានការចូលរួមពីសំណាក់សមាជិក-សមាជិកាគណៈមេធាវី និងភ្ញៀវកិត្តិយសយ៉ាងច្រើន ក្រោមបរិយាកាសសប្បាយរីករាយ។



## ២. គោលនយោបាយមូលនិធិសុខុមាលភាពមេធាវី

នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានចេញសេចក្តីសម្រេចលេខ ១០០/សសគម/១៧ ស្តីពី គោលនយោបាយមូលនិធិសុខុមាលភាពមេធាវី។ គោលនយោបាយនេះមានគោលបំណងដើម្បីជួយសម្រាលបន្ទុកហិរញ្ញវត្ថុ ដល់មេធាវី និងក្រុម-គ្រួសារមេធាវីដែលទទួលរងទុព្វលភាព ឬមរណភាព ព្រមទាំងដើម្បីបង្ហាញសាមគ្គីភាព និងការយកចិត្តទុកដាក់របស់សមាជិកទាំងអស់នៃគណៈមេធាវី ចំពោះក្រុមគ្រួសារនៅក្នុងគ្រាមានទុក្ខ-លំបាក។

គោលនយោបាយមូលនិធិសុខមាលភាពនេះ បានកំណត់នូវលក្ខខណ្ឌដែលមេធាវីអាចទទួលបាននូវមូលនិធិមានដូចខាងក្រោមនេះ ៖

- មេធាវីកម្មសិក្សាដែលបង់វិភាគទានដោយស្ម័គ្រចិត្ត នៅក្នុងអំឡុងពេលធ្វើកម្មសិក្សា
- មេធាវីដែលបានប្រកបវិជ្ជាជីវៈមេធាវីរហូតដល់ថ្ងៃទទួលមរណភាព ឬ ទុព្វលភាព
- មេធាវីដែលសុំមិនប្រកបវិជ្ជាជីវៈ និងមេធាវីដែលនៅក្រៅបញ្ជី ហើយដែលបានបង់វិភាគទានគ្រប់តាមចំនួនដែលតម្រូវដោយគណៈមេធាវី
- មេធាវីដែលក្រុមប្រឹក្សាគណៈមេធាវីបានសម្រេចមិនបាច់ឲ្យបង់វិភាគទាន។

ខាងក្រោមជាខ្លឹមសារលំអិតនៃគោលនយោបាយមូលនិធិសុខុមាលភាពមេធាវី៖

# គោលនយោបាយមូលនិធិសុខុមាលភាពមេធាវី

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១. គោលបំណង

គោលនយោបាយនេះមានគោលបំណងដើម្បីជួយសម្រាលបន្ទុកហិរញ្ញវត្ថុ ដល់មេធាវី និងក្រុមគ្រួសារមេធាវីដែលទទួលរងទុព្វលភាព ឬមរណភាព ព្រមទាំងដើម្បីបង្ហាញសាមគ្គីភាព និងការយកចិត្តទុកដាក់របស់គណៈមេធាវីចំពោះមេធាវី និងក្រុមគ្រួសារមេធាវីនៅក្នុងគ្រាមានទុក្ខលំបាក។

### ប្រការ ២. ទិសដៅ

គោលនយោបាយនេះមានទិសដៅដើម្បីអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវីនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សានៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ឲ្យមានប្រសិទ្ធភាពខ្ពស់។

### ប្រការ ៣. វិសាលភាព

គោលនយោបាយនេះអនុវត្តចំពោះមេធាវី និងក្រុមគ្រួសារមេធាវីដូចមានចែងនៅក្នុងគោលនយោបាយនេះ។

### ប្រការ ៤. និយមន័យនៃទុព្វលភាព

ដែលហៅថាទុព្វលភាព គឺសភាពផ្លូវកាយ ឬផ្លូវស្មារតីមានវិការៈខ្លាំង ធ្វើឲ្យមេធាវីសាមីមិនអាចបំពេញការងារជាមេធាវីតទៅទៀតបាន ដោយមានការបញ្ជាក់ពីវេជ្ជបណ្ឌិតដែលមានការទទួលស្គាល់តាមច្បាប់។

## ផ្នែកទី ២

## បុគ្គលដែលមានសិទ្ធិទទួលអត្ថប្រយោជន៍នៃមូលនិធិសុខុមាលភាពមេធាវី

### ប្រការ ៥. មេធាវី

ស្របតាមលក្ខណៈវិនិច្ឆ័យដែលកំណត់ក្នុងផ្នែកទី៣ នៃគោលនយោបាយមូលនិធិសុខុមាលភាពមេធាវីនេះ មេធាវីដែលទទួលទុព្វលភាព ឬមរណភាព ត្រូវទទួលអត្ថប្រយោជន៍នៃមូលនិធិសុខុមាលភាពនេះដោយផ្ទាល់។

### ប្រការ ៦. សាច់ញាតិរបស់មេធាវី

សាច់ញាតិផ្ទាល់របស់មេធាវីដែលទទួលមរណភាព ត្រូវទទួលអត្ថប្រយោជន៍នៃមូលនិធិសុខុមាលភាពជំនួស ស្របតាមលក្ខខណ្ឌ និងនីតិវិធីដែលចែងក្នុងគោលនយោបាយមូល-និធិសុខុមាលភាពនេះ។

សាច់ញាតិផ្ទាល់របស់មេធាវី ហើយទទួលមរណភាពត្រូវទទួលអត្ថប្រយោជន៍នៃមូល-និធិសុខុមាលភាពជំនួសស្របតាមលក្ខខណ្ឌ និងនីតិវិធីដែលចែងក្នុងគោលនយោបាយមូលនិធិសុខុមាលភាពនេះ។

### ប្រការ ៧. បុគ្គលដែលបាត់បង់សិទ្ធិ

មេធាវីដែលមិនអាចទទួលអត្ថប្រយោជន៍នៃមូលនិធិសុខុមាលភាពមេធាវីគឺ ៖

- មេធាវីដែលត្រូវបានហាមឃាត់មិនឲ្យប្រកបវិជ្ជាជីវៈរហូតមកទល់ថ្ងៃមរណភាព ឬទុព្វលភាព។
- មេធាវីដែលធ្វើអត្តឃាត ឬបង្កើតទុព្វលភាពដោយចេតនា។

## ផ្នែកទី ៣

## លក្ខណៈវិនិច្ឆ័យដើម្បីកំណត់បុគ្គលដែលមានសិទ្ធិទទួលអត្ថប្រយោជន៍

### ប្រការ ៨. លក្ខណៈវិនិច្ឆ័យ

មេធាវីដែលត្រូវទទួលបានអត្ថប្រយោជន៍នៃមូលនិធិសុខមាលភាពមេធាវី ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោមនេះ ៖

- មេធាវីកម្មសិក្សាដែលបង់វិភាគទានដោយស្ម័គ្រចិត្ត នៅក្នុងអំឡុងពេលធ្វើកម្មសិក្សា។
- មេធាវីដែលបានប្រកបវិជ្ជាជីវៈមេធាវី ឬបង់វិភាគទានរហូតដល់ថ្ងៃទទួលមរណភាព ឬទុព្វលភាព។

**ប្រការ ៩. ផលប្រយោជន៍ដែលមេធាវីត្រូវទទួលបាន**

មេធាវីដែលទទួលទុព្វលភាព ដែលមានលិខិតបញ្ជាក់ពីវេជ្ជបណ្ឌិត ត្រូវទទួលបានអត្ថប្រយោជន៍នៃមូលនិធិសុខុមាលភាពមេធាវីចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល។

មេធាវីដែលទទួលមរណភាព ដែលបញ្ជាក់ដោយលិខិតមរណភាព ត្រូវទទួលបានអត្ថប្រយោជន៍នៃមូលនិធិសុខុមាលភាពមេធាវីចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល។

**ប្រការ ១០. អត្ថប្រយោជន៍ដែលសាច់ញាតិត្រូវទទួលបាន**

សហព័ទ្ធ ឬកូនរបស់មេធាវី ដែលទទួលមរណភាព ដែលមានលិខិតបញ្ជាក់មរណភាព ត្រូវទទួលបានអត្ថប្រយោជន៍នៃមូលនិធិសុខុមាលភាពមេធាវីក្នុងចំនួន ៤.០០០.០០០ (បួនលាន) រៀលក្នុងម្នាក់ៗ។

បើសហព័ទ្ធ ឬកូនរបស់មេធាវី ជាមេធាវីដែរ សហព័ទ្ធ ឬកូននោះ អាចទទួលបានតែអត្ថប្រយោជន៍នៃមូលនិធិមេធាវីក្នុងឋានៈខ្លួនជាមេធាវីដែលត្រូវទទួលអត្ថប្រយោជន៍ប៉ុណ្ណោះ។

សហព័ទ្ធ ឬកូនរបស់អតីតមេធាវីជាមរណជន មិនអាចទទួលអត្ថប្រយោជន៍នៃមូលនិធិសុខុមាលភាពមេធាវីបានទេ។

**ប្រការ ១១. ការសើរើចំនួនអត្ថប្រយោជន៍**

ក្រុមប្រឹក្សានៃគណៈមេធាវីអាចសើរើបង្កើនចំនួនអត្ថប្រយោជន៍នៃមូលនិធិសុខុមាលភាពមេធាវីក្នុងរយៈពេល ០២ (ពីរ)ឆ្នាំម្តង។

ការបង្កើននេះត្រូវផ្អែកលើលទ្ធភាពនៃមូលនិធិសុខុមាលភាពមេធាវី។

## ផ្នែកទី ៤
## នីតិវិធីនៃការស្នើសុំអត្ថប្រយោជន៍

**ប្រការ ១២. ការដាក់ពាក្យស្នើសុំអត្ថប្រយោជន៍**

ជនដែលមានសិទ្ធិស្នើសុំអត្ថប្រយោជន៍នៃមូលនិធិសុខុមាលភាពមេធាវីបានគឺ ៖

- មេធាវីដែលមានទុព្វលភាពផ្ទាល់ ក្នុងករណីដែលមេធាវីនោះអាចចុះហត្ថលេខា ឬផ្តិតមេដៃលើពាក្យសុំបានដោយខ្លួនឯង។

- សហព័ទ្ធ ឬកូន ក្នុងករណីដែលមេធាវីមានទុព្វលភាពមិនអាចចុះហត្ថលេខា ឬ ផ្តិត-មេដៃលើពាក្យសុំបានដោយខ្លួនឯង។
- សហព័ទ្ធ ឬកូន ក្នុងករណីដែលមេធាវីដែលត្រូវទទួលអត្ថប្រយោជន៍បានទទួលមរណភាព។

**ពាក្យស្នើសុំត្រូវភ្ជាប់មកជាមួយនូវ ៖**

- លិខិតបញ្ជាក់ទុព្វលភាព (ក្នុងករណីទុព្វលភាព) ដោយវេជ្ជបណ្ឌិតដែលមានការទទួលស្គាល់។
- លិខិតបញ្ជាក់មរណភាព (ក្នុងករណីមរណភាព) ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។
- លិខិតសម្គាល់ទំនាក់ទំនងគតិយុត្តរវាងអ្នកស្នើសុំ និងមេធាវីដែលត្រូវទទួលអត្ថ-ប្រយោជន៍ មានជាអាទិ៍ សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រកំណើត។
- ពាក្យស្នើសុំអត្ថប្រយោជន៍ត្រូវដាក់ចូលមកការិយាល័យរដ្ឋបាលនៃគណៈមេធាវី រួចហើយត្រូវបញ្ជូនមកជាបន្ទាន់ដល់អគ្គលេខាធិការនៃគណៈមេធាវី ដើម្បីត្រួតពិនិត្យមើលថា មេធាវីសាមីត្រូវតាមលក្ខខណ្ឌនៃការទទួលបានអត្ថប្រយោជន៍នៃមូលនិធិសុខុមាលភាពមេធាវី ព្រមទាំងលក្ខខណ្ឌហិរញ្ញវត្ថុដែលមានចែងក្នុងផ្នែកទី៣ នៃគោលនយោបាយនេះ។
- អគ្គលេខាធិការត្រូវធ្វើមូលវិចារណ៍ លើការស្នើសុំដើម្បីដាក់ជូនប្រធាននៃគណៈ-មេធាវីធ្វើការសម្រេច។

## ប្រការ ១៣. ការសម្រេចផ្តល់អត្ថប្រយោជន៍

ប្រធានគណៈមេធាវីការសម្រេចលើពាក្យសុំអត្ថប្រយោជន៍ដោយផ្អែកលើលក្ខខណ្ឌខាងក្រោម៖

- ចំនួនអប្បបរមានៃមូលនិធិដែលត្រូវបម្រុងទុក។
- សក្តានុពលនៃការស្នើសុំ។

ប្រធានអាចពន្យារការសម្រេចផ្តល់អត្ថប្រយោជន៍ទៅពេលណាមួយ ប្រសិនបើមូលនិធិសុខុមាលភាពមេធាវីស្រុតចុះមកដល់ចំនួនអប្បបរមាដែលត្រូវបម្រុងទុក ឬសក្តានុពលនៃការស្នើសុំនៅក្នុងពេលណាមួយ ធ្វើឲ្យមូលនិធិសុខុមាលភាពមេធាវីមិនអាចរក្សាចំនួនអប្បបរមានៃមូលនិធិបម្រុងទុករបស់ខ្លួនបាន។

## ផ្នែកទី ៥
## ការកំណត់ចំនួនអប្បបរមានៃមូលនិធិដែលត្រូវបម្រុងទុក

### ប្រការ ១៤. ការគ្រប់គ្រងមូលនិធិ

នៅដើមឆ្នាំសារពើពន្ធនីមួយៗ ក្រុមប្រឹក្សានៃគណៈមេធាវីត្រូវកំណត់ចំនួនអប្បបរមានៃមូលនិធិដែលត្រូវបម្រុងទុក ដោយពិចារណាទៅលើសក្តានុពលនៃការស្នើសុំអត្ថប្រយោជន៍នៅក្នុងឆ្នាំកន្លងមក។ ជាដំបូង ចំនួនអប្បបរមានៃមូលនិធិដែលត្រូវបម្រុងទុក យ៉ាងហោចណាស់មានចំនួន ៤.៥០០.០០០៛ (បួនលានប្រាំរយពាន់រៀល)។

ប្រធានគណៈមេធាវី ត្រូវរៀបចំរបាយការណ៍ស្តីពីការចំណាយ និងការចាត់ចែងមូលនិធិនេះជូនក្រុមប្រឹក្សាគណៈមេធាវីជារៀងរាល់ឆ្នាំ។

### ប្រការ ១៥. ប្រភពមូលនិធិ

ចំនួនទឹកប្រាក់នៃមូលនិធិនេះត្រូវបានមកពីការកាត់ប្រាក់ភាគទានសមាជិកភាពរបស់មេធាវីម្នាក់ៗចំនួនបីដុល្លារអាមេរិកក្នុងមួយត្រីមាស និងចំនួនមួយរយដុល្លារអាមេរិកពីប្រាក់ឧបត្ថម្ភចំនួន ២.០០០ ដុល្លារអាមេរិក ពីមេធាវីដែលចូលប្រកបវិជ្ជាជីវៈមេធាវីតាមលក្ខខណ្ឌមាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដើម្បីបញ្ចូលទៅក្នុងមូលនិធិនេះ។

សប្បុរសជនក៏អាចផ្តល់អំណោយសម្រាប់មូលនិធិនេះផងដែរ។

## ផ្នែកទី ៦
## ការធ្វើវិសោធនកម្ម និងការចូលជាធរមាននៃគោលនយោបាយមូលនិធិសុខុមាលភាពមេធាវី

### ប្រការ ១៦. ការធ្វើវិសោធនកម្ម

ការធ្វើវិសោធនកម្មនៃគោលនយោបាយមូលនិធិសុខុមាលភាពមេធាវីអាចធ្វើទៅបានលុះត្រាតែមានសំឡេងគាំទ្រពីក្រុមប្រឹក្សាគណៈមេធាវីចំនួនពីរភាគបីនៃក្រុមប្រឹក្សាទាំងមូល។

### ប្រការ ១៧. ការចូលជាធរមាន

គោលនយោបាយមូលនិធិសុខុមាលភាពមេធាវីនេះ ចូលជាធរមានបន្ទាប់ពីក្រុមប្រឹក្សានៃគណៈមេធាវីបានអនុម័តដោយសំឡេងភាគច្រើនដោយធៀប និងចាប់ពីថ្ងៃប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការដោយប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ១៨. ការអនុវត្តន៍**

អគ្គលេខាធិការ ប្រធាននាយដ្ឋានបុគ្គលិករដ្ឋបាល និងហិរញ្ញវត្ថុ និងមេធាវីត្រូវអនុវត្តសេចក្ដីសម្រេចនេះតាមមុខការរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**
**ប្រធាន**

**សួន វិសាល**

# ៣.ទំនាក់ទំនងជាតិ និងអន្តរជាតិ

## ៣.១ ទំនាក់ទំនងជាតិ

### ការចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

នៅព្រឹកថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានដឹកនាំប្រតិភូគណៈមេធាវី ០៦រូប មានលោកមេធាវី **លីវ សុវណ្ណា** លោកស្រីមេធាវី **សៅ កញ្ញា** លោកមេធាវី **វ៉ា ពិសី** លោកមេធាវី **ជូ ចាន់ធីរ៉ា** ជាសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី លោកមេធាវី **ព្រហ្ម វិចិត្រអក្ខរា** អគ្គលេខាធិការគណៈមេធាវី និងលោកមេធាវី **យុង ផានិត** អនុប្រធាននាយកដ្ឋានការពារក្តីជូនជនក្រីក្រនៃគណៈមេធាវី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ពាក់ព័ន្ធនឹងការងារការពារក្តីជូនជនក្រីក្រ ការកែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ ព្រមទាំងកិច្ចសហការផ្សេងៗទៀត។



## សកម្មភាពលោកប្រធាន និងប្រតិភូគណៈមេធាវីចុះពិភាក្សាការងារជាមួយប្រធានសាលាដំបូងខេត្ត

ចាប់ពីខែមេសាដល់ ខែឧសភា ឆ្នាំ២០១៧ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានដឹកនាំប្រតិភូគណៈមេធាវី រួមមានលោកមេធាវី **ជូ ចាន់ធីរ៉ា** លោកមេធាវី **វ៉ា ពិសី** សមាជិកក្រុមប្រឹក្សាគណៈមេធាវី លោកមេធាវី **លីវ សុវណ្ណា** ប្រធាននាយកដ្ឋានការពារក្តីជូនជនក្រីក្រ លោកមេធាវី **យុង ផានិត** អនុប្រធាននាយកដ្ឋានការពារក្តីជូនជនក្រីក្រ និងលោកមេធាវី **យឹម សារី** នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ធ្វើដំណើរទៅកាន់សាលាដំបូងខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តកំពង់ធំ ដើម្បីប្រជុំពិភាក្សាជាមួយប្រធានសាលាដំបូងខេត្ត ពាក់ព័ន្ធនឹងការរៀបចំតុមេធាវីនៅក្នុងបន្ទប់សវនាការ ការផ្តល់ទិន្នន័យពាក់ព័ន្ធនឹងការការពារក្តីជូនជនក្រីក្រ ព្រមទាំងកិច្ចសហការផ្សេងៗទៀត។



### ការជួបសម្តែងការគួរសម

នៅព្រឹកថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានអនុញ្ញាតឲ្យលោកប្រធានសមាគម ហង់រីកាពីតង់កម្ពុជា និងក្រុមការងារចូលជួបសម្តែងការគួរសម និងអបអរសាទរ លោកមេធាវី **សួន វិសាល** ដែលបានជាប់ជាប្រធានគណៈមេធាវីអាណត្តិទី១១។ ក្នុងជំនួបសម្តែងការគួរសមនេះផងដែរ សមាគមហង់រីកាពីតង់បានស្នើសុំបន្តកិច្ចសហការជាមួយគណៈមេធាវី ក្នុងការពង្រឹងសមត្ថភាពមេធាវីក្នុងវិស័យព្រហ្មទណ្ឌ តាមរយៈការធ្វើសិក្ខាសាលារួមគ្នាដោយអញ្ជើញវាគ្មិន មានបទពិសោធន៍ធ្វើបទឧទ្ទេសនាម។

ឆ្លើយតបនឹងសំណើនេះ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីបានថ្លែងការកោតសរសើរ ចំពោះសមាគមហង់រីកាពីតង់កម្ពុជា ដែលបានជួយគណៈមេធាវីកន្លងមក និងបន្តសហការល្អរវាងគណៈមេធាវី និងវិស័យឯកជន។

## ៣.២ ទំនាក់ទំនងអន្តរជាតិ

### ជំនួបពិភាក្សាការងារ រវាងប្រធានគណៈមេធាវី ជាមួយតំណាងសមាគមច្បាប់ និងពាណិជ្ជកម្ម មកពីទីក្រុងម៉ុងពីលីយេ ប្រទេសបារាំង

នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅទីស្នាក់ការគណៈមេធាវី លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាអាណត្តិទី១១ បានជួបពិភាក្សាការងារជាមួយតំណាងសមាគមច្បាប់ និងពាណិជ្ជកម្មមកពីទីក្រុងម៉ុងពីលីយេ ប្រទេសបារាំង ដើម្បីរៀបចំសិក្ខាសាលាផ្លាស់ប្តូរទស្សនទានរវាង នីតិវិទូកម្ពុជា និងនីតិវិទូ បារាំង ស្តីពីយន្តការដោះស្រាយវិវាទពាណិជ្ជកម្មដែលនឹងគ្រោងធ្វើឡើងនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។ កិច្ចពិភាក្សានេះបានបញ្ចប់នៅវេលាម៉ោង ៩:៣០ នាទី នាថ្ងៃខែឆ្នាំដដែល។

### សកម្មភាពកិច្ចប្រជុំពិភាក្សា ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការរវាងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងអង្គការ JICA

នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលោកអគ្គលេខាធិការ លោកអគ្គលេខាធិការរងនៃគណៈមេធាវី បានជួបប្រជុំពិភាក្សាការងារជាមួយលោក **ផ្សឹជិ យ៉ាសឹហ៊ិខុ** ប្រធានទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ អមដោយទីប្រឹក្សាច្បាប់ និងទីប្រឹក្សារៀបចំគម្រោង (អភិបាលកិច្ច)។



## សកម្មភាពក្នុងសិក្ខាសាលាស្តីពី ការផ្លាស់ប្តូរទស្សនទានរវាងនីតិវិទូកម្ពុជា និងនីតិវិទូបារាំង

នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅសហសាល G1 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច លោកមេធាវី **ព្រហ្ម វិចិត្រអក្ខរា** អគ្គលេខាធិការគណៈមេធាវី បានចូលរួមសិក្ខាសាលាស្តីពី ការផ្លាស់ប្តូរទស្សនទានរវាងនីតិវិទូកម្ពុជា និងនីតិវិទូបារាំង ក្រោមអធិបតីភាព ឯកឧត្តម **អង្គ វង្សវឌ្ឍានា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង ឯកឧត្តម **អាទ្បាំង ហ្សតាំង** ភារៈធារីស្ថានទូតបារាំងប្រចាំកម្ពុជា ដែលសិក្ខាសាលានេះរៀបចំឡើងក្រោមកិច្ចសហការរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសមាគមច្បាប់ និងពាណិជ្ជកម្ម សាធារណរដ្ឋបារាំង។ ក្នុងឱកាសនោះដែរ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានទទួលនូវមេដាយ នៃកិច្ចសហប្រតិបត្តិការសម្រាប់ការចូលរួមចំណែកផ្សព្វផ្សាយច្បាប់ពាណិជ្ជកម្ម។




## សកម្មភាពកិច្ចប្រជុំពិភាក្សាការងារ រវាងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងគណៈប្រតិភូមកពីប្រទេសជប៉ុន

នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានជួបប្រជុំពិភាក្សាការងារជាមួយលោកសាស្ត្រាចារ្យផ្នែកច្បាប់ **MATSUO Hiroshi** នៃសាកលវិទ្យាល័យ KEIO (University Law School) អមដោយសហការីមួយចំនួន។ អង្គប្រជុំបានពិភាក្សាផ្តោតលើសកម្មភាពសំខាន់ៗរបស់គណៈមេធាវីក្នុងការផ្តល់ការបណ្តុះបណ្តាលដល់មេធាវី, ការផ្សព្វផ្សាយឲ្យសាធារណជនឲ្យបានស្គាល់ពីតួនាទីរបស់មេធាវីនៅក្នុងសង្គម និងការគ្រប់គ្រងវិជ្ជាជីវៈមេធាវី។

## កិច្ចប្រជុំពិភាក្សាការងារ រវាងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសមាគមមេធាវីគ្មានព្រំដែន សាធារណរដ្ឋបារាំង

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលោកអគ្គលេខាធិការ លោកអគ្គលេខាធិការរងនៃគណៈមេធាវីបានជួបប្រជុំពិភាក្សាការងារជាមួយលោកស្រី **Magali Doisy** អ្នកសម្របសម្រួលកម្មវិធីនៃសមាគម

មេធាវីគ្មានព្រំដែន។ អង្គប្រជុំបានពិភាក្សាផ្តោតសំខាន់លើសកម្មភាពរបស់គម្រោងនៅខេត្តបាត់ដំបង រួមមានការផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ និងការការពារក្តីក្នុងសំណុំរឿងព្រហ្មទណ្ឌនាពេលកន្លងមក និងផែនការអនុវត្តបន្តសម្រាប់កិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរ។



## កិច្ចប្រជុំពិភាក្សាការងាររវាងគណៈមេធាវី និងអង្គការ JICA

នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលោកអគ្គលេខាធិការ និងលោកអគ្គលេខាធិការរងគណៈមេធាវីបានជួបប្រជុំពិភាក្សាការងារជាមួយអ្នកតំណាងនៃអង្គការ JICA អំពីការរៀបចំសិក្ខាសាលាក្នុងវិស័យរដ្ឋប្បវេណីនៅគណៈមេធាវី។

## កិច្ចប្រជុំពិភាក្សាការងាររវាងគណៈមេធាវី និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលោកអគ្គលេខាធិការ និងលោកអគ្គលេខាធិការរងគណៈមេធាវី

បានជួបប្រជុំពិភាក្សាការងារជាមួយមន្ត្រីសិទ្ធិមនុស្ស និងមន្ត្រីផ្នែកច្បាប់នៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា។



## ជំនួបពិភាក្សាការងាររវាងគណៈមេធាវី ជាមួយលោក Andrew Ianuzzi

នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលោកមេធាវី **ព្រហ្ម វិចិត្រអក្ខរា** អគ្គលេខាធិការគណៈមេធាវី បានទទួលជួបពិភាក្សាការងារជាមួយ **Andrew Ianuzzi** អតីតសហមេធាវីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពាក់ព័ន្ធនិងកិច្ចសហការរៀបចំសិក្ខាសាលា។

## ជំនួបពិភាក្សាការងាររវាងគណៈមេធាវី ជាមួយអង្គការ Destination Justice

នៅព្រឹកថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលោកមេធាវី **ព្រហ្ម វិចិត្រអក្ខរា** អគ្គលេខាធិការគណៈមេធាវី បានទទួលជួបពិភាក្សាការងារជាមួយអង្គការ **Destination Justice** ពាក់ព័ន្ធនិងកិច្ចសហការរៀបចំសិក្ខាសាលា ព្រមទាំងកិច្ចសហការផ្សេងៗទៀត។

## ការចុះទស្សនកិច្ចសិក្សារបស់សាស្ត្រាចារ្យ និងក្រុមនិស្សិតច្បាប់មកពីប្រទេសអូស្ត្រាលី

នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ នៅទីស្នាក់ការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

លោកមេធាវី **ព្រហ្ម វិចិត្រអក្ខរា** អគ្គលេខាធិការគណៈមេធាវី លោកមេធាវី **លីវ សុវណ្ណា** ប្រធាននាយកដ្ឋានការពារក្ដីជូនជនក្រីក្រនៃគណៈមេធាវី ព្រមទាំងបុគ្គលិកគណៈមេធាវីបានទទួលជួបជាមួយសាស្ត្រាចារ្យ និងក្រុមនិស្សិតច្បាប់មកពីប្រទេសអូស្ត្រាលីដែលបានចុះមកធ្វើទស្សនកិច្ចសិក្សាសាកសួរព័ត៌មានពាក់ព័ន្ធនឹងវិជ្ជាជីវៈមេធាវីនៅព្រះរាជាណាចក្រកម្ពុជា និងប្រតិបត្តិការការពារក្ដីជូនជនក្រីក្ររបស់គណៈមេធាវី។



## ៤. មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី

## សកម្មភាពកិច្ចប្រជុំពិភាក្សា ពាក់ព័ន្ធនឹងការងារមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី

នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី១១ បានជួបប្រជុំពិភាក្សាការងារជាមួយលោកមេធាវី **យឹម សារី** នាយកមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី ដោយមានការចូលរួមពីលោកមេធាវី **ព្រហ្ម វិចិត្រអក្ខរា** អគ្គលេខាធិការ អគ្គលេខាធិការរងនៃគណៈមេធាវី អគ្គលេខាធិការមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី ប្រធានមណ្ឌលច្បាប់ ព្រមទាំងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀត។

អង្គប្រជុំបានពិភាក្សាទៅលើរបៀបវារៈដូចខាងក្រោម៖

១-របាយការណ៍សកម្មភាពការងាររបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។

២-ផែនការសកម្មភាព និងទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៧។

៣-បញ្ហាផ្សេងៗ។



## ពិធីបើកបវេសនកាលសម្រាប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីជំនាន់ទី ១៥

នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី បានរៀបចំពិធីបើកបវេសនកាលសម្រាប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីជំនាន់ទី ១៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។



## ការសម្ភាសន៍ជ្រើសរើសគ្រូបង្រៀនមុខវិជ្ជា ការវិភាគក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

នៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៧ នៅទីស្នាក់ការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា លោកមេធាវី **ព្រហ្ម វិចិត្រអក្ខរា** អគ្គលេខាធិការគណៈមេធាវី និងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីក្នុងនាមជាគណៈកម្មការសម្ភាសន៍ បានធ្វើការសម្ភាសន៍សមាជិក-សមាជិកាគណៈមេធាវីដែលបានដាក់ពាក្យស្នើសុំបង្រៀនមុខវិជ្ជា ការវិភាគក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ដល់អ្នកដែលចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។

## ការបណ្តុះបណ្តាល សិក្ខាសាលាស្តីពីការគ្រប់គ្រងសំណុំរឿង និងរបៀបសរសេរសំអាងហេតុ

នៅថ្ងៃទី២៤ និង២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅសណ្ឋាគារកាំបូឌីយ៉ាណា សមាជិក-សមាជិកាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានចូលរួមសិក្ខាសាលាស្តីពីការគ្រប់គ្រងសំណុំរឿង និងរបៀបសរសេរសំអាងហេតុ សហការរៀបចំដោយសាលាឧទ្ធរណ៍ និងអង្គការ IRZ ដែលទទួលជំនួយពីក្រសួងយុត្តិធម៌នៃសហព័ន្ធអាល្លឺម៉ង់។ អង្គសិក្ខាសាលានេះធ្វើឡើងដើម្បីចែករំលែកនូវបទពិសោធន៍ពីអ្នកជំនាញការច្បាប់នៃសហព័ន្ធអាល្លឺម៉ង់ ដល់ចៅក្រម មន្ត្រីគ្រប់គ្រងរដ្ឋបាលក្នុងប្រព័ន្ធតុលាការ និងភាគីពាក់ព័ន្ធ ឲ្យយល់ដឹងពីរបៀបគ្រប់គ្រងសំណុំរឿងតាមប្រព័ន្ធព័ត៌មានវិទ្យា របៀបតាក់តែងសាលក្រម និងសាលដីកា ប្រកបដោយគុណភាព។



## វគ្គបណ្តុះបណ្តាលស្តីពី "សិទ្ធិការពារខ្លួនតាមផ្លូវតុលាការ"

នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៦ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានសហការជាមួយសមាគម **ហង់រី កាពីតង់ កម្ពុជា** ក្រោមជំនួយឧបត្ថម្ភពីស្ថានទូតបារាំងប្រចាំនៅកម្ពុជា រៀបចំវគ្គបណ្តុះបណ្តាលស្តីពី **"សិទ្ធិការពារខ្លួនតាមផ្លូវតុលាការ"** ក្រោមអធិបតីភាពលោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តមបណ្ឌិត **ថេង ច័ន្ទសង្វារ** ភារធារីប្រចាំសមាគមហង់រីកាពីតង់កម្ពុជា អនុរដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយមានការចូលរួមពីវាគ្មិនដែលមានបទពិសោធន៍យូរឆ្នាំក្នុងវិស័យច្បាប់ និងយុត្តាធិការ រួមមានលោកមេធាវី **លីវ សុវណ្ណា** លោកព្រះរាជអាជ្ញារង **លី សុផាណា** និងលោកចៅក្រម **Marcel LEMONDE**។




## ការបណ្តុះបណ្តាលបញ្ចប់វគ្គសុក្រឹតការចំពោះមេធាវីចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា ៣២

នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជារៀបចំការបណ្តុះបណ្តាលបញ្ចប់វគ្គសុក្រឹតការចំពោះការចូលប្រកបវិជ្ជាជីវៈមេធាវី តាមមាត្រា៣២នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី វគ្គទី២ នៅទីស្នាក់ការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដោយលោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាជាគ្រូឧទ្ទេសនាម។

# ៥. ផ្សេងៗ

## ការចូលរួមរំលែកទុក្ខដល់ក្រុមគ្រួសារសព របស់លោកមេធាវី ការ សារុត្ថ

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី ព្រមទាំងសមាជិក-សមាជិកាគណៈមេធាវី បានធ្វើដំណើរទៅចូលរួមពិធីបុណ្យសពរបស់លោកមេធាវី **ការ សារុត្ថ** នៅផ្ទះលេខ ៤៤១G ផ្លូវលេខ ១0២R២ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដែលលោកបានទទួលមរណភាពកាលពីថ្ងៃសុក្រ ទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦។

## ប្រធាន និងសមាជិក គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានអញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសព សម្តេចវិបុលបញ្ញា សុខ អាន

នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ប្រធាន សមាជិក-សមាជិកាក្រុមប្រឹក្សា សមាជិក-សមាជិកាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបុគ្គលិកបានអញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសព សម្តេចវិបុលបញ្ញា **សុខ អាន** ដែលតម្កល់ទុកនៅផ្ទះលេខ ៧0 ផ្លូវ២១៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ យើងខ្ញុំទាំងអស់គ្នា សូមគោរពបួងសួងឲ្យដួងព្រលឹងសម្តេចវិបុលបញ្ញា **សុខ អាន** ទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។



## ពិធីសូត្រមន្ត ប្រោះព្រំ លើករាសី ក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិ

នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ នៅទីស្នាក់ការគណៈមេធាវី លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី សមាជិក-សមាជិកាគណៈមេធាវី ព្រមទាំងបុគ្គលិកគណៈមេធាវី បានរៀបចំពិធីសូត្រមន្តប្រោះព្រំលើករាសី ក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១។



## ពិធីអបអរសាទរទិវាអន្តរជាតិនារី ៨ មីនា ខួបលើកទី ១០៦

នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ០៣:០០នាទីរសៀល គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានរៀបចំពិធីអបអរសាទរទិវាអន្តរជាតិនារី ៨ មីនា ខួបលើកទី ១០៦ ក្រោមប្រធានបទ "**ស្ត្រី ដើម្បីសុខសន្តិភាព និងវឌ្ឍនភាព**" ក្រោមអធិបតីភាពលោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ និងមានការអញ្ជើញចូលរួមជាកិត្តិយសពីសំណាក់លោកជំទាវ **ចាន់ សុទ្ធាវី** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និង ឯកឧត្តម **ជីវ សុងហាក់** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី សមាជិក-សមាជិកាគណៈមេធាវី ព្រមទាំងបុគ្គលិកស្ត្រីនៃគណៈមេធាវី។

បន្ទាប់ពីបង្ហាញនូវប្រវត្តិសិទ្ធិនារី អានព្រះរាជសារសម្តេចម៉ែ និងមតិសំណេះសំណាលរួចមក លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ បានផ្តល់កិត្តិយសជូនវត្ថុអនុស្សាវរីយ៍ជាសំពត់ផាមួង ជូនដល់មេធាវីស្ត្រីទាំងអស់ដែលបានចូលរួម និងបុគ្គលិកស្ត្រីនៃគណៈមេធាវី។ បន្ទាប់មកទៀត លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ បានអញ្ជើញភ្ញៀវដែលបានចូលរួមទាំងអស់ពិសាអាហារសាមគ្គី ដើម្បីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី ១០៦ នេះ។ កម្មវិធីជប់លៀងបានប្រព្រឹត្តទៅក្រោមបរិយាកាសសប្បាយរីករាយ ដែលឆ្លុះបញ្ចាំងពីការផ្តល់តម្លៃដល់មេធាវីស្ត្រី និងបុគ្គលិកស្ត្រីទាំងអស់នៃគណៈមេធាវី៕



## គណៈកម្មការព្រឹត្តិបត្រ

| | |
|---|---|
| ១-ឯកឧត្តម សួន វិសាល | ចាងហ្វាងការផ្សាយ |
| ២-លោកមេធាវី កុយ នាម | និពន្ធនាយក |
| ៣-លោកមេធាវី លីវ សុវណ្ណា | លេខាធិការ |

## នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ

| | |
|---|---|
| ១-លោក កែ ប៊ុនធឿន | ប្រធាននាយកដ្ឋាន |
| ២-លោកមេធាវី សេង សុខឃីម | អនុប្រធាននាយកដ្ឋាន |
| ៣-លោកមេធាវី ម៉ៃ ច័ន្ទសត្យា | អនុប្រធាននាយកដ្ឋាន |
| ៤-លោក ថ៉ា សំរិត | ប្រធានការិ. ព្រឹត្តិបត្រ |
| ៥-កញ្ញា គុណ ថាវី | លេខារដ្ឋបាល |
| ៦-លោកស្រី រី សុផល្លា | បណ្ណារក្ស |
| ៧-លោក ហួត សុវណ្ណា | បុគ្គលិកស្ម័គ្រចិត្ត |

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ

DFDL

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

អាសយដ្ឋានអគារកាច់ជ្រុងផ្លូវលេខ ១១២៩ កែងផ្លូវ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ : (៨៨៥-២៣) ៦២២ ៧០៧០ អ៊ីម៉ែល : info@bakc.org.kh គេហទំព័រ : www.bakc.org.kh